ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Dec-2015, 13:00
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥**

**ម៉ោង ០៩:១១នាទី**

**សវនាការលើកទី៣៤៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រី រតនៈ

លោក ឌែល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ស៊ិន ឆែម (2-TCW-820) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ស៊ិន ឆែម ឬ ស៊ីន ឆែម** (2-TCW-820)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៣
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ........ ទំព័រ ៧
សួរដោយលោក ស្រ៊ា រតនៈ ផ្តើមពី ........ ទំព័រ ៣០
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........ ទំព័រ ៣២
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី........ ទំព័រ ៦៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១១:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានមានរហស្សនាម 2-TCW-820។ ហើយមុននឹងបន្តកិច្ចដំណើរការសវនាការ ថ្ងៃនេះអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីក្នុងសំណុំរឿង០០២ទាំងអស់ឱ្យបានជ្រាបថា នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ និងថ្ងៃបន្តបន្ទាប់ទៀត ដោយលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ គាត់មានធុរៈចាំបាច់ផ្ទាល់ខ្លួន មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបាន បន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ម៉ាទីន ខារ៉ុបគីន ដែលជាចៅក្រមបម្រុងអន្តរជាតិជំនួសកន្លែង ក្លូឌា ហ្វេនស៍ ដែលអវត្តមានរហូតដល់ពេលណាដែលលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមសវនាការនៅក្នុងអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ហើយការអនុវត្តនេះដោយយោងទៅតាមខ្លឹមសារនៃបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ហើយតទៅនេះ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរសវនាការថ្ងៃនេះ។

[០៩:១២:៤៧]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោកមេធាវី ខលវីន សោនដឺស៍ មកយឺតដោយមូលហេតុស្ទះចរាចរណ៍ និងលោកមេធាវី ពេជ អង្គ តំណាងដើមបណ្តឹងរដ្ឋប្បវេណី (សុំទោស) សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានមួយសប្តាហ៍ ដោយមូលហេតុសុខភាពផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំ

លះបង់សិទ្ធិដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺមានរហស្សនាម 2-TCW-820។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញ។ សាក្សីស្ថិតនៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:១៤:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធិភាព ខ្លួនសុំលះបង់សិទ្ធិនិងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភ័ស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះខ្លាំង វិលមុខ មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថាសូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោយសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយពីបន្ទប់ឃុំខ្លួន

មួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-820 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១៧:២៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីសាក្សី។ តើលោកស្រីឈ្មោះអី? កុំអាលទាន់និយាយ ចាំៗក្បាលមីក្រូហ្វូនឲ្យភ្លើងក្រហមសឹមនិយាយណ៎ា! លោកស្រីឈ្មោះអី?

**លោកស្រី ស៊ិន ផែម៖**

**ឆ៖** ខ្ញុំ ស៊ិន ផែម។

**ស៖** អរគុណលោកស្រី ស៊ិន ផែម។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណាដែរ លោកស្រីចាំទេ? កុំអាលទាន់! កុំអាលទាន់ឆ្លើយ! លោកស្រីកើតនៅថ្ងៃខែឆ្នាំណាចាំទេ?

**ឆ៖** ឆ្នាំមមី។

**ស៖** លោកស្រីឆ្នាំនេះអាយុប៉ុន្មានហើយឥឡូវហ្នឹង?

**ឆ៖** ៧៤។

**ស៖** អរគុណ។ ហើយលោកស្រី ស៊ិន ផែម លោកស្រីកើតនៅទីកន្លែងណា ស្រុកកំណើតរបស់លោកស្រី?

[០៩:១៩:០៤]

**ឆ៖** នៅស្វាយយា។

**ស៖** នៅស្វាយយានុ៎ង ភូមិស្វាយយា ឃុំអី ស្រុកអី ខេត្តអីដែរ ស្វាយយា?

**ធ៖** ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។

**ស៖** បាទ អរគុណ។ ហើយចុះទីកន្លែងលំនៅដ្ឋានរបស់លោកស្រីសព្វថ្ងៃនៅទីកន្លែងណា? ផ្ទះៗរបស់លោកស្រីដែលរស់នៅសព្វថ្ងៃនៅកន្លែងណា?

**ធ៖** នៅស្វាយយាតែម្តង ភូមិស្វាយយា។

**ស៖** បាទ អរគុណ។ ហើយលោកស្រីសព្វថ្ងៃហ្នឹងធ្វើដែរ សព្វថ្ងៃនេះ?

**ស៖** បាទ អរគុណ។ ហើយលោកស្រីសព្វថ្ងៃហ្នឹង ធ្វើអីដែរ សព្វថ្ងៃនេះ?

**ធ៖** របរខ្ញុំរកស៊ីធ្វើស្រែ ប៉ុន្តែឥឡូវខ្ញុំឈឺ ខ្ញុំធ្វើមិនកើត។

**ស៖** បាទ អរគុណ។ ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ធ៖** កែវ – ឪឈ្មោះ កែវ, ម៉ែឈ្មោះ ផែ។ ស្លាប់ចោលអស់ហើយ គ្មាននៅទេ។

**ស៖** ចុះប្តីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់? កុំអាលឆ្លើយ! អំមិញឆ្លើយទៅ សំឡេងរបស់លោកស្រី អត់ឮដល់អ្នកដទៃទេ នៅក្នុងរឿង នៅក្នុងសាលសវនាការនេះណា ជាពិសេសអ្នកបកប្រែភាសា។ ប្តីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

[០៩:២០:៥៤]

**ធ៖** កូនពីរ។

**ស៖** ចុះប្តីរបស់លោកស្រីឈ្មោះអី?

**ធ៖** ទៀង ផាន់។

**ស៖** បាទ អរគុណ។ ហើយលោកស្រី ស៊ិន ឆែម តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា តាមសមត្ថភាពដែលលោកស្រីអាចដឹង គឺលោកស្រីមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន និងបុគ្គលទាំងឡាយដែលបានទទួលយកជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ។ តើរបាយការណ៍នេះ ពិតជាត្រឹមត្រូវដែរឬទេ?

**ធ៖** ខ្ញុំមិនចេះ -- ត្រឹមត្រូវ ពីព្រោះខ្ញុំនិយាយតាមការពិត គេប្រាប់ខ្ញុំដែរ។

**ស៖** តើលោកស្រីបានធ្វើសម្បថរួចហើយនៅ មុននឹងចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅមុខតុលាការនេះ នៅព្រឹកមិញនេះ នៅអ្នកតាដំបងដែក នៅពីខាងកើតសាលសវនាការនេះ?

**ធ៖** ស្បថហើយ ស្បថហើយៗ។

**ស៖** តទៅនេះ អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកស្រីចូលរួមក្នុងសវនាការ ក្នុងឋានៈជាសាក្សី។ អំពីសិទ្ធិដែលលោកស្រី ស៊ិន ឆែម ក្នុងឋានៈលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកស្រីធ្វើអត្ថាធិប្បាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច លោកស្រី ស៊ិន ឆែម ក្នុងឋានៈលោកស្រីជាសាក្សីដែលត្រូវឆ្លើយតបទៅនឹងសំណួរៗទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី លើកលែងតែសំណួរដែលនាំឲ្យដាក់ចម្លើយតបរបស់លោកស្រីនុ៎ង ដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយក្នុងឋានៈលោកស្រីជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏ធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។

លោកស្រី ស៊ិន ឆែម តើលោកស្រីធ្លាប់ដែលផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើធ្វើធ្វើប៉ុន្មានដង?

[០៩:២៤:០៣]

**ឆ៖** ពីរដង។

**ស៖** ធ្វើនៅពេលណា ហើយនៅកន្លែងណាដែរ ពីរដងនុ៎ង លោកស្រីចាំទេ?

**ឆ៖** ចាំ ធ្វើនៅផ្ទះខ្ញុំតែម្តង។

**ស៖** ពីឆ្នាំណាដែរ លោកស្រីចាំទេ?

**ឆ៖** អត់ចាំទេ គ្មានចាំ គ្មានអីទេ។

**ស៖** លោកស្រី ស៊ិន ឆែម ចេះអក្សរដែរឬទេ? អាចអានបានដែរទេ អក្សរខ្មែរ?

**ឆ៖** អត់ ខ្ញុំអត់ដែលរៀនផង។

**ស៖** ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកស្រីបានពិនិត្យមើលស្តាប់ការអានពីបុគ្គលណាមួយនូវកំណត់ហេតុ ដែលលោកស្រីបានផ្តល់ចម្លើយកាលពីពេលមុននៅនឹងផ្ទះរបស់លោកស្រីចំនួនពីរដង ដើម្បីរំឭកការចងចាំរបស់លោកស្រីដែរទេ? មានអ្នកណាអានកំណត់

ហេតុហ្នឹងឲ្យស្តាប់ដែរទេ?

**ឆ៖** អានៗ ឲ្យស្តាប់ហើយ។

**ស៖** ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំបាន ថាតើលោកស្រីអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកស្រីបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកស្រីបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននៅនឹងផ្ទះរបស់លោកស្រីនោះ ដែរឬទេ?

**ឆ៖** នៅផ្ទះខ្ញុំ ខ្ញុំពិតប្រាកដមែនបានខ្ញុំហ៊ានថា បើមិនមែនពិតប្រាកដខ្ញុំមិនហ៊ានថាទេ។

**ស៖** អង្គជំនុំជម្រះចង់សួរថា ក្រោយពីស្តាប់ការអានឲ្យស្តាប់នូវកំណត់ហេតុដែលមានអ្នកអានឲ្យលោកស្រីស្តាប់ហ្នឹង ខ្លឹមសារនៃកំណត់ហេតុដែលអានឲ្យស្តាប់ហ្នឹងវាសមស្របទៅនឹងចម្លើយដែលលោកស្រីបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត កាលពីបានធ្វើនៅនឹងផ្ទះរបស់លោកស្រីកាលពីពេលមុននោះដែរឬទេ?

**ឆ៖** គេអានឲ្យខ្ញុំស្តាប់ ពិតមែន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី ស៊ិន ឆែម។ ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:២៧:១៨]

**លោក ឌេល លីសាក់៖**

សូមអរគុណ។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រី លោកស្រីបានឆ្លើយថា លោកស្រីរស់នៅពេញមួយជីវិត នៅក្នុងភូមិ-ឃុំស្វាយយា។ តើលោកស្រីអាចជម្រាបបានទេថា ខ្មែរ

ក្រហមបានចូលមកត្រួតត្រាភូមិស្វាយយាហ្នឹងចាប់ពីពេលណាមកដែរ?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** ខ្ញុំវាមិនដឹងឆ្នាំណា វាភ្លេចអស់ដែរហ្នឹង ខែមើល! បើឆ្នាំ វាមិនដឹងជាឆ្នាំប៉ុន្មានទេ ប៉ុន្តែខ្ញុំដឹងថា ខ្មែរក្រហមសម្លាប់អស់ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។ ប្ដីខ្ញុំធ្វើការខាងគណៈឃុំ ហើយដល់ពេលអ៊ីចឹងពួកអ្នកធ្វើជាមួយគ្នាហ្នឹង គាត់និយាយប្រាប់ខ្ញុំ គេខ្សឹបប្រាប់ ថាសម្លាប់អស់ហើយ អ្នកធំៗគ្មាននៅសល់ទេ។ ហើយដល់ពេលមកក្រោយ--

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន! លោកស្រីចាំស្ដាប់សំណួរឱ្យបាន គេមិនសួរអ៊ីចឹងទេណា។ ខ្លឹមសារសំណួរសួរមិនមានទាន់ដល់ដំណាក់កាលហ្នឹងទេ។ បន្តិចទៀត លោកស្រីនឹង -- សំណួរនឹងសួរដល់បញ្ហា ដែលលោកស្រីឆ្លើយអម្បាញ់មិញហ្នឹងហើយ ប៉ុន្តែសំណួរបឋមដំបូងៗហ្នឹង គឺមិនទាន់ដល់ហ្នឹងទេ។ ចាំស្ដាប់សំណួរឱ្យបាន សឹមឆ្លើយតបឱ្យចំសំណួរ ដើម្បីរហ័សនឹងអាលបានចប់តាមផែនការកំណត់គឺសវនាការស្ដាប់សក្ខីកម្មរបស់លោកស្រីពេញមួយថ្ងៃនេះ។ កាលណាធ្វើឱ្យមានបញ្ហាទៅ អាចអូសដល់ស្អែកទៀត រំខានដល់ការងាររបស់លោកស្រី។ ចាំស្ដាប់សំណួរឱ្យបាន ហើយឆ្លើយតបខ្លីៗទៅនឹងសំណួរបានហើយ កុំអត្ថាធិប្បាយវែង។

តំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ តាំងសំណួរសាជាថ្មីម្ដងទៀត។ គាត់ស្ដាប់មិនយល់ទេ បានគាត់ឆ្លើយផ្សេង មិនតបនឹងសំណួរដែលលោកចង់សួរ មានបំណងចង់សួរអម្បាញ់មិញនេះទេ។

[០៩:២៩:៣៥]

**សួរដោយលោក ខេល លីសាក់៖**

បាទ អរគុណលោកប្រធាន។

**ស៖** ខ្ញុំដឹងហើយថា លោកស្រីមិនអាចចងចាំថា ខ្មែរក្រហមចូលមកត្រួតត្រាក្នុងភូមិឃុំលោកស្រីនៅពេលណានោះទេ។ ប៉ុន្តែលោកស្រីគិតមើល តើគិតពីពេលដែលថ្ងៃរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្ដម សីហនុ ហ្នឹងថាតើខ្មែរក្រហមមកកាន់កាប់ហ្នឹង គិតពីពេលហ្នឹងវាគម្លាតខុសគ្នាប៉ុនណាដែរ ឬក៏ប្រៀបធៀបទៅថ្ងៃ ១៧ មេសា ១៩៧៥?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** ចាស ខ្ញុំដឹងតែប៉ុណ្ណឹងដែរ។ ដឹង៧៥ សង្គ្រាមក្នុង៧៥។

**ស៖** នៅក្នុងរបបខ្មែរក្រហម តើឃុំដែលលោកស្រីរស់នៅនោះ ឃុំស្វាយជ្រំ ឬក៏ឃុំមានជ័យថ្មី?

**ឆ៖** ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឃុំស្វាយយា។

**ស៖** លោកស្រីដឹងថា ស្រុកស្វាយជ្រំហ្នឹងស្ថិតនៅក្នុងតំបន់អ្វីដែរ ស្ថិតនៅក្នុងភូមិភាគអ្វីដែរក្នុងរបបខ្មែរក្រហម?

**ឆ៖** អត់ដឹងភូមិភាគអី ខ្ញុំមិនដឹងដែរ ខេត្ត គ្រាន់តែដឹងខេត្តស្វាយរៀង។ វាមិនមែនខេត្តព្រៃវែងទេ។

**ស៖** លោកស្រីដឹងថា លោកស្រីរស់នៅក្នុងតំបន់លេខប៉ុន្មានដែរ កាលណោះ?

**ឆ៖** បើសួរតំបន់ទៀត អ៎! ដឹងលេខទៀត ខ្ញុំមិនដឹងទេ អត់ដឹងអីផង។

**ស៖** ចុះបើខ្ញុំនិយាយថា តំបន់២៣ តើលោកស្រីធ្លាប់បានឮដែរទេ តំបន់២៣?

**ឆ៖** អត់ចាំ ហើយៗខ្ញុំភ្លេច ខ្ញុំវាភ្លេចដែរ។

[០៩:៣២:៣១]

**ស៖** សូមលោកស្រីរៀបរាប់អំពីចំនួនមនុស្សរស់នៅក្នុងភូមិស្វាយយា។ តើនៅមុនឆ្នាំ១៩៧៥ មានប្រជាជនប៉ុន្មានគ្រួសាររស់នៅក្នុងភូមិស្វាយយា?

**ឆ៖** មានប្រជាជន១០០គ្រួសារ។

**ស៖** ក្នុងចំណោមប្រជាជន១០០គ្រួសារនេះ តើលោកស្រីដឹងថា មានប៉ុន្មានគ្រួសារជាជនជាតិវៀតណាម?

**ឆ៖** ប្រហែលជា វាជិតផ្សារដែរវាច្រើនដែរ។ ប្រហែលជា តែដឹងគេនេះនោះ មើល! បីគ្រួសារ បួនគ្រួសារ ប៉ុណ្ណឹង។

**ស៖** តើគេឲ្យលោកស្រីធ្វើអ្វីដែរនៅក្នុងរបបខ្មែរក្រហម?

**ឆ៖** ខ្ញុំគ្មានធ្វើអីទេ ខ្ញុំដើរតែស្ទូង។ គេឲ្យទៅណេះទៅណេះទៅ ឲ្យទៅណោះទៅណោះទៅ។ មិនធ្វើការងារអីនឹងគេទេ។

**ស៖** តើលោកស្រីមានធ្លាប់បានទៅ គេឲ្យទៅជីកប្រឡាយ លើកទំនប់ណាមួយទេ? ហើយបើសិនណាជាធ្លាប់ តើលោកស្រីចាំឈ្មោះទំនប់ដែលលោកស្រីបានលើកនោះទេ?

**ឆ៖** ចាំ ព្រះទន្លេ ហើយនិងឃុំឃ្នត់ នៅខាងកើតវត្តស្វាយជ្រំ។

**ស៖** ខ្ញុំសូមសួរលោកស្រីអំពីសមាជិកគ្រួសាររបស់លោកស្រី ដែលធ្វើការនៅក្នុងរបបខ្មែរ

ក្រហម។ ចាប់ផ្តើមទី១ គឺឈ្មោះ ស៊ិន ឈ្លួន បងប្រុសរបស់លោកស្រី។ តើបងប្រុសរបស់លោកស្រី ស៊ិន ឈ្លួន នេះ ចូលបដិវត្តន៍ពីពេលណាមកដែរ? ហើយគាត់មានមុខងារជាអ្វីដែរ?

**ឆ៖** គាត់នៅខាង មិនដឹងស្អីគេទេ ខ្ញុំមិនដឹងដែរ។ គេធ្វើនៅអី ក្រសាំងចារឯណោះ ប៉ុន្តែអើគេធ្វើការ ប៉ុន្តែមានធ្វើការ។ ខ្ញុំដឹងថាគេធ្វើការ ប៉ុន្តែ អើមានពួកម៉ាកមិត្តភក្តិអីអ៊ីចឹងតិចតួចដែរ។

**ស៖** បងប្រុសរបស់លោកស្រី ឈ្មោះ ស៊ិន ឈ្លួន នៅក្នុងរបបខ្មែរក្រហមហ្នឹង តើគាត់រស់នៅភូមិស្វាយយាដែរ ឬក៏គាត់រស់នៅកន្លែងផ្សេង?

**ឆ៖** នៅកន្លែងផ្សេង នៅក្រសាំងចារ ក្បែរឯត្បូងត្របែក។

**ស៖** ចុះនៅឯក្រសាំងចារហ្នឹង គាត់ទៅធ្វើអ្វីដែរ?

**ឆ៖** កាលពីដើមធ្វើស្រែធ្វើអី ប៉ុន្តែដល់ពេលក្រោយមកបានគេចូលក្នុងនេះហ្នឹងទៅ ដល់នេះគេលែងធ្វើទៅ។

[០៩:៣៦:៥០]

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី ដែលបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គេបានបង្ហាញប្រវត្តិរូបរបស់បងប្រុសលោកស្រី ហើយខ្ញុំសូមអានសម្រង់ចេញពីប្រវត្តិរូបដែលគេបង្ហាញលោកស្រីនេះ នេះគឺឯកសារ E3/7526។ នេះគឺជាប្រវត្តិរូបរបស់បងស្រីលោកស្រី ឈ្មោះ ស៊ិន ឈ្លួន ឈ្មោះបដិវត្តន៍ហៅ ជឿន កើតនៅថ្ងៃទី២៨ តុលា ១៩៤០ នៅភូមិស្វាយយា នៅឃុំស្វាយយា។ ហើយប្រវត្តិរូបនេះក៏វាពាក់ព័ន្ធទៅនឹងបងប្អូនប្រុសមួយទៀត ដែលមាន ERN ជាភាសាខ្មែរ 00079576, អង់គ្លេស 00324095, បារាំង 00728266។ នៅក្នុងប្រវត្តិរូបរបស់បងប្រុសលោកស្រីនេះ គាត់ថា ក្នុងគ្រួសារលោកស្រីហ្នឹង គឺមានបងប្អូនបួននាក់ (ស្រីបីនាក់ ប្រុសម្នាក់)។ ហើយនៅក្នុងកថាខណ្ឌមួយគឺ នេះគឺហើយនិយាយអំពីរបររកស៊ី និងវណ្ណៈរបស់ម្នាក់ៗ។ សូមដកស្រង់៖ "ប្អូនស្រីខ្ញុំធ្វើស្រែ ហើយប្តីធ្វើបដិវត្តន៍។ ហើយប្អូនប្រុសទី៣ កសិករក្រីក្រ។ ប្អូនប្រុសទី៤ ធ្វើបដិវត្តន៍ ធ្វើពេទ្យនៅសេនាធិការយោធា។" បញ្ចប់ការដកស្រង់។ លោកស្រីសាក្សីលោកស្រីមានប្អូនប្រុសម្នាក់ធ្វើពេទ្យបដិវត្តន៍ហ្នឹងដែរទេ? ហើយបើអ៊ីចឹងមែន តើគាត់ឈ្មោះអីដែរ?

**ឆ៖** ស៊ិន ឈ្យុក។

**ស៖** តើ ស៊ិន ឈ្យុក នេះធ្វើ ពេទ្យបដិវត្តន៍ហ្នឹងនៅឯណាដែរ?

**ឆ៖** ធ្វើនៅនេះ ដល់នេះមកនៅវត្តនិរោធ។

**ស៖** តើមន្ទីរពេទ្យដែលគាត់ធ្វើនេះ នៅវត្តនិរោធនេះ ស្ថិតនៅក្នុងតំបន់២៤មែនទេ?

**ឆ៖** ចាស តំបន់២៤។

**ស៖** ត្រឡប់ទៅនិយាយអំពីប្រវត្តិរូបរបស់បងប្រុសលោកស្រីឡើងវិញ។ នៅក្នុងកថាខណ្ឌ១០ នៃផ្នែកទី១ នៃប្រវត្តិរូបរបស់គាត់ បងប្រុសរបស់លោកស្រីបានសរសេរដូចតទៅ អំពីការដែលគាត់ចូលជាមួយនឹងចលនាបក្សកុម្មុយនីស្តកម្ពុជា។ សូមដកស្រង់៖ “ខ្ញុំចូលបក្សនៅថ្ងៃទី២៦ តុលា ១៩៧០ នៅភូមិចាន់រ៉ា ស្រុកបាភ្នំ តំបន់២៤។ សមមិត្តដែលឧទ្ទេសនាមឲ្យខ្ញុំចូលបដិវត្តន៍នោះឈ្មោះ សមមិត្តចក្រី” បញ្ចប់ការដកស្រង់។ លោកស្រីដឹងថា សមមិត្តចក្រី នេះជាអ្នកណាទេ?

**ឆ៖** ខ្ញុំមិនដឹងជាអ្នកណា មិនដែលឃើញទេ ប៉ុន្តែបងខ្ញុំនិយាយប្រាប់ខ្ញុំ។

**ស៖** តើ ចាន់ ចក្រី នេះជាមេបញ្ជាការកងទ័ពម្នាក់នៅក្នុងភូមិភាគបូព៌ានោះ មែនទេ?

**ឆ៖** ហ្នឹងហើយ កងទ័ពខាងបូព៌ា។

[០៩:៤១:៤៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រមទាំងអស់គ្នា។ ខ្ញុំមានសំណួរតូចមួយសូមការបញ្ជាក់បំភ្លឺ។ ខ្ញុំឮសួរសហព្រះរាជអាជ្ញា គាត់បានសួរពីខាងដើមមក ថាតើស្រុករបស់លោកស្រីដែលរស់នៅអង្កាល់នោះ នៅក្នុងតំបន់២៣ ឬក៏អត់ទេ? តាមខ្ញុំដឹង គឺភូមិរបស់គាត់ចំណុះឲ្យតំនប់២៤។ យើងខ្ញុំក៏មិនទាន់ច្បាស់ពេញលេញដែរ ប៉ុន្តែពេលអានឯកសារ E3/7526 នៅក្នុងអត្ថបទជាភាសាអង់គ្លេស និយាយថា ភូមិ ឃុំ ស្រុកនៅក្នុងស្រុកបាភ្នំ គឺចំណុះឲ្យតំបន់២៤។ ដូច្នេះមើលទៅហាក់បីដូចជាមានភាពច្របូកច្របល់បន្តិច។ ដូច្នេះ ខ្ញុំសុំឲ្យតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ឡើងវិញ ថាតើភូមិ ឃុំ ស្រុកនេះវាចំណុះឲ្យតំបន់២៣ ឬតំបន់២៤?

**លោក ឌេល លីសាក់៖**

ខ្ញុំរីករាយនឹងបញ្ជាក់ជូន។ ជាការពិតណាស់ ស្រុកដែលលោកស្រីរស់នៅនោះគឺកាលនោះចំណុះឲ្យតំបន់២៣។ ដូច្នេះបើលោកមេធាវីការពារក្តីមើលទៅបញ្ជីអ្នកទោស ស-២១ ឯកសារ E3/2010 ពេលនោះលោកនឹងរកឃើញផ្នែកមួយស្តីអំពីតំបន់២៣ហើយ។ ហើយក៏បញ្ជាក់ផងដែរ ថា

ស្រុករបស់សាក្សីរូបនេះ ពិតជាចំណុះឲ្យតំបន់២៣ហើយ។ តែសំណួរខ្ញុំនេះ ខ្ញុំសួរពាក់ព័ន្ធទៅនឹងបងប្រុសរបស់គាត់ដែលធ្លាប់ធ្វើការចំណុះឲ្យតំបន់២៤។ លោកប្រធាន ខ្ញុំសូមបន្តទៅមុខទៀត។

[០៩:៤៤:០៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សី លោកស្រីដឹងទេ បងប្រុសរបស់លោកស្រីដែលត្រូវបាន ចាន់ ចក្រី ឧទ្ទេសនាមឲ្យចូលបដិវត្តន៍ហ្នឹង លោកស្រីដឹងថា បងប្រុសរបស់លោកស្រីហ្នឹងស្គាល់ ចាន់ ចក្រី ដោយរបៀបណាដែរទេ?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** ពួកម៉ាក មិត្តភក្តិ។ រកស៊ីដូចគ្នា។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី លោកស្រីក៏បាននិយាយអំពីមេដឹកនាំខ្មែរក្រហមដែលបងប្រុសរបស់លោកស្រីបានស្គាល់ ក្នុងនោះមានម្នាក់ឈ្មោះ តាឈូក, កែវ មាស និងម្នាក់ទៀតឈ្មោះ តាធុច។ តើ តាឈូក, កែវ មាស, និង តាធុច នេះទាំងបីនាក់នេះ ម៉េចបានជាប្រុសរបស់លោកស្រីស្គាល់អ្នកទាំងបីនាក់នេះ?

**ឆ៖** សុទ្ធតែបងប្អូនខ្ញុំ នៅផ្ទះក្បែខ្ញុំ ចឹបើមិនស្គាល់។

**ស៖** លោកស្រីថាជាបងប្អូនសាច់ញាតិរបស់លោកស្រី។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រី លោកស្រីបាននិយាយថា កែវ មាស ជាសាច់ញាតិ ហើយពីរនាក់ទៀតនោះគឺថារស់នៅក្នុងភូមិស្រុកក្បែរគ្រួសាររបស់លោកស្រី។ ត្រឹមត្រូវដែរឬទេ? ឥឡូវនេះដំបូងថាសូមសួរថាតើសាច់ញាតិជាមួយនឹង កែវ មាស ហ្នឹងជាសាច់ញាតិបែបម៉េចដែរ?

[០៩:៤៦:០៩]

**ឆ៖** បងប្អូនមីងខ្ញុំ កូនយាយជីដូនមួយ ផ្ទះក្បែរគ្នា។ នៅបងគាត់ នៅសព្វថ្ងៃហ្នឹង អាយុ៩០ជាងហើយ មិនទាន់ស្លាប់ផង។

**ស៖** តើ កែវ មាស នេះជាជីដូនមួយ ឬក៏ជាជីទួតមួយរបស់លោកស្រី?

**ឆ៖** វាជីដូនមួយ។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានទេ អំពី តាឈូក ហើយនិង កែវ មាស ធ្វើម៉េចបានជាលោកស្រីស្គាល់អ្នកទាំងពីរនេះ?

**ធ៖** វាបានជាខ្ញុំស្គាល់ ពីព្រោះ តាឈូក ហ្នឹងបង្រៀនបងខ្ញុំ។ ធ្វើគ្រូបង្រៀនបងខ្ញុំ។

**ស៖** តើ តាឈូក នេះជាមនុស្សរបៀបណាដែរ លោកស្រី ជាមនុស្សល្អ ឬក៏យ៉ាងណា? សូមលោកស្រីរៀបរាប់អំពីអត្តចរិតនេះរបស់ តាឈូក នេះលម្អិតបន្តិចមើល?

**ធ៖** មនុស្សគេត្រឹមត្រូវល្អល្អាច់ណាស់ មិនពន្លិចពន្លូចទេ គេល្អណាស់។

**ស៖** នៅក្នុងរបបខ្មែរក្រហម តាឈូក មានតួនាទីជាអ្វីដែរ តាឈូក ធ្វើអ្វីដែរ?

**ធ៖** ខ្ញុំអត់បានដឹងទេ អារឿងធ្វើអីៗ ប៉ុន្តែគ្រាន់តែដឹងគេសម្លាប់ ប៉ុណ្ណឹង។

**ស៖** តើលោកស្រីអាចចាំបានថា គាត់ជាប្រធានតំបន់២៤ ឬក៏យ៉ាងណា?

**ធ៖** ខ្ញុំវាភ្លេច។ ដល់ភ្លេចអ៊ីចឹង ខ្ញុំមិនដឹងថាម៉េច ហើយខ្ញុំចេះតែនេះទៅ។

[០៩:៤៨:៥៦]

**ស៖** ចុះជីដូនមួយរបស់លោកស្រី កែវ មាស នេះនៅក្នុងរបបខ្មែរក្រហមនេះ គាត់ធ្វើអីដែរ?

**ធ៖** គាត់ ខ្ញុំអត់បានដឹងធ្វើអីទេ គាត់នៅតែភ្នំពេញ។ ហើយម្យ៉ាងទៅ គាត់ធ្វើគ្រូបង្រៀនដែរជាមួយគ្នា តាឈូក ហ្នឹង។ បងខ្ញុំរៀនទៅ ដល់ពេលយកបងខ្ញុំមកបង្រៀន។ ខ្ញុំអត់បានដឹងធ្វើអីៗទេ។

**ស៖** សូមអរគុណលោកស្រី។ បន្តនិយាយអំពីប្រវត្តិរូបរបស់បងប្រុសលោកស្រី ត្រង់កថាខណ្ឌ ១១ ផ្នែកទី១។ គាត់បានសរសេររៀបរាប់ដូចតទៅ អំពីតួនាទីដែលគាត់មានក្រោយពេលគាត់ចូលជាមួយបដិវត្តន៍ ក្រោយឆ្នាំ១៩៧០។ សូមដកស្រង់៖ “ក្រោយរដ្ឋប្រហារ ដំបូងខ្ញុំទទួលភារៈជាប្រធានភូមិ បន្ទាប់មកជាគណៈឃុំ ក្រោយមកទៀតមកក្នុងកងទ័ពជាមួយកងអនុសេនាធំ។ បន្ទាប់មកទៀតទទួលភារៈជាគណៈវរសេនាតូច ហើយបន្ទាប់មកទទួលការងារជាគណៈវរសេនាធំ ដល់សព្វថ្ងៃ។” បញ្ចប់ការដកស្រង់។ លោកស្រីចាំបានទេ នៅពេលដែលបងលោកស្រីចូលរួមជាមួយកងទ័ពបដិវត្តន៍នោះ លោកស្រីដឹងថា គាត់ធ្លាប់បានចូលរួមប្រយុទ្ធជាមួយនឹងទាហានលន់ នល់ ទេ? ហើយតើគាត់ធ្លាប់បានចូលរួមបាញ់គ្នាជាមួយខាងទាហាន លន់ នល់ ទេ? ហើយបើធ្លាប់ចូលរួមបាញ់គ្នាហ្នឹង បាញ់គ្នានៅសមរភូមិណាដែរ?

**ធ៖** ខ្ញុំមិនបានដឹងទេ អារឿងគេបាញ់គ្នាឯណាៗ ប៉ុន្តែដឹងតែថា ដល់ពេលគេចាប់ផ្តើមធ្វើការក្នុងតំបន់២៤ហ្នឹង ដល់ធ្វើការ ការងារហ្នឹងក៏វាមិនដឹងការងារស្អី ខ្ញុំក៏ភ្លេចភ្លាំងដែរ។ ហើយដល់ពេលនេះទៅ គេឮតែស្រាប់ថា គេថាសម្លាប់ចោល។ អ៊ីចឹងខ្ញុំវាឆ្ងល់ដែរហ្នឹងណា បានខ្ញុំឆ្ងល់ណាស់។

**ស៖** *(គ្មានការបកប្រែ)*

[០៩:៥២:០១]

**ប្រធានអង្គជំនុំ៖**

អត់ៗ មានការបកប្រែជាភាសាខ្មែរទេ។ ម្តងទៀតមើល! ដូចអត់មានបកប្រែជាភាសាខ្មែរទេ សំណួរចុងក្រោយរបស់លោកអម្បាញ់មិញ។ លោកអាចតាំងសំណួរសាជាថ្មីម្តងទៀត សំណួរចុងក្រោយអម្បាញ់មិញ អត់មានការបកប្រែជាភាសាខ្មែរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទ តើបងប្រុសរបស់លោកស្រី ស៊ិន ឈួន នេះពីឆ្នាំ៧៥ ដល់៧៦ លោកស្រីបានជួបបងប្រុសលោកស្រីឈ្មោះ ស៊ិន ឈួន នេះប៉ុន្មានដងដែរ?

**លោកស្រី ស៊ិន ផែម៖**

**ឆ៖** បានពីរដង មកការប្អូនម្តង ហើយខ្ញុំទៅលេងម្តង បានតែប៉ុណ្ណឹង។

**ស៖** តើលោកស្រីទៅលេងបងប្រុសរបស់លោកស្រីហ្នឹងនៅពេលណាដែរ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ ខ្ញុំទៅលេងពេលណាៗ ខ្ញុំអត់ទេ។ តែគាត់ដឹងតែទៅបានម្តង ហើយពេលមកការប្អូនម្តង តែប៉ុណ្ណឹង។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា E3/7526 ERN ជាភាសាបារាំង 00746948, ខ្មែរ 00185369 ដល់ 71 មិនមានការបកប្រែជាភាសាអង់គ្លេសទេត្រង់ផ្នែកនេះ។ នៅក្នុងកិច្ចសម្ភាសន៍លោកស្រីបញ្ជាក់ថា៖ "ក្រោយឆ្នាំ១៩៧៥ បងប្រុសរបស់ខ្ញុំគឺជាប្រធានទ័ពតំបន់មានមូលដ្ឋាននៅជិតបាភ្នំ។" តើត្រឹមត្រូវមែនទេ ដែលលោកស្រីថាបងប្រុសរបស់លោកស្រីនេះគឺមានតួនាទីជាមេបញ្ជាការទ័ពតំបន់២៤ នៅជិតបាភ្នំ?

[០៩:៥៤:៥៣]

**ឆ៖** វាមែន ប៉ុនខ្ញុំវាភ្លេច ដល់អ៊ីចឹងខ្ញុំមិនដឹងថាម៉េចទេ។

**ស៖** ឥឡូវនេះយើងនិយាយអំពីប្តីរបស់លោកស្រីឈ្មោះ ទៀង ផាន់ តើលោកស្រីរៀបការជាមួយប្តីរបស់លោកស្រី ទៀង ផាន់ ហ្នឹងនៅពេលណា ឆ្នាំណា?

**ឆ៖** ខ្ញុំឆ្នាំរោង ដឹងគេប៉ុន្មានៗហើយទេនេះ ខ្ញុំវាភ្លេចអស់ហើយ។ ហើយប៉ុន្តែខ្ញុំមិនដឹងថាឆ្នាំណាខែណាទេ ខ្ញុំភ្លេចហើយ ដឹងតែការឆ្នាំរោង ពីឆ្នាំរោង វាឥឡូវវាអាយុ៦០ជាងហើយ អ៎! ៧០ជាងហើយ ៧៧ហើយ។

**ស៖** ខ្ញុំសួរបែបនេះ តើលោកស្រី ហើយនិងប្ដីលោកស្រីរៀបការតាមប្រពៃណីខ្មែរ ឬក៏រៀបការតាមរបៀបបដិវត្តន៍ដែលអង្គការគេរៀបឲ្យ?

**ឆ៖** ទេ ខ្ញុំរៀបការតាមប្រពៃណីខ្មែរតើ! ខ្ញុំការអីណា បដិវត្តន៍អីណារៀបការខ្ញុំទេ។

**ស៖** ប្ដីរបស់លោកស្រី តើគាត់មានមុខងារអ្វីទេនៅក្នុងរបបខ្មែរក្រហម នៅក្នុងឃុំស្វាយយា?

**ឆ៖** គណៈឃុំ។

**ស៖** តើលោកស្រីចាំទេ គេចាត់តាំងឲ្យគាត់ធ្វើជាគណៈឃុំស្វាយយាហ្នឹងនៅក្នុងឆ្នាំណា?

**ឆ៖** ពីឆ្នាំ៧៦។

[០៩:៥៧:២៧]

**ស៖** តើអ្នកណាជាអ្នកតែងតាំងប្ដីលោកស្រីឲ្យធ្វើជាមេឃុំស្វាយយានោះ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ មិនដឹងពីណាទេ។ មិនដឹងពីណាទេ អ្នកបង្គាប់ទេ ហើយខ្ញុំភ័យ។ ខ្ញុំថាកុំខំពេក ខំប្រយ័ត្នងាប់ចោលកូន ថាអ៊ីចឹងណ៎ា អីយ៉ា! វាមិនអីទេ។

**ស៖** តើលោកស្រីចាំដែរឬទេ គណៈស្រុកដែលប្ដីលោកស្រីត្រូវរាយការណ៍ឲ្យទៅហ្នឹង តើគណៈស្រុកនុ៎ងឈ្មោះអ្វី?

**ឆ៖** គណៈស្រុកស្វាយរៀង គណៈស្រុកនោះ ខ្ញុំមិន -- អ៎! តា ខ្ញុំភ្លេចឈ្មោះគាត់ហើយ។ ភ្លេចអស់ហើយ ភ្លេចឈ្មោះគាត់ នៅ ស្គាល់ដែរ ប៉ុន្តែខ្ញុំភ្លេច ឥឡូវភ្លេចអស់រលីង គ្មានដឹងស្អីទេ។

**ស៖** ខ្ញុំសូមរំឭកការចងចាំលោកស្រី សេចក្ដីដកស្រង់ពីបទសម្ភាសន៍លោកស្រីនៅឲ្យមជ្ឈ-មណ្ឌលឯកសារគឺE3/7526, បារាំង ERN00746966, ខ្មែរ 00185388។ លោកស្រីបាននិយាយថា៖ “ប្រធានស្រុកមានឈ្មោះមានជ័យថ្មីនោះ ឈ្មោះ ខៀវ សាមិត”។ តើលោកស្រីនឹកឃើញទេ ពេលដែលខ្ញុំអានសម្រង់នេះជូនលោកស្រីស្ដាប់ថា ខៀវ សាមិត នោះ?

**ឆ៖** មែន តាសាមិត ខ្ញុំភ្លេច។ ឈ្មោះ តាសាមិត។

**ស៖** យើងនិយាយអំពីប្ដីរបស់លោកស្រីនៅ ដែលជាគណៈឃុំស្វាយយា ហើយនិងបងប្រុសជាយោធានៅតំបន់ ហើយប្អូនស្រីរបស់លោកស្រីជាពេទ្យនៅមន្ទីរពេទ្យមួយ។ ហើយខ្ញុំចង់ដឹងថាតើប្ដីរបស់លោកស្រី បងរបស់លោកស្រី ហើយនិងប្អូនប្រុសរបស់លោកស្រីនោះ មានបញ្ហាអ្វីទេ នៅក្នុងរបបខ្មែរក្រហម?

[១០:០០:២៥]

**ផ៖** អត់មានទេ។ មានស្អីទេ ទទេ។

**ស៖** ខ្ញុំសួរអំពីប្ដីរបស់លោកស្រី ហើយនិងបងប្រុស ហើយនិងប្អូនប្រុសរបស់លោកស្រី គឺ ស៊ិន ឈួន ហើយនិងប្អូនប្រុសមួយទៀត ថាតើពួកគាត់មានបញ្ហាអ្វីទេនៅក្នុងរបបខ្មែរក្រហម? តើគាត់បានរួចរស់ជីវិតដែរឬទេ?

**ផ៖** អត់មានទេ ស្លាប់អស់ហើយ។

**ស៖** តើពួកគាត់ស្លាប់ដោយរបៀបណា?

**ផ៖** ស្លាប់គេយកទៅវាយចោលតែម្ដង។ មិនដឹងទៅស្លាប់ឯណាផង ខ្ញុំមិនដឹងដែរ។

**ស៖** តើលោកស្រីចាំទេ នៅក្នុងឆ្នាំណាដែលថា គេយកប្ដីរបស់លោកស្រី ហើយនិងបងប្រុស ហើយនិងប្អូនប្រុសយកទៅសម្លាប់នោះ តើនៅក្នុងឆ្នាំណា ចាំទេ?

**ផ៖** បងប្រុសហ្នឹងប្រហែលជាឆ្នាំ៧៧ អ៎!ប្ដីខ្ញុំក៏ក្នុងឆ្នាំ៧៧ដែរ តែគេយកមុន។ គេយកមុនហ្នឹង គេយកមកនៅភ្នំឈើកាច់។

**ស៖** តើបងប្រុសលោកស្រី គឺជាមនុស្សដែលគេយកទៅមុនគេ អ៊ីចឹងឬទេ?

**ផ៖** ចាស។

**ស៖** តើក្រោយពីគេយកបងប្រុសលោកស្រីទៅហ្នឹង គឺរយៈពេលប៉ុន្មានបានគេមកយកប្ដីរបស់លោកស្រីទៅ?

**ផ៖** ប្រហែលជាឆ្នាំ៧៧ ដល់ជិតដាច់ ក្រោយៗបងខ្ញុំ។

[១០:០៣:១៩]

**ស៖** បាទ ឥឡូវនេះខ្ញុំនឹងចាប់និយាយអំពីបងប្រុសលោកស្រីឈ្មោះ ស៊ិន ឈួន។ តើលោកស្រីដឹងដោយរបៀបណាថា គេយកបងប្រុសលោកស្រីទៅ គេចាប់គាត់ទៅហ្នឹង?

**ផ៖** គេខ្សឹបប្រាប់ខ្ញុំ គេប្រាប់ខ្ញុំថា ស៊ិន ឈួន គេយកទៅបាត់ហើយ។

**ស៖** តើលោកស្រីចាំទេ អ្នកណាប្រាប់មកលោកស្រីហ្នឹង អ្នកហ្នឹងឈ្មោះអី?

**ផ៖** ពូស៊ឹម។ ពូស៊ឹម នៅគណៈឃុំជាមួយគ្នាដែរ។

**ស៖** តើ ស៊ឹម បាននិយាយពីអ្វីថា ពីមូលហេតុដែលគេចាប់បងប្រុសរបស់លោកស្រីទេ?

**ផ៖** ខ្ញុំសួរថាហេតុអីបានគេសម្លាប់ បានគេយកទៅសម្លាប់? ថាអត់ដឹងៗរឿងទេ គាត់ថាអ៊ីចឹងអត់ដឹងរឿងអីទេ។

**ស៖** យើងនិយាយពីខាងដើមអំពីការណែនាំឲ្យចូលបដិវត្តន៍ថា ចាន់ ចក្រី នាំឲ្យបងប្រុសលោកស្រីចូលបដិវត្តន៍ ហើយ តាឈូក ជាអ្នកបង្រៀនគាត់។ មុនពេលដែលគេចាប់បងប្រុសរបស់ លោកស្រីថាតើលោកស្រីបានដឹងថា ចក្រី, តាឈូក ហើយនិង កែវ មាស នោះមានបញ្ហាអីទេ មានរឿង រ៉ាវអីទេមុនដែលគេចាប់បងប្រុសលោកស្រី?

**ឆ៖** ទេ គ្មានរឿងរ៉ាវស្អីទេ ខ្ញុំមិនមានដឹងថា រឿងរ៉ាវអីទេ ប៉ុន្តែគាត់ហ្នឹងមិនដែលនឹងនៅផ្ទះផងទៅបាត់ៗទៅ។ ហើយដល់ពេលអ៊ីចឹងទៅ ទាល់តែគេសម្លាប់ចោលអស់បានខ្ញុំដឹង។

[១០:០៥:៥៦]

**ស៖** តើលោកស្រីចាំទេថា ប្តីរបស់លោកស្រីបានប្រាប់លោកស្រីអំពីការចាប់ខ្លួន ចក្រី ហើយនិងគេចាប់ តាឈូក? តើលោកស្រីនៅនឹកឃើញទេថា ប្តីលោកស្រីធ្លាប់ប្រាប់លោកស្រីពីរឿងនេះ?

**ឆ៖** មិនមែនប្តីខ្ញុំទេ គេ។ គេធ្វើជាមួយខ្ញុំ ធ្វើជាមួយប្តីខ្ញុំ គេខ្សឹបប្រាប់ខ្ញុំ ក្នុងគណៈឃុំដែរ ប៉ុន្តែក្រោមប្តីខ្ញុំបន្តិច។

**ស៖** ខ្ញុំចង់អានសេចក្តីដកស្រង់ពីចម្លើយ ដែលលោកស្រីបានឆ្លើយទៅនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/7794 ខ្មែរERN 00249916 ដល់17, អង់គ្លេស ERN00251405, បារាំង 00285545។ អានេះជាអ្វីដែលលោកស្រីបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ៖ “ខ្ញុំបានដឹងតាមរយៈប្តីរបស់ខ្ញុំថា ប៉ុល ពត ឬអង្គការបានចាប់ខ្លួន តាចក្រី ជាមេបញ្ជាការកងទ័ពនៅតំបន់២៤ ហើយនិង តាឈូក ជាលេខាតំបន់២៤ ហើយក៏បានសម្លាប់ពួកគាត់។ នៅក្នុងចុងឆ្នាំ១៩៧៦ ខ្ញុំបានឮតាមកម្មាភិបាលមូលដ្ឋានថា ហ៊ូ នឹម ក៏ត្រូវបានអង្គការចាប់ខ្លួនដែរ ហើយក៏បានយកទៅសម្លាប់ចោល។ នៅពេលជាមួយគ្នានោះដែរ បងប្រុសរបស់ខ្ញុំ ស៊ិន ឈួន ដែលជាប់ខ្សែជាមួយ តាឈូក ក៏បានបាត់ខ្លួនប្រហែលជាមួយខែ បន្ទាប់ពី ហ៊ូ នឹម។” ចប់សេចក្តីដកស្រង់ ជាចម្លើយរបស់លោកស្រី។ តើអាចរំឭកការចងចាំរបស់លោកស្រីទេ អំពីប្តីរបស់លោកស្រីប្រាប់លោកស្រីថា គេចាប់ខ្លួន តាចក្រី ហើយនិង តាឈូក?

**ឆ៖** ខ្ញុំ អើ!ខ្ញុំក៏វាភ្លេច ប៉ុន្តែបើកាលនោះវាពិតមែន។ ដល់ពេលអ៊ីចឹងខ្ញុំភ័យ ដល់ភ័យ ចេះតែប្រឹងៗ ហើយប្តីខ្ញុំហាមខ្ញុំថា កុំមាត់កុក នៅឲ្យស្ងៀមទៅ។ តិចយើងស្រីចេះមាត់ចេះក ប្រយ័ត្ន! ខ្លាច។ ខ្ញុំចេះតែលាក់បាំង ភ័យផង អីផង។

[១០:០៩:០៥]

**ស៖** តើលោកស្រីចាំដែរឬទេ ក្រោយពីចាប់ខ្លួន តាឈ្យូក គឺថាក្រោយមកដែលគេចាប់បងប្រុសរបស់លោកស្រី ស៊ិន ឈ្យួន ទៅ ក្រោយពីគេចាប់ តាឈ្យូក រយៈពេលប៉ុនណា?

**ឆ៖** ខ្ញុំភ្លេចភ្លាំងអស់ហើយនេះ មិនដឹងប៉ុនណាៗទេ ប៉ុន្តែគេចាប់បងខ្ញុំហើយ បានគេចាប់ តាឈ្យូក – តាឈ្យូក បងចក្រី។ វាភ្លេចដែរហ្នឹង តែកាលនិយាយនោះមានអីទេ ចាំ ក្នុងអក្សរក្នុងនេះហ្នឹង ប៉ុន្តែដល់ពេលឥឡូវ ខ្ញុំភ្លេចអស់ហើយ មិនដឹងស្អីៗផង។

**ស៖** ខ្ញុំអាចនឹងជួយឱ្យលោកស្រីរំឭកការចងចាំឡើងវិញខ្លះ។ លោកស្រីបានប្រាប់សហចៅក្រមស៊ើបអង្កេតថា មួយខែបន្ទាប់ពីគេចាប់ ហ៊ូ នឹម ក្រោយមកបងប្រុសរបស់លោកស្រីក៏គេយកទៅដែរ គេចាប់ទៅដែរ។ យើងមានកំណត់ត្រាចេញពីស-២១ អំពីពេលវេលាដែលគេចាប់ខ្លួនអ្នកទាំងនេះ ពីឯកសារ E3/342 គឺបញ្ជីកែតម្រូវរបស់ការិយាល័យសហព្រះអាជ្ញាគឺបញ្ជាក់ថា៖ "លេខាតំបន់២៤ ឈ្មោះ សួស នៅ ហៅ ឈូក ត្រូវបានចាប់បញ្ជូនមក ស-២១ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ហើយ កែវ មាស ត្រូវបានចាប់ខ្លួនហើយចូលដល់ស-២១ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦។ ហើយ ហ៊ូ នឹម ត្រូវបានចាប់ខ្លួន ហើយចូលដល់ ស-២១ ប្រហែលជាមួយឆ្នាំកន្លះក្រោយមក ហើយមកដល់ ស-២១ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧"។ ដូចដែលលោកប្រាប់សហចៅក្រមស៊ើបអង្កេតនោះថា បងប្រុសរបស់លោកស្រីត្រូវចាប់ខ្លួនមួយខែក្រោយពី ហ៊ូ នឹម។ នោះមានន័យថា ត្រូវបានគេចាប់ខ្លួនពាក់កណ្ដាលឆ្នាំ ១៩៧៧ ឬក៏លោកស្រីគិតថា នៅដើមឆ្នាំ ឬក៏ចុងឆ្នាំ១៩៧៧?

[១០:១១:៥៨]

**ឆ៖** ដើមឆ្នាំ ប្ដីខ្ញុំបានចុងឆ្នាំ។

**ស៖** បងប្រុសរបស់លោកស្រីនៅក្នុងប្រវត្តិរូបរបស់គាត់ៗ ថាគាត់មានកូនប្រាំ មានកូនប្រុសបីនាក់ កូនស្រីពីរនាក់។ តើប្រពន្ធនិងកូនរបស់គាត់មានរឿងអ្វីដែរនៅពេលដែលគេយកបងប្រុសលោកស្រីទៅនោះ?

**ឆ៖** វាគ្មានរឿងអីទេ អ៊ូ!ប្រពន្ធតែយំមិនហ៊ានយំផង។ ហើយគេនុំងគេនៅក្បែរៗនុំងគេ អើគេជួយនេះដែរ គេជួយអាណិតជួយអីដែរ។

**ឆ៖** នៅក្នុងបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា E3/7526 បារាំង ERN 00746950, ខ្មែរ ERN 00185372។ លោកស្រីបានបញ្ជាក់ថា៖ "ប្រពន្ធរបស់បងប្រុសរបស់លោកស្រី និងកូនៗរបស់គាត់ត្រូវបានគេបញ្ជូនទៅខាងលិចខេត្តពោធិ៍សាត់ក្រោយពីគេចាប់ខ្លួនគាត់"។ តើធ្វើឱ្យលោកស្រី

ចងចាំដែរឬទេ? តើលោកស្រីអាចជម្រាបតុលាការបានទេថា ក្រោយពីគេចាប់បងប្រុសរបស់លោកស្រីទៅ គេបញ្ជូនប្រពន្ធនិងកូនគាត់ទៅខាងលិចខេត្តពោធិ៍សាត់ ហើយពួកគាត់មានបញ្ហាអីទេ ប្រពន្ធនិងកូនគាត់នោះ?

[១០:១៩:០១]

**ផ៖** ខ្ញុំភ្លេច។ បញ្ជូនទៅមែន ហើយដល់ពេលនេះកូនចេះរស់មកវិញទាំងអស់។

**ស៖** តើពួកគាត់រស់នៅដែរឬទេ?

**ផ៖** រស់នៅ នៅសព្វថ្ងៃឥឡូវ តែកូនងាប់អស់ពីរហើយ ឈឺ។

**ស៖** យើងបាននិយាយអំពី កែវ មាស ជាជីទួតមួយ ហើយឯកសារស-២១ គេបានចាប់ខ្លួនគាត់នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦។ តើលោកស្រីដឹងទេប្រពន្ធរបស់គាត់ កូន និងបងប្អូនបង្កើតរបស់គាត់ត្រូវបានគេចាប់ខ្លួនដែរ ឬក៏មានរឿងហេតុអ្វីទេ ទាក់ទងទៅនឹងការចាប់ខ្លួន កែវ មាស នេះ?

**ផ៖** ពូធុចៗ មួយធ្វើគ្រូបង្រៀន ហើយក្មួយ ពូធុច ហ្នឹងស្រី ហើយបងប្អូន ផ្ទះនុំងច្រើនគ្នាណាស់ មិនតិចគ្នាទេ។

**ស៖** សំណួររបស់ខ្ញុំ លោកស្រីសាក្សី ខ្ញុំចង់សួរថា តើសមាជិកក្រុមគ្រួសាររបស់ កែវ មាស ដូចជាប្រពន្ធរបស់គាត់ កូនរបស់គាត់ ឬបងប្អូនបង្កើតរបស់គាត់ត្រូវបានគេចាប់ខ្លួនដែរឬទេ ក្រោយពីគេចាប់ កែវ មាស ទៅ?

**ផ៖** អត់ ប្រពន្ធមិនដឹងនៅឯណាទេ មិនដឹងគាត់យកឯណាផង។ ចាឮដំណឹងថាមានកូន ប៉ុន្តែអាកូន ក៏មិនដែលដឹងដែរ។ គ្រាន់តែដឹងថា គាត់ហើយនិងប្អូនគាត់ហ្នឹង តាធុច ហ្នឹងហើយក្រោយមកប្អូនស្រី -- ក្មួយស្រី កូនបងគាត់ តែប៉ុណ្ណឹង។ នុំងស្រី យកគ្នាទៅសម្លាប់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអាជ្ញារង។ បាទ ឥឡូវនេះដល់សម្រាកហើយ អង្គជំនុំជម្រះប្រកាសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៦ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរចំពោះសាក្សី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើមានអ្នកណាម្នាក់ធ្លាប់ជម្រាបប្រាប់លោកស្រីថា ហេតុអ្វីបានជា កែវ មាស នេះត្រូវបានគេចាប់ខ្លួនទេ?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** គេប្រាប់ខ្ញុំ គេតាមរក រកទាល់តែឃើញ យកទៅសម្លាប់ចោល។

**ស៖** ខ្ញុំសូមអានសម្រង់មួយស្ដីអំពី កែវ មាស ចេញពីសៀវភៅមួយក្បាលដែលអ្នកកាសែតឈ្មោះ ថេត សម្បត្តិ បានសរសេរអំពី នួន ជា។ នេះគឺឯកសារ E3/4202៌ ត្រង់ ERN ជាភាសាខ្មែរ 00858339, អង់គ្លេស 00757531, បារាំង 00849435។ នេះ គឺជាសម្រង់មួយដែលនិយាយអំពីបងប្រុសរបស់លោកស្រី៖ "មេដឹកនាំបក្សម្នាក់ទៀត ឈ្មោះ កែវ មាស ត្រូវស្ថិតនៅក្នុងភាពសង្ស័យ មុននឹងការចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ ដោយសារគាត់ធ្លាប់រស់នៅក្នុងប្រទេសវៀតណាម មុននឹងខ្មែរក្រហមទទួលជ័យជម្នះ។ នួន ជា បាននិយាយថា ថានៅពេលដែល កែវ មាស បានត្រឡប់មកវិញក្នុងឆ្នាំ១៩៧៥ គាត់សង្ស័យថា កែវ មាស នេះមានភាពលម្អៀងទៅខាងវៀតណាម។" បញ្ចប់ការដកស្រង់។

លោកស្រីសាក្សី លោកស្រីស្គាល់ នួន ជា នេះជាអ្នកណាទេ? ហើយលោកស្រីធ្លាប់ដែលឮសួរបងប្រុសរបស់លោកស្រីនិយាយអំពីការចូលរួមពាក់ព័ន្ធខ្លួនរបស់ កែវ មាស នេះដែរទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ រឿងហ្នឹង អត់ដឹងសោះ។ នួន ជា ហ្នឹងខ្ញុំអត់ស្គាល់ទេ។ ខ្ញុំស្គាល់តែតាឈ្យូក, តាធុច, តាកែវ មាស, ចក្រី ប៉ុណ្ណឹងទេ។

[១០:៣៦:៤១]

**ស៖** សូមអរគុណ។ ខ្ញុំសួរអំពីការចាប់ខ្លួនប្ដីរបស់លោកស្រី ទៀង ផាន់។ ធ្វើម៉េចបានលោកស្រីដឹងអំពីការចាប់ខ្លួនប្ដីលោកស្រី? លោកស្រីថា គេចាប់ខ្លួនប្ដីលោកស្រីនៅឆ្នាំ៧៧ តើធ្វើដូចម្ដេចបានជាលោកស្រីដឹងថា ប្ដីលោកស្រីត្រូវបានគេចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៧?

**ឆ៖** ខ្ញុំបានដឹង គេប្រាប់ខ្ញុំ គេរត់មកប្រាប់ខ្ញុំ។ ប្ដីខ្ញុំទៅធ្វើការនៅខាងក្បែរធ្លក ហើយដល់អ៊ីចឹងគេចាប់អ៊ីនុ៎ង។ គេប្រាប់ខ្ញុំដែរ បានខ្ញុំដឹង។

**ស៖** លោកស្រីដឹងទេ អ្នកណាជាអ្នកចាប់ខ្លួនប្ដីលោកស្រីហ្នឹង? ហើយគេចាប់យកទៅទីណាដែរ?

**ឆ៖** គេចាប់យកទៅក្បែរស្វាយរៀង យកទៅទុកជន៎ុងបានបីថ្ងៃ។ អាអោ –ឈ្មោះ អាអោ– អានុ៎ង វាធ្វើសន្តិសុខ។

**ស៖** មនុស្សឈ្មោះ អាអោ នេះជាអ្នកណា?

**ឆ៖** មិនដឹងពីណា នៅឯណាទេ អាហ្នឹងមិនដឹងដែរ តែដឹងថាវាធ្វើសន្តិសុខ។ ឈ្មោះ អាអោ។

**ស៖** នៅពេលគេចាប់ប្ដីលោកស្រី តើសមាជិកគណៈកម្មាធិការឃុំស្វាយយាហ្នឹង ត្រូវបានគេចាប់ខ្លួននៅពេលនោះដែរទេ?

**ឆ៖** គេចាប់តើ ចាប់យកអស់។ គណៈឃុំយកទៅស្វាយរៀង យកទៅរៀនៗ យកទៅបាត់។ យកទៅរៀនៗ យកទៅបាត់ មិនដឹងទៅឯណាមកណីទេ។

[១០:៣៩:១៧]

**ស៖** ក្រោយពេលគេចាប់ខ្លួនប្ដីលោកស្រីទៅបាត់ទៅ តើលោកស្រីធ្លាប់បានជួបគាត់ឡើងវិញនៅពេលណាមួយទេ?

**ឆ៖** ខ្ញុំមិនដែលបានជួបទេ តែគ្រាន់តែឮពាក្យគេនិយាយថា យកមកវិញ។ យកមកនៅភូមិស្វាយយាវិញ ដល់ពេលយកទៅយប់ យកទៅបាត់ យកទៅវ៉ៃចោលបាត់ទៅ។ វ៉ៃចោល ខ្ញុំតាមទៅមើលឃើញខោអាវទៀតណោះ ឃើញក្នុងអន្លង់។

**ស៖** សូមអរគុណដែលលោកស្រីរៀបរាប់អំពីប្ដី និងបងប្រុងរបស់លោកស្រី។ ឥឡូវនេះខ្ញុំចូលទៅប្រធានបទមួយទៀត តើលោកស្រីអាចជម្រាបជូនតុលាការបានទេថា ជនជាតិវៀតណាមដែលរស់នៅក្នុងភូមិស្វាយយាក្នុងរបបខ្មែរក្រហមហ្នឹងមានអ្វីកើតឡើងចំពោះពួកគេដែរ?

**ផ៖** អត់មានអីទេ។ គ្នាមានប្ដីមក ប្ដីខ្មែរហើយប្រពន្ធយួន អ៊ីចឹង! អត់មានបញ្ហាអី ទទេ។

**ស៖** លោកស្រី! លោកស្រីបាននិយាយអំពីគ្រួសារដែលរៀបការជាមួយវៀតណាម ប្ដីខ្មែរប្រពន្ធវៀតណាម ឬក៏ប្ដីវៀតណាមរៀបការជាមួយនឹងប្រពន្ធខ្មែរ។ តើមានអ្វីកើតឡើងដល់គ្រួសារដែលរៀបការចម្រុះជាតិសាសន៍នេះ ប្ដីខ្មែរការប្រពន្ធវៀតណាម ប្ដីវៀតណាមការប្រពន្ធខ្មែរ មានអ្វីកើតឡើងចំពោះពួកគេនៅក្នុងរបបខ្មែរក្រហម?

**ផ៖** មានយកប្រពន្ធៗយួន យកទៅវ៉ៃចោល យកទាំងកូនទាំងប្រពន្ធយកទៅវ៉ៃចោល។ ប្ដីនៅឱបនឹងទ្រូង បេះអែ្ហងយកទៅបាត់។ បានជាខ្ញុំវាដូចជាហួសពេក បើទុកកូនឲ្យនៅ អត់អីទេ តែយកទាំងអស់។

[១០:៤១:៥៦]

**ស៖** លោកស្រី ក្នុងករណីដែលគ្រួសាររៀបការចម្រុះអ៊ីចឹង បើប្រពន្ធជាជនជាតិវៀតណាម គេចាប់ប្រពន្ធយកទៅ ចុះកូនៗ?

**ផ៖** កូនៗយកទៅអស់រលីង គេមិនទុកផង។ គេថា នាំជាប់សាសន៍។

**ស៖** តើជនជាតិវៀតណាមប៉ុន្មាននាក់នៅក្នុងភូមិលោកស្រីហ្នឹងត្រូវបានគេយកទៅបាត់នោះ?

**ផ៖** គេយកទៅបាត់នោះបួនគ្រួសារ បាត់ៗបួនគ្រួសារទេ។

**ស៖** ចុះធ្វើម៉េចបានជាលោកស្រីដឹងថា គេចាប់ជនជាតិវៀតណាមយកទៅបាត់ ហើយសម្លាប់ចោល ម៉េចបានជាលោកស្រីដឹង?

**ផ៖** នៅក្បែរផ្ទះខ្ញុំ នៅជិតហ្នឹង ប្រហែល១គីឡូដីហ្នឹង។ ខ្ញុំមិនដឹងម៉េច! ហើយប្ដីខ្ញុំនៅនុ៎ងដែរ ធ្វើប៉ូលិស -- ធ្វើគណៈឃុំនៅនុ៎ងដែរ។

**ស៖** តើជនជាតិវៀតណាមដែលគេចាប់ខ្លួន ហើយយកទៅសម្លាប់ហ្នឹង គេចាប់ខ្លួននិងសម្លាប់នៅពេលណាដែរ? មុនពេលគេចាប់ខ្លួនប្ដីលោកស្រី ឬក៏ក្រោយពេលគេចាប់ប្ដីលោកស្រី ហើយយកកម្មាភិបាលទាំងនេះមកជំនួសនោះ?

**ផ៖** គេយកពួកយួនទៅហើយ បានគេមកចាប់ប្ដីខ្ញុំទៅ។ យកៗសុទ្ធតែយកយប់ គ្មានយកថ្ងៃទេ។ សម្លាប់អស់មួយស្តុក នុ៎ងមួយស្តុកប្ដីប្រពន្ធកូនយកទាំងអស់។

**ស៖** តើលោកស្រីដឹងថាអ្នកណាជាអ្នកបញ្ជាឲ្យចាប់ និងយកជនជាតិវៀតណាមទាំងនោះទៅសម្លាប់ចោល?

[១០:៤៤:៤៥]

**ឆ៖** អើ! ដែលអត់ពីប្ដីខ្ញុំទៅ មានគេមកកាន់កាប់ក្រោយ។ ហើយដល់អ៊ីចឹងគេប្រមែលប្រមូលយកទៅអស់រលីង រលត់ហើយ។ តែខ្ញុំអត់ស្គាល់គេទេ មិនដឹងពីណានៅណាទេ។ ខ្ញុំមិនដែលឃើញមុខគេផង។

**ស៖** ខ្ញុំចង់សួរបញ្ជាក់ចំណុចមួយ។ ការចាប់ក្រុមគ្រួសារវៀតណាមនេះ គេចាប់ក្រោយពេលប្ដីលោកស្រីបាត់ខ្លួនហើយ ឬក៏ថាគេចាប់ខ្លួនជនជាតិវៀតណាមទាំងនេះនៅពេលដែលប្ដីលោកស្រីនៅកំពុងធ្វើជាគណៈឃុំនៅឡើយ?

**ឆ៖** អត់ទេ ប្ដីខ្ញុំទៅបាត់អស់ហើយ បានគេមានឃុំ គេមកក្រោយ។ ដល់មកក្រោយគេរម្លីងហ្នឹង គេតាមក្រោយ។ មិនមែនទៅមុនប្ដីខ្ញុំទេ។ ប្ដីខ្ញុំគ្មានដឹងខ្យល់អីទេ គ្នា។

**ស៖** ខ្ញុំសូមអានសម្រង់មួយ។ មុនចូលសម្រង់នេះ សុំសួរសំណួរមួយផ្សេងទៀតសិន។ នៅពេលកម្មាភិបាលថ្មីមកដល់ ហើយទទួលមុខងារគណៈឃុំជំនួសប្ដីលោកស្រី តើកម្មាភិបាលថ្មីនេះមានបើកអង្គប្រជុំ ហើយនិយាយអំពីក្រុមគ្រួសារដែលបានរៀបការចម្រុះជាតិសាសន៍ជាមួយនឹងជនជាតិវៀតណាមនេះដែរទេ?

**ឆ៖** ខ្ញុំនិយាយមែនទែនទៅ ដល់ពេលគេប្រជុំ ខ្ញុំអត់ដែលបានទៅទេ ព្រោះគេប្រជុំៗគ្នាគេទៅ ហើយខ្ញុំមិនបានទៅក្បែរគេទេ ខ្ញុំលែងរវល់តែហ្នឹង។ ខ្ញុំនឹកឃើញថា ប្ដីខ្ញុំងាប់ហើយ ខ្ញុំមិនទៅក្បែរទេ។ ខ្ញុំនឹកឃើញអ៊ីចឹង ហើយដល់ផ្ទះ ខ្ញុំមិនដែលដឹងផងហ្នឹង។

[១០:៤៧:១១]

**ស៖** លោកស្រីនៅចាំថា ធ្លាប់បានឮអំពីកិច្ចប្រជុំមួយដែលកម្មាភិបាលថ្មី គេបានបើកអង្គប្រជុំហ្នឹង ហើយដែលក្នុងអង្គប្រជុំហ្នឹង គេនិយាយអំពីវិធានការផ្សេងៗចំពោះជនជាតិវៀតណាម លោកស្រីធ្លាប់បានឮអំពីអង្គប្រជុំនេះទេ?

**ឆ៖** ខ្ញុំមិនដែលបានឮទេ។ អត់ដែលទៅក្បែរគេទេ ព្រោះខ្ញុំស្អប់។ ខ្ញុំមិនទៅទេ។

**ស៖** ខ្ញុំសូមអានសម្រង់មួយ ដើម្បីជួយរំឭកដល់ការចង់ចាំរបស់លោកស្រី គឺសម្រង់នៃកិច្ចសម្ភាសឯកសារ E3/7794 ERN ជាភាសាខ្មែរ 00249918 ដល់ 19, អង់គ្លេស 00251407, បារាំង 00285548។ នេះគឺអ្វីដែលលោកស្រីបានឆ្លើយជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត៖ “ប្រជាជនដែលត្រូវគេឲ្យទៅប្រជុំ ពាក់ព័ន្ធទៅនឹងកម្មាភិបាលដែលគេទើបបញ្ជូនមកថ្មី

គេថាប្រសិនណាជា ឪពុកជាវៀតណាម គឺយកតែឪពុកហ្នឹងទៅសម្លាប់ចោលបានហើយ។ ប៉ុន្តែប្រសិនណាបើម្តាយណាជនជាតិវៀតណាម គឺថាគេនឹងយកទាំងម្តាយទាំងកូននោះយកទៅសម្លាប់ចោលដោយសារតែកូនៗហ្នឹងបៅទឹកដោះម្តាយ។" តើចំណុចនេះវាជួយរំឭកដល់ការចងចាំរបស់លោកស្រីទេ ដែលប្រជាជនរស់នៅក្នុងឃុំលោកស្រីហ្នឹង ប្រាប់លោកស្រីថា គេប្រជុំនិយាយអំពីចំណុចនេះ?

**ឆ៖** គេនិយាយអ៊ីចឹងមែន។ គេថាអ៊ីចឹង គេថា ម៉ឹមទឹកដោះម្តាយ គេមិនទុកទេកូន យកទៅទាំងអស់ ហើយកូនប៉ុន្មាននាក់យកទៅ កូនពីរនាក់យកទាំងពីរ។ អត់ទុកទេ ទុកតែឪទេ។

[១០:៤៩:៤០]

**ស៖** លោកស្រីនៅចាំទេ អ្នកណាអ្នកភូមិហ្នឹង ប្រាប់លោកស្រីអំពីបញ្ហានេះ? លោកស្រីបានឮពីតែអ្នកភូមិតែម្នាក់ ឬឮពីអ្នកភូមិច្រើននាក់ដែរ?

**ឆ៖** ឥឡូវខ្ញុំមិននេះទេ។ មួយវាធ្វើការនៅជាមួយគ្នា ពីដើមធ្វើជាមួយគ្រួសារខ្ញុំ ដល់ពេលនេះគេសល់ គេកែមកនៅ បែរខ្នងមកនៅក្រោយ។ ហើយដល់ពេលអ៊ីចឹង ឈ្មោះ អាសារិន អាហ្នឹង។ អាសារិន វាមក វាចុះលានៅនឹងភូមិស្វាយយាដែរនោះ ដល់អ៊ីចឹងវានិយាយ វានិយាយអត់ខ្លាចទេ ហើយខ្ញុំចាំតែស្តាប់គេ តែខ្ញុំឯនេះវាស៊ឹងដាច់ពោះវៀនអស់ទៅហើយ ភ័យ។

**ស៖** ហើយក្រោយពីបុគ្គលនេះប្រាប់លោកស្រីអំពីកិច្ចប្រជុំមួយនេះ តើលោកស្រីបានដឹងអំពីការចាប់ខ្លួនជនជាតិវៀតណាម ហើយនិងកូនៗយកទៅសម្លាប់នោះទេ?

**ឆ៖** ខ្ញុំគ្រាន់តែបានដឹងថា គេសម្លាប់។ ខ្ញុំអត់បានដឹងថា គេម៉េចៗខ្ញុំមិនដឹង ប៉ុន្តែឈ្មោះវាន៉ុង អាសារិនៗ ហ្នឹងវាអ្នកដើរសម្លាប់ជាមួយគ្នា អាគណៈឃុំថ្មី ជាមួយពួកសន្តិសុខ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** តើ អាសារិន នេះមានប្រាប់លោកស្រីអំពីការសម្លាប់អ្នកទាំងនេះទេ?

**ឆ៖** វាប្រាប់អីយើង! វាគ្រាន់តែដើរនិយាយ ហើយឮដល់។ វាៗអ្នកធ្វើការ វាចូលគណៈឃុំក្រោយៗ វាហ្នឹងលាក់ដែលាក់ជើង។

[១០:៥២:០៨]

**ស៖** ខ្ញុំសូមអានសម្រង់មួយទៀត នៃកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតគឺ ERN ជាភាសាខ្មែរ 0029918*(ស៊ីក)*, អង់គ្លេស 00251407, បារាំង 00285547 គឺឯកសារ E3/7794។ សូមដកស្រង់៖ "នៅក្នុងពេលនោះដែរជនជាតិខ្មែរពីភូមិស្វាយយាត្រូវបានគេបញ្ជូនចេញហ្នឹង ឯជនជាតិវៀតណាមវិញ ត្រូវបានគេចាប់ខ្លួនយកទៅសម្លាប់ចោល។ ឧទាហរណ៍ នៅភូមិទួលវិហារ ឃុំស្វាយយា

ដែរនេះ ខ្មែរឈ្មោះ ឆោម ការជាមួយប្រពន្ធយួន គឺថាត្រូវបានចាប់ប្រពន្ធ និងកូនៗយកទៅសម្លាប់ចោល។ នៅភូមិមួយទៀត ភូមិស៊ីការ ឃុំស្វាយយាដែរ ប្តីឈ្មោះ ឈិន គឺថារៀបការជាមួយប្រពន្ធយួន ដូច្នេះប្រពន្ធ និងកូនៗនោះត្រូវបានគេចាប់ខ្លួនយកទៅសម្លាប់ចោលទាំងអស់។ មួយទៀត នៅភូមិកៀនតាសៀវ ឃុំស្វាយយាដែរ ប្តីនិងប្រពន្ធហ្នឹង គឺជាយួនទាំងពីរនាក់ (ខ្ញុំភ្លេចឈ្មោះពួកគាត់ទៅ)។ ដូច្នេះគ្រួសារទាំងមូលហ្នឹង គឺថាប្រមូលយកទៅសម្លាប់ចោលអស់។ ខ្ញុំដឹងបញ្ហានេះ ពីព្រោះនៅប្រជាជននៅភូមិហ្នឹងគេជួបគ្នា គេនិយាយប្រាប់គ្នាតៗគ្នា។"

លោកស្រីសាក្សី ក្នុងសម្រង់នេះ លោកស្រីនិយាយអំពីអ្នកភូមិបីនាក់ ដែលរៀបការជាមួយវៀតណាម ត្រូវយកទៅសម្លាប់ចោលនៅភូមិទួលវិហារ ស៊ីការ និងកៀនតាសៀវ។ អ្នកណាប្រាប់លោកស្រីអំពីការសម្លាប់គ្រួសារទាំងបីនេះ? លោកស្រីឮពីមនុស្សដែលប្រាប់លោកស្រីតាំងពីលើកមុនមក ឬក៏លោកស្រីឮពីមនុស្សផ្សេងទៀត?

**ឆ៖** វានិយាយប្រាប់ខ្ញុំ។ គេនៅក្បែរគ្នា គេខ្សឹបប្រាប់ខ្ញុំនុ៎ង គេមិនឲ្យអ្នកណាដឹងទេ។ គេខ្សឹបប្រាប់ណ៎ា។ គេថា យកទៅអស់ហើយ យកយប់មិញ គេយកតែយប់ទេ មិនដែលយកថ្ងៃទេ។

**ស៖** លោកស្រីចាំឈ្មោះអ្នកដែលប្រាប់លោកស្រីអំពីការចាប់ខ្លួន និងសម្លាប់គ្រួសារវៀតណាមបីគ្រួសារនេះទេ? លោកស្រីចាំឈ្មោះអ្នកប្រាប់លោកស្រីហ្នឹងទេ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ ដឹងពីណាៗទេ ខ្ញុំភ្លេចអស់ហើយ ប៉ុន្តែផ្ទះក្បែរគ្នាហ្នឹង ជាប់សំយាបគ្នាហ្នឹង ប្រាប់។ តែឥឡូវវាភ្លេចអាមនុស្សហ្នឹងទៀតណ៎ា មិនដឹងម៉េចទេ។

[១០:៥៥:៥៣]

**ស៖** លោកស្រី តើខ្មែរក្រហមគេស្គាល់ថា អ្នកណាជាវៀតណាម អ្នកណាជាខ្មែរដោយរបៀបណា?

**ឆ៖** គេគ្មានស្អីទេ រឿងខ្មែរក្រហម ហើយវៀតណាម គេត្រូវគ្នាដែរ។ មានអី តែរឿងហ្នឹង ដឹងខ្ញុំវាមិនដឹងដែរ ដឹងក្រហម ដឹងសទេ។ តែខ្ញុំដឹងថា គេធ្វើបដិវត្តន៍ៗ។

**ស៖** លោកស្រីសាក្សី ខ្ញុំសួរលោកស្រីថាអ៊ីចេះ តើលោកស្រីដឹងថា ខ្មែរក្រហមនៅភូមិឃុំលោកស្រីហ្នឹង គេធ្វើម៉េចបានគេដឹងថា អ្នកណាជាជនជាតិវៀតណាមនោះ?

**ឆ៖** ទេ ខ្ញុំដូចជាមិនសូវយល់ដែរនេះ ភ្លេចអស់រលីងហើយ។ ភ្លេចមែន ខ្ញុំភ្លេចអស់ហើយ មិនសូវយល់ទេ។

**ស៖** ក្រោយការចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាមដែលលោកស្រីបាននិយាយនេះ តើមាននៅសេសសល់ជនជាតិវៀតណាមរស់នៅក្នុងភូមិឃុំលោកស្រីទៀតទេ?

**ឆ៖** មានដែរតើឥឡូវ គេមកវិញ រកស៊ីរវើក។

**ស៖** ពេលលោកស្រីនិយាយថា ពេលគេត្រឡប់មកវិញ លោកស្រីនិយាយពីអ្នកដែលរត់ចូលទៅវៀតណាម ហើយក៏វិលត្រឡប់មកវិញ ក្រោយរបបខ្មែរក្រហមដួលរលំទៅ អ៊ីចឹងអេ្ហស?

**ឆ៖** មានដែរតើ មិនថាអត់ទេ។ អើវាមិនច្រើនទេ មួយឯនេះមួយឯនោះ រកស៊ីតាមធម្មតាទៅ។

**ស៖** អ្វីដែលខ្ញុំចង់សួរ ខ្ញុំចង់សួរថាដូច្នេះ ជនជាតិវៀតណាមដែលនៅរស់រានមានជីវិតហ្នឹង តើលោកស្រីចង់និយាយថា អ្នកដែលរត់គេចខ្លួនចូលទៅប្រទេសវៀតណាម ហើយក៏វិលត្រឡប់មកវិញ អ៊ីចឹងឬក៏យ៉ាងណា?

[១០:៥៨:៣០]

**ឆ៖** វាទៅដល់ស្រុកវាហើយ វាមិនមកទេ មកអាអ្នកជិតៗ ហើយដូចថាវាមិនបានរត់នោះ វានៅសល់ ដល់អ៊ីចឹងត្រឡប់មកវិញ មករកស៊ី។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទថ្មីមួយទៀត។ នៅក្នុងរបបខ្មែរក្រហម តើមានអ្វីកើតឡើងចំពោះអ្នកភូមិឃុំរបស់លោកស្រីដែលត្រូវគេដឹងថា គឺជាអតីតទាហាន លន់ នល់? មានអ្វីកើតឡើងទៅដល់អ្នកទាំងនោះ?

**ឆ៖** ខ្ញុំ អារឿងហ្នឹង ខ្ញុំមិនសូវដឹងទេ មិនសូវចេះនឹងគេ មិនសូវដឹងទេ រឿងទាហាន លន់ នល់នោះ។ តែឮថា គេវាយៗគ្នា ខ្ញុំមិនដឹងដែរ។

**ស៖** ខ្ញុំសូមអានសម្រង់មួយទៀតចេញពីសាក្សីមួយផ្សេងដែលរស់នៅក្នុងស្រុករបស់លោកស្រីដែរ រស់នៅក្នុងឃុំធ្លក។ នៅក្នុងកំណត់ហេតុរបស់សាក្សីរូបនេះ គឺឯកសារ E3/7719, ERN ជាភាសាខ្មែរ 00344565 ដល់ 66, អង់គ្លេស 00347416, បារាំង 00411563។ សាក្សីរូបនេះ ឈ្មោះ ណុំ សារឿន ហៅ ណម។ ខ្ញុំសូមដកស្រង់៖ “ក្រោយឆ្នាំ១៩៧៦ ខ្មែរក្រហមបានប្រមូលគ្រូបង្រៀន សិស្សនិស្សិត បញ្ញវន្ត និងអតីតទាហាន លន់នល់។ ហើយបន្ទាប់មកគ្រួសាររបស់ទាហាន លន់នល់ ហ្នឹងត្រូវបានគេស្រង់ប្រវត្តិរូប ហើយបញ្ជូនទៅឲ្យរៀនសូត្រ។ ប៉ុន្តែក្រោយពេលរៀបចំប្រវត្តិរូបហើយ ស្រង់ប្រវត្តិរូបហើយ គេក៏យកទៅដាក់នៅវត្តឡុងគឿន ហើយសម្លាប់ចោល។” តើលោកស្រីស្គាល់វត្តឡុងគឿននេះទេ?

**ឆ៖** វត្តអីៗ? ខ្ញុំអត់បានស្គាល់ទេ។ ព្រោះខ្ញុំមិនសូវស្គាល់ទេ រឿងវត្តទាំងហ្នឹងនោះ។

[១១:០១:៤៩]

**លោក ស្រ៊ា វតនៈ៖**

សូមជម្រាបលោកប្រធាន ដោយសារខ្ញុំស្ដាប់ខាងបកប្រែទៅ គាត់អានវត្តហ្នឹងអត់ច្បាស់ តាមពិត វត្តហ្នឹងឈ្មោះ "វត្តល្វើន"–, ល-ូ-េី-ន។

**លោក ឌេល លីសាក់៖**

សូមអរគុណសហព្រះរាជអាជ្ញាជាតិ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីស្គាល់វត្តល្វើននេះទេ?

**ឆ៖** ស្គាល់ ស្គាល់តើ! នៅក្បែរដូនស។ អំមិញភាសាមិនច្បាស់ ខ្ញុំស្ដាប់មិនបាន។

**ស៖** តើគេប្រើវត្តហ្នឹងដើម្បីធ្វើអ្វីដែរនៅក្នុងរបបខ្មែរក្រហម?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំជំទាស់ ពីព្រោះថាវត្តល្វើននេះមិនស្ថិតនៅក្នុងចំណោមមន្ទីរសន្តិសុខដែលស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះ ជាពិសេសគឺនៅក្នុងដីកាបំបែកនីតិវិធី។ ដូច្នេះ ខ្ញុំសូមជំទាស់ចំពោះការសួរសំណួរពាក់ព័ន្ធនឹងវត្តល្វើននេះ លោកប្រធាន។

**លោក ឌេល លីសាក់៖**

សូមលោកប្រធាន គឺថាភ័ស្តុតាងពីសាក្សីនេះបញ្ជាក់ថា ទាហាន លន់នល់ ត្រូវបានគេប្រមូលហើយគេយកទៅសម្លាប់នៅកន្លែងនេះ។ នេះជាគំរូនៃហេតុការណ៍ដែលយើងបានដឹងនៅទូទាំងប្រទេស បញ្ហានេះ បានលើកឡើងជាញឹកញាប់ ហើយភ័ស្តុតាងនោះគឺថា បញ្ជាក់ថា អ្វីដែលកើតឡើងចំពោះមន្ត្រីអតីតទាហាន លន់នល់ នោះគឺជាគំរូនៃគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងយើងចង់សួរសាក្សីថាតើគាត់ដឹងដែរឬទេពីបញ្ហានេះ ដើម្បីជាភ័ស្តុតាងស៊ីសង្វាក់ ថាតើគាត់ដឹងពីអតីតទាហាន លន់នល់ ឬក៏មន្ត្រី លន់នល់ គេយកទៅវត្តហ្នឹងដែរឬទេ។

[១១:០៤:២០]

**លោក វិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំជឿជាក់ថា សហព្រះរាជអាជ្ញាដឹងថាភ័ស្តុតាងសំខាន់នៅក្នុងសៀវភៅ ប៉ែន យៀរនិន អំពីការប្រព្រឹត្តលើទាហាន លន់នល់ នៅភូមិភាគបូព៌ាត្រឹមត្រូវ ឬមិនត្រឹមត្រូវ ប៉ុន្តែគាត់ធ្វើទឡ្ហីករថា មន្ត្រី លន់នល់ ត្រូវបានបញ្ជូនទៅរៀនសូត្របន្ទាប់ពីឆ្នាំ១៩៧៥ បីបួនខែក្រោយមកត្រូវបានដោះលែង។ ហើយការដែលនិយាយថា អ្វីដែលកើតឡើងនៅក្នុងភូមិភាគបូព៌ានោះគឺថា គឺស្ថិតនៅក្នុងសៀវភៅ ប៉ែន យៀរនិន។ តើអ៊ីចឹងឬទេ សហព្រះរាជអាជ្ញា?

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមឆ្លើយតបលោកប្រធាន គឺបញ្ហាពិតប្រាកដដែលយើងកំពុងតែជួបប្រទះនោះគឺថា យើងបានដាក់បញ្ចូលព័ត៌មានដែលមិនមាននៅក្នុងដីកាដំណោះស្រាយ ហើយវាក៏មិនស្ថិតនៅក្នុងការស៊ើបអង្កេតដែរ។ ដូច្នេះមេធាវីការពារក្តីមិនបានដឹងអំពីបញ្ហានេះទេ ហើយជាគោលការណ៍យើងមានដីកាដំណោះស្រាយដែលបញ្ជាក់ច្បាស់លាស់អំពីបទចោទ។ ដូច្នេះយើងត្រៀមខ្លួនទៅតាមបទចោទទាំងអស់នេះ ហើយប្រសិនបើយើងចេះតែបន្ថែមភ័ស្តុតាង ហើយថាវាជាគោលនយោបាយទូទៅនៅថ្នាក់ជាតិគឺជារំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៦:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះចាត់តាំងលោក ប្រគល់ភារៈជូនលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសម្រេចលើសេចក្តីជំទាស់របស់មេធាវីការពារក្តីទាំងពីរក្រុម ជំទាស់ទៅលើការតាំងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ដែលជំទាស់អំពីវិសាលភាពនៃអង្គហេតុដែលត្រូវជំនុំជម្រះ គឺក្រៅពីវិសាលភាពនៃអង្គហេតុ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសម្រេចបដិសេធជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន។ នេះជាការលំបាកដូចគ្នាដែលយើងធ្លាប់ជួបប្រទះរួចមកហើយកាលពីអតីតកាល។ គឺសំណួរពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅទៅលើអតីតយោធា និងមន្ត្រីរដ្ឋការ

របប លន់ នល់។ វាមានភាពពាក់ព័ន្ធសំណួរ ដូច្នេះអង្គជំនុំជម្រះអនុញ្ញាតឲ្យសួរបាន ក៏ប៉ុន្តែអង្គជំនុំជម្រះមិនចង់ឲ្យការសួរនេះចូលទៅលម្អិតខ្លាំងពេក ពាក់ព័ន្ធទៅនឹងទិដ្ឋភាពនៃបញ្ហាដែលបានកើតឡើងនោះទេ។

**លោក ឌេល លីសាក់៖**

ខ្ញុំនឹងសួរសំណួរផ្តោតដោយជាក់លាក់ ហើយខ្ញុំនឹងសួរពីបញ្ហាបន្ត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅវត្តនេះ លោកស្រីសាក្សី វត្តល្វើននេះ តើលោកស្រីនៅចាំដែរឬទេថា តើគេប្រើដើម្បីធ្វើអ្វី? តើលោកស្រីចាំច្បាស់លាស់ដែរឬទេថា អតីតទាហានលន់ នល់ ហើយនិងអតីតមន្ត្រីរបបលន់ នល់នោះត្រូវបានគេយកទៅកន្លែងហ្នឹងក្នុងឆ្នាំ១៩៧៥ និង១៩៧៦?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** ខ្ញុំមិនបានដឹង បានឮទេ ពីព្រោះខ្ញុំអារឿងគេៗគិតផ្សេង ខ្ញុំគិតផ្សេង។ អ៊ីចឹងខ្ញុំអត់ដឹងផង វាភ្លេចភ្លាំងដែរហើយ។ បើខ្ញុំដឹង ក៏ខ្ញុំភ្លេចដែរ ភ្លេចអស់ហើយ។

[១១:០៩:១៥]

**ស៖** បញ្ហាចុងក្រោយដែរខ្ញុំចង់សួរលោកស្រីសាក្សី តើលោកស្រីដឹងទេនៅក្នុងរបបខ្មែរក្រហមថាតើលោកស្រីដឹងថា ខៀវ សំផន ធ្វើអ្វីទេ? ហើយលោកចាំថា គាត់បានទៅតំបន់លោកស្រីទេកាលណោះ តាមអ្វីដែលលោកស្រីចងចាំនោះ?

**ឆ៖** បានដឹងតែបង ហ៊ូ នឹម, ហ៊ូ យន់ ទេ គាត់ទៅធ្វើស្រែស្រូវប្រាំង ហើយបើថា ខៀវ សំផនវត់ចូលបាត់ហើយ។ ខ្ញុំដឹងប៉ុណ្ណឹង។

**ស៖** តើ ហ៊ូ យន់ និង ហ៊ូ នឹម ទៅតំបន់លោកស្រីហ្នឹងក្នុងឆ្នាំណាដែរ?

**ឆ៖** ទៅឆ្នាំ៧៦ ទៅធ្វើស្រូវប្រាំង។

**ស៖** ខ្ញុំចង់អានសេចក្តីដកស្រង់អំពីចម្លើយសាក្សីមួយដែលខ្ញុំទើបតែបានអាន គឺឯកសារ E3/7719, ខ្មែរ ERN 00344567, អង់គ្លេស 00347418, បារាំង 00411565។ នៅក្នុងសេចក្តីដកស្រង់នេះ ខ្ញុំនឹងអានសាក្សីនេះនិយាយដែលជា គាត់បញ្ជាក់ថា គណៈស្រុករបស់លោកស្រីឈ្មោះ ខៀវ សាមិ។ សូមដកស្រង់៖ “ខ្ញុំបានឮថា ខៀវ សាមិត គឺជាបងប្អូនរបស់លោក ខៀវ សំផន។ ខៀវ សំផន បានមកមើលការងាររបស់ប្រជាជននៅទំនប់ ប្រឡាយនៅភូមិផ្លូក។” ចប់សេចក្តីដកស្រង់។ សំណួរទី១

របស់ខ្ញុំ តើលោកស្រី ថាតើលោកស្រីបានដឹងឬទេ ថាតើ ខៀវ សាមិត ជាប្រធានស្រុក គណៈស្រុក តើគាត់ជាបងប្អូនជាប់សាច់ញាតិអីនឹងលោក ខៀវ សំផន ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងផង ដឹងគាត់បងប្អូនសាច់ឈាមអីទេ។ ប៉ុន្តែដឹងតែថា គាត់នៅខេត្តតាកែវ ហើយគាត់ធ្វើការ។ ដល់ពេលអ៊ីចឹងគាត់មកធ្វើការនៅហ្នឹង នៅស្វាយយា ឃុំស្វាយយាហ្នឹង។ ខ្ញុំបើថាដឹងថាបងប្អូន ខៀវ សំផន ខ្ញុំមិនស្គាល់ទេ ខ្ញុំមិនដឹងទេ។

[១១:១២:០៨]

**ស៖** លោកបានប្រាប់តុលាការថា ធ្វើការនៅទំនប់ ប្រឡាយ ហើយនិង តើលោកស្រីធ្វើនៅការដ្ឋាននៅថ្លុក នៅភូមិថ្លុកទេ? បើកាលណោះ តើមានមេដឹកនាំពីភ្នំពេញទៅមើលការដ្ឋាននៅកន្លែងលោកស្រីធ្វើការដែរឬទេ?

**ឆ៖** មានតែបងនេះទេ ហ៊ូ យន់ ហ៊ូ នឹម ទេ តែពីរនាក់ហ្នឹង តែក្រៅពីហ្នឹង ខ្ញុំអត់ដឹងទេ។ ខ្ញុំអត់ដឹងអី។

**ស៖** សំណួរចុងក្រោយរបស់លោកស្រី នៅក្នុងពេលបទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E3/7526 ខ្មែរ ERN 00185385, បារាំង ERN 00746963។ លោកស្រីបាននិយាយពីបញ្ហាមួយទាក់ទងទៅនឹង ខៀវ សំផន។ ខ្ញុំនឹងឲ្យសហសេវិករបស់ខ្ញុំអានភាសានេះ ដើម្បីឲ្យលោកស្រីស្ដាប់ជាភាសាខ្មែរដោយផ្ទាល់ ហើយនិងខ្ញុំសួរបន្ទាប់ពីនេះ។

**លោក ស្រ៊ា រតនៈ៖**

សូមដកស្រង់៖ “ដែល ខៀវ សំផន ហ្នឹង កាលពីដើមពូកែណាស់ខាងខ្មែរក្រហម ប៉ុន្តែដល់ក្រោយមកទាំងអស់គ្នាតែម្ដង ទាញក្បាលគ្នាឯងយកទៅសម្លាប់ចោលតែម្ដង ខ្ញុំនឹកឃើញ។” បញ្ចប់ការដកស្រង់។

[១១:១៣:៤៨]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** តើលោកស្រីនៅចាំថាលោកស្រីបានផ្ដល់ចម្លើយបែបនេះទៅអ្នកសម្ភាសន៍មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាទេ? ដែលលោកស្រីបាននិយាយពីរឿងលោក ខៀវ សំផន តើលោកស្រីអាចនិយាយលម្អិត ឬក៏ពិស្ដារជាងនេះបន្ថែមជូនតុលាការបានទេ?

**លោកស្រី ស៊ិន ផែម៖**

**ឆ៖** ខ្ញុំគ្រាន់តែដឹងត្រួសៗ។ ខ្ញុំដឹងត្រង់ថា ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ចូលក្នុងគណបក្សខ្មែរក្រហម។ ដល់ពេលក្រោយមក ខៀវ សំផន រត់ចូលខ្មាំង ហើយដល់អ៊ីចឹងពួកនេះភ័យ ថាអ៊ូ! គេរត់ចូលខ្មាំងហើយ។ ដល់អ៊ីចឹងទៅភ័យ មានណាបានតែបន្តិច អូសក្បាលយកទៅចោល យកទៅវាយចោលអស់រលីងទៅ។ បានដោយអ្នែងមួយហ្វូងមួយហ្វាយទៅៗ។ អ៊ីចឹងបានខ្ញុំឆ្ងល់ដែរ។

**លោក ឌេល លីសាក់៖**

លោកស្រីសាក្សីសូមអរគុណ ដែលលោកស្រីបានចំណាយពេលឆ្លើយសំណួររបស់ខ្ញុំ។ ខ្ញុំនឹងផ្តល់វេទិកាទៅសហសេវិកជាតិដើម្បីសួរសំណួរលោកស្រីបន្ត។

**លោក ស្រ៊ា រតនៈ៖**

សូមលោកប្រធាន លោក លោកស្រីចៅក្រម ភាគី។

[១១:១៥:១៤]

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ជម្រាបសួរលោកស្រី។ ខ្ញុំបាទមានសំណួរខ្លីទេ បើលោកស្រីឆ្លើយតបទៅនឹងសំណួរខ្ញុំច្បាស់ ប៉ុន្តែអាចនឹងវែងបន្តិច បើសិនលោកស្រីស្តាប់អត់សូវបាន។ សំណួរហ្នឹងគឺពាក់ព័ន្ធទៅនឹងប្រធានបទនៃការសម្លាប់ជនជាតិវៀតណាមក្នុងភូមិរបស់លោកស្រី។ លោកស្រីបានឆ្លើយនៅក្នុងកំណត់ហេតុរបស់សហចៅក្រមស៊ើបសួរ -- ស៊ើបអង្កេតថា មានការសម្លាប់ប្រពន្ធវៀតណាម និងកូនវៀតណាមនៅសល់ ដែលក្នុងនោះនៅសល់ប្តីជាជនជាតិខ្មែរនៅរស់។ អ៊ីចឹងខ្ញុំចង់សួរថា តើប្តីជាជនជាតិខ្មែរហ្នឹងក្រោយដែលនៅរស់ហ្នឹង ក្រោយមកតើគាត់ត្រូវបានគេបង្ខំឲ្យរៀបការ ឬក៏ត្រូវបានរៀបការនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងដែរឬទេ?

**លោកស្រី ស៊ិន ផែម៖**

**ឆ៖** គាត់អ៊ីចេះ! គាត់នេះទៅ គាត់ស្រឡាញ់គ្នា។ ដល់ស្រឡាញ់គ្នា យកគ្នាហើយ ដល់បានកូនបានជាចៅហើយ វាទៅដល់ពេលមែនទែន យកគ្នាទៅសម្លាប់ចោលអស់។ ហើយវាអាណោចអាធ័មតិចអី កូនប៉ុនៗកដៃ កជើង។ ខ្ញុំវាហួសចិត្ត ខ្ញុំថា ខ្ញុំហួសចិត្តហើយ។

**ស៖** អ្វីៗដែលខ្ញុំចង់ជម្រាបសួរលោកស្រីនៅទីនេះ គឺចង់សួរថា ប្តីរបស់ជនជាតិវៀតណាមដែលត្រូវបានគេយកទៅសម្លាប់នោះ ក្រោយមក តើគាត់បានរៀបការម្តងទៀតទេ?

**ឆ៖** អត់។ គាត់អត់យក ឥឡូវស្លាប់អស់ហើយ គ្មាននៅទេ។

**ស៖** ចុះអ្នកដែលលោកស្រី ជនជាតិវៀតណាម ស្ត្រីជនជាតិវៀតណាមដែលលោកស្រីអះអាងថា ត្រូវបានគេនាំយកទៅសម្លាប់ហ្នឹង លោកស្រីដែលឃើញទៀតទេ នៅពេលក្រោយមក?

**ឆ៖** គ្មានទេ មិនដែលឃើញទេ។ គ្មានស្អីទៀតទេ អស់ ចប់ហ្មង។

**លោក ស្រ៊ា រតនៈ៖**

ខ្ញុំបាទអស់សំណួរត្រឹមប៉ុណ្ណេះ។ អរគុណលោកប្រធាន។

[១១:១៧:៤៤]

**ប្រធានអង្គជំនុំ៖**

ចុះខាងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានសំណួរសួរដល់សាក្សីរូបនេះដែរឬទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខាងយើងខ្ញុំអត់មានសំណួរទេ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

នៅជាង១០នាទីទៀត ចុះខាង -- ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីដំបូងនេះ ផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំចង់ចាប់ផ្តើមក្រោយពេលសម្រាក ប៉ុន្តែខ្ញុំនឹងត្រូវតទល់ជាមួយសាក្សី ដោយហេតុថា ចុងម៉ោងនេះគាត់ប្រហែលជាមិនបានត្រៀមខ្លួនទេ។ ខ្ញុំនឹងសួរសំណួរមួយចំនួនច្រើន។ បើអង្គជំនុំជម្រះមិនយល់ទាស់ទេ ខ្ញុំចង់សូមអនុញ្ញាតចាប់ផ្តើមក្រោយពេលសម្រាកអាហារថ្ងៃត្រង់ លោកប្រធាន។ ប្រសិនបើអង្គជំនុំជម្រះមិនអនុញ្ញាតថាឲ្យខ្ញុំចាប់ផ្តើមក្រោយទេ ខ្ញុំចាប់ផ្តើមឥឡូវនេះ ចំណាយពេល១០នាទី ក៏បាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

[១១:១៩:២៧]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងប្រើពេលនេះ។ សូមជម្រាបសួរលោកស្រីសាក្សី។ ព្រឹកនេះ ភាគីសួរសំណួរច្រើនទៅលោកស្រី ទៅមនុស្សម្នាក់ឈ្មោះ កែវ មាស ដែលថាជាបងប្អូនជីដូនមួយ ជីទួតមួយ ហើយគាត់រស់នៅភូមិលោកស្រី ហើយលោកស្រីស្គាល់ច្បាស់។ តើអាចដែរឬទេ លោកស្រីនិយាយឲ្យបានពិស្តារឲ្យបានលម្អិតជាងនេះ តើលោកស្រីនឹកឃើញគាត់ពីអ្វី? តើគាត់រស់នៅក្នុងភូមិយ៉ាងម៉េច? ជាមនុស្សបែបណាមុននឹងគាត់ចូលបដិវត្តន៍? ហើយចូលបដិវត្តន៍ហ្នឹងបែបណា? លោកស្រីរៀបរាប់ឲ្យវែងបន្តិចបានទេ?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** ខ្ញុំមិនបានដឹងទេ។ គាត់ទៅបាត់ៗទៅ តែបើ ពូធុច ខ្ញុំចាំ គាត់ធ្វើគ្រូបង្រៀន។ ប្អូនគាត់ តែបើគាត់ៗដើរបាត់ទៅ រកស៊ីនេះទៅ ហើយជួបខ្ញុំហ្នឹងទាក់ទងគ្នាធ្វើគ្រូបង្រៀនបងខ្ញុំ។ បងខ្ញុំរៀនទៅបានទៅសញ្ញាបត្រប្រឡងគ្រូវាធ្លាក់។ ដល់អ៊ីចឹងទៅៗចូលរៀនជាមួយគាត់ទៀត។ ខ្ញុំបានដឹងតែប៉ុណ្ណឹងទេ ហើយស្រាប់គាត់បាត់ខ្លួនទៅ។

**ស៖** តើលោកស្រីចាំដែរឬទេ កែវ មាស គាត់ទៅកន្លែងណា នៅពេលដែលលោកស្រីថាមិនបានឃើញគាត់ទៀតហ្នឹង ហេតុអ្វីបានជាមិនបានឃើញគាត់នៅពេលនោះ?

[១១:២១:១៣]

**ឆ៖** គាត់មិនដែលចូលស្រុកផងហ្នឹង។ ហើយម្យ៉ាងទៅថាគាត់នៅស្អីទេ នៅភ្នំពេញហ្នឹងដែរ ហើយបងខ្ញុំក៏នៅហ្នឹងដែរ ហើយឥឡូវវាភ្លេចទៅ ខ្ញុំភ្លេចអស់ហើយ។ កាលមុនចាំ ឥឡូវភ្លេចអស់ហើយមិនដឹងស្អីទេ។

**ស៖** តើមុនឆ្នាំ១៩៧៥ តើគាត់នៅកន្លែងណា? គាត់នៅក្នុងប្រទេសកម្ពុជា ឬក៏គាត់នៅប្រទេសក្រៅទេ និយាយពីរឿង កែវ មាស?

**ឆ៖** នៅក្នុងប្រទេសកម្ពុជា គ្មានទៅប្រទេសណាទេ។ ហើយដល់ពេលអ៊ីចឹងទៅ គាត់គេចខ្លួនគេចៗ គេតាមរកឃើញ គេចាប់យកទៅសម្លាប់បាត់ទៅ។ មិនដឹងគេចទៅណា ខ្ញុំមិនដឹងដែរ។

**ស៖** លោកស្រីសាក្សី ខ្ញុំសួរលោកស្រីអំពីពេលមុនឆ្នាំ១៩៧៥។ លោកស្រីសាក្សី ខ្ញុំសួរលោកស្រីអំពីទីកន្លែងរបស់គាត់ ដែលគាត់ទៅណា ធ្វើអ្វីមុនឆ្នាំ១៩៧៥? តើគាត់តែងតែទៅប្រទេសវៀតណាមដែរឬទេ មុនឆ្នាំ១៩៧៥?

ឆ៖ បើតាមខ្ញុំស្តាប់មើលទៅ ដែលឮខ្ញុំហ្នឹងគាត់គ្មានដែលទៅទាក់ទងអីវៀតណាមទេ គាត់នៅតែភ្នំពេញហ្នឹង។ នៅហៅស្អីទេក្នុងភ្នំពេញហ្នឹង ខ្ញុំវាភ្លេចអាកន្លែងហ្នឹងទៅ។ នៅតែនឹងហ្នឹង គាត់នៅរកស៊ីរបរធម្មតា ដូចគេដូចឯង។ ដល់ពេលឮថាអ៊ីចឹង គាត់គេចខ្លួន ដល់គេចៗ គេតាមរកឃើញ គេចាប់យកមកសម្លាប់ទៅ។ ខ្ញុំសូមមិនបានដឹងគាត់ធ្វើអីៗ ខ្ញុំមិនបានដឹងទេ។

សៈ អ្វីដែលលោកស្រីនិយាយហ្នឹង គឺថាលោកស្រីមិនដែលឮថា អ្វីទេថាគាត់នៅវៀតណាមទេនៅមុនឆ្នាំ១៩៧៥នោះ?

ឆ៖ វាមិនដែលឮ គាត់មិនដែលទៅនៅឯវៀតណាម។ ឮតែគាត់នៅតែភ្នំពេញ ត្រង់ផ្សារស្អីគេទេ ខ្ញុំភ្លេចទៅ ខ្ញុំវាភ្លេច។ ហើយបងខ្ញុំមកនៅហ្នឹងដែរ គាត់ធ្វើគ្រូបង្រៀនបងខ្ញុំ។ ហើយ តាឈូក ហ្នឹងក៏ធ្វើគ្រូបង្រៀនបងខ្ញុំដែរ។ ពេលគាត់មិនបង្រៀន ឲ្យ ពូឈូក។ បានជាខ្ញុំចាំបាន ហើយឥឡូវវាភ្លេចអាផ្សារហ្នឹងទៅ វាមិនដឹងផ្សារស្អី។ ខ្ញុំភ្លេចអស់ហើយ ស្មារតីខ្ញុំភ្លេចទៅ។ កាលពីដើមខ្ញុំចាំ ឥឡូវខ្ញុំភ្លេចអស់ហើយ។

សៈ តើលោកស្រីដឹងទេថា ពូរបស់លោកស្រីពាក់ព័ន្ធនឹងការចូលបដិវត្តន៍នៅក្នុងឆ្នាំ១៩៥១ ដែរឬទេ?

ឆ៖ ខ្ញុំដឹងតែត្រង់ថា កាលបងខ្ញុំមុនចូលគ្នាថា ជំនុំគ្នាថាទៅចូលហើយបដិវត្តន៍ ប៉ុន្តែមិនដឹងជំនុំគ្នាពីកាលណាទេ គេនិយាយកាលណា ស្រាប់តែឃើញគេរវើទ្រុលអ៊ីចឹងទៅ បានខ្ញុំដឹងខ្លួន ចុះខ្ញុំស្រីហើយខ្ញុំនៅតែផ្ទះ។ ខ្ញុំមិនដែលដឹងអីផង។

សៈ តើលោកស្រីដឹងដូចម្តេចថា គាត់ចូលបដិវត្តន៍ពេលជាមួយគ្នា ជាមួយប្តី ជាមួយបងលោកស្រីហ្នឹង? តើលោកស្រីដឹងដោយរបៀបណា?

ឆ៖ បងខ្ញុំនិយាយប្រាប់។

[១១:២៥:៣៧]

សៈ តើបងប្រុសរបស់លោកស្រីចូលបដិវត្តន៍នៅពេលណា? តើនៅដើមឆ្នាំ១៩៥០ឬ?

ឆ៖ ទេ ខ្ញុំមិនដែរ ប្រហែលជាឆ្នាំ១៩៧៥ហ្នឹងយ៉ាង។

សៈ បាទ ខ្ញុំព្យាយាមសួរសំណួរអំពីពេលវេលា។ តើអាចដែរឬទេ បងប្រុសរបស់លោកស្រីហើយ កែវ មាស ជាពូរបស់លោកស្រីចូលបដិវត្តន៍ គឺចូលក្នុងឆ្នាំ១៩៥១ គឺជាបក្សដែលមុនពីបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ថា ខ្ញុំវាមិនដឹង។ ខ្ញុំវាមិនដឹងដែរ ព្រោះខ្ញុំភ្លេច ខ្ញុំភ្លាំងអស់ហើយ។ ខ្ញុំមិនសូវដឹងទេ។

**ស៖** តើលោកស្រីធ្លាប់ឮថាមានទេនៅកម្ពុជា ប្រហែលជាគេហៅថា "បក្ស" មានបក្សពីរគឺថា មានបក្សកុម្មុយនីស្តកម្ពុជាពីរ? តើធ្លាប់ឮទេ មួយបដិវត្តន៍ មួយអ្វីទៀត?

**ឆ៖** ខ្ញុំដឹងតែបដិវត្តន៍ ខ្ញុំមិនដឹងបក្សស្អីទេ តែធ្វើបដិវត្តន៍ ដឹង។

**ស៖** ខ្ញុំយល់ ប៉ុន្តែលោកស្រីធ្លាប់ឮពីពូ កែវ មាស ហើយនិងបងប្រុសរបស់លោកស្រីអំពីបក្ស មួយមែនទែន មានតែបក្សទេកុម្មុយនីស្ត គឺមានបក្សពីរដែលពាក់ព័ន្ធជាមួយនឹងបដិវត្តន៍។ តើធ្លាប់ឮ អីចឹងទេ?

**ឆ៖** ខ្ញុំឮដែរ តែវាភ្លេច។ ដល់ភ្លេច ខ្ញុំភ្លេចអស់ហើយ អីចឹងបានខ្ញុំថា ខ្លួនខ្ញុំភ្លេចអស់ហើយ។ ខ្ញុំ មិនសូវចាំទេ។ បើកាលមុន ខ្ញុំចាំ។

**ស៖** ខ្ញុំយល់ គឺថាយូរហើយដែលមិនចាំ។ ប៉ុន្តែលោកស្រីសូមព្យាយាម តើលោកស្រីចាំបានអ្វី ខ្លះ អំពីបក្សផ្សេងទៀត ដែលបងប្រុសហើយនិងពូរបស់លោកស្រីបាននិយាយដែលនោះ? លោកស្រី អញ្ជើញរំឭកបន្តិចមើល។

[១១:២៨:៣១]

**ឆ៖** និយាយៗថាម៉េច? ខ្ញុំមិនដឹងទេ ពេលអីចឹងទៅ។ ខ្ញុំដឹងតែបងខ្ញុំនិយាយប្រាប់ខ្ញុំថា "អញ ចូលបដិវត្តន៍"។ ហើយដល់ពេលអីចឹងទៅ ទាក់ទងគ្នាបានមួយគរគោកមួយគរដីទៅ បានតា សម្តេចតា ឲ្យចូលព្រៃម៉ាគីៗ ខ្ញុំថា អ៊ូ! គេចូលហើយណា គេរត់ចូលអស់ហើយ។ រត់ចូលព្រៃម៉ាគី មិនបានប៉ុន្មាន មកវិញអស់រលីង។ ខ្ញុំដឹងតែប៉ុណ្ណឹង ហើយដល់ក្រោយមកឃើញតែគេសម្លាប់ប្រជាជន។

**ស៖** តើលោកស្រីឮដែរឬទេ ដែលថាបងប្រុស ប្តីលោកស្រី ឬក៏ ចាន់ ចក្រី ឬក៏ ឈូក ឬក៏ កែវ មាស ធ្លាប់បាននិយាយអំពីពីបក្សកុម្មុយនីស្តៗកម្ពុជាពីរគឺ បក្សម៉ាក្ស-ឡេនីន គឺថាមានពីរមិនមែនមាន តែមួយ។ តើលោកស្រីធ្លាប់ឮអីចឹងទេ?

**ឆ៖** ខ្ញុំអត់ដែលឮទេ។ គេមិនដែលប្រាប់ខ្ញុំទេ ព្រោះខ្ញុំជាស្រី ហើយខ្ញុំក្មេង។ ហើយគាត់ប្រុស ហើយគេចាស់ គេចេះ។ ដល់អីចឹងគេអត់ដែលនិយាយជាមួយខ្ញុំទេ អាអីចឹងៗ។

**ស៖** ខ្ញុំនឹងសួរអំពីបងប្រុសលោកស្រី។ សូមលោកស្រីនិយាយអំពីតំណែងខាងយោធារបស់ គាត់ប្រៀបធៀបទៅនឹង ចក្រី ហើយនិងប្រៀបធៀបទៅនឹង ឈូក តើគាត់មានតំណែងខ្ពស់ ឬទាបយ៉ាង ណា និយាយពីបងប្រុសលោកស្រី?

**ឆៈ** ខ្ពស់ដែរ គណបក្ស -- តំបន់។ ខាងតំបន់វាធំបន្តិចហើយ វាមិនតូចទេ។ អើ! កាលនោះគេមានកាំភ្លើងខ្លី កាំភ្លើងអីកាន់ ខ្ញុំមិនដឹងដែរហ្នឹង។ មិនសូវយល់ទេ។

**សៈ** តើលោកស្រីដឹងដែរឬទេ ថាតើ ចាន់ ចក្រី មានឋានៈខ្ពស់ជាងបងលោកស្រី ឬក៏បងលោកស្រីមានតំណែង ឋានៈហ្នឹងខ្ពស់ជាង ចាន់ ចក្រី?

**ឆៈ** បងចក្រី ខ្ពស់ជាងបងខ្ញុំ។ ខ្ពស់ជាងបន្តិច។

[១១:៣១:១៥]

**សៈ** តើលោកស្រីដឹងទេ ថាតើ ចាន់ ចក្រី ហ្នឹងឋានៈខ្ពស់ជាងហ្នឹង ខ្ពស់មួយឋានៈខ្ពស់ជាង ឬក៏ប៉ុន្មានថ្នាក់អាចដឹងបានទេ ដែលថាខ្ពស់ហ្នឹង?

**ឆៈ** វាមិនមែនទៅខ្ពស់អីណានៅលើមេឃទេ តែគ្រាន់ថា ខ្ពស់ដូចថាមួយថ្នាក់ៗអីចឹងណ៎ា គាត់ឡើងបន្តិចៗអីចឹងណ៎ា។ ហ្នឹងគ្រាន់តែប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹង។ ចុះបើមិនអីចឹង ម៉េចបងខ្ញុំហៅបង។

**ប្រធានអង្គជំនុំៈ**

បាទ បានហើយ អរគុណលោកមេធាវី។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និង ឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និង បង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជីៈ**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០១]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ភាគីទាំងអស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ មុនពេលឈប់សម្រាកពិសាបាយថ្ងៃត្រង់ យើងនិយាយពីមនុស្សម្នាក់ដែលជិតដិតជាមួយនឹងលោកស្រី គឺជាបងប្អូនជីដូនមួយឈ្មោះ កែវ មាស។ ឥឡូវនេះខ្ញុំសូមបង្ហាញរូបថតទៅឱ្យលោកស្រីមើល ហើយសួរលោកស្រី តើស្គាល់អ្នក តើរូបថតនេះជា ពិតជារូបថតកែវ មាស ឬក៏មិនមែនទេ?

លោកប្រធាន ព្រឹកមិញនេះ ខ្ញុំតាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់ ខ្ញុំបានសរសេរអ៊ីម៉ែលមួយច្បាប់ដោយផ្តល់ទៅមន្ត្រីច្បាប់ជាន់ខ្ពស់ ពីខ្សែភាពយន្តមួយ វារក -- សរសេរដោយជនជាតិអាល្លឺម៉ង់ ហៅថា "អង្គការ"។ សូមការអនុញ្ញាតពីអង្គជំនុំជម្រះ ចាក់បង្ហាញខ្សែភាពយន្តឯកសារនេះ រយៈពេល២នាទីទេ ប៉ុន្តែដំបូង ខ្ញុំសូមបង្ហាញរូបថតមួយសន្លឹកដែលមាននៅក្នុងខ្សែភាពយន្តនេះ។ សូមអរគុណ។

[១៣:៣៤:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រី ខ្ញុំឃើញលោកស្រីនិយាយនៅពេលដែលក្បាលមីក្រូមិនទាន់បើកនៅឡើយ។ រូបថតដែលខ្ញុំផ្តល់ទៅជូននេះ លោកស្រីស្គាល់ទេ?

**លោកស្រី ស៊ិន ផែម៖**

**ឆ៖** រូបថតហ្នឹង រូបថត ប្រហែលពុកមាត់គាត់ហ្នឹង ប៉ុន្តែគ្រាន់ថាវាមិនច្បាស់ ដល់មិនច្បាស់ វាពិបាកដែរ ខ្ញុំមិនទុកដែរ។ តែគាត់ពុកមាត់អ៊ីចឹង ហើយ*(ឮមិនច្បាស់)*។

**ស៖** ដូច្នេះលោកស្រីមិនច្បាស់មួយរយភាគរយថា ពិតជា កែវ មាស ទេ ឬក៏យ៉ាងណា?

**ឆ៖** ច្បាស់តែពុកមាត់ ហើយនិងចង្ការ ពុកចង្ការ ហើយបើថាភ្នែកថាអី ដូចមិនប្រហែលផង។ ហ្នឹងរូបថតគាត់ច្បាស់ល្អណាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវនេះ លោកប្រធាន ខ្ញុំសុំការអនុញ្ញាតបញ្ចាំងខ្សែភាពយន្តចេញពីភាពយន្តឯកសារគឺ E3/305R ឬក៏ថា E3/719R (សុំកែតម្រូវគឺ R) ភាសាដើមនៃខ្សែភាពយន្តនេះគឺថាជាភាសាអាល្លឺម៉ង់ ដោយសារនេះគឺថា ខ្សែភាពយន្តនេះរៀបរៀងឡើងដោយជនជាតិអាល្លឺម៉ង់ខាងកើតពីរនាក់។ ព្រឹកមិញ ក៏ខ្ញុំបានផ្ញើអ៊ីម៉ែលមួយច្បាប់ទៅមន្ត្រីច្បាប់ជាន់ខ្ពស់ជាមួយនឹងពាក្យជាភាសាអាល្លឺម៉ង់ ហើយនៅខាងក្រោមជាការបកប្រែក្រៅផ្លូវការ។ យើងក៏បានផ្តល់ការបកប្រែក្រៅផ្លូវការនេះទៅឲ្យអ្នកបកប្រែរួចរាល់ហើយដែរ។ ប៉ុន្តែសោកស្តាយថ្ងៃនេះ លោកស្រីចៅក្រម ហ្វេនស៍ គាត់មិនមានវត្តមាន គាត់ស្តាប់ភាសាអាល្លឺម៉ង់បាន។ ហើយទៅខ្ញុំក៏សុំបញ្ចាំងបង្ហាញខ្សែភាពយន្តរយៈពេល២នាទីនេះទៅសាក្សី ពីព្រោះមានពាក់ព័ន្ធនឹង កែវ មាស នេះដែរ។ ដូច្នេះយើងខ្ញុំសុំការអនុញ្ញាតបង្ហាញឯកសារនេះ ជូនទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

មានកំណត់នាទីណាដល់នាទីណាទេ?

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៣:៣៧:៥៥]

**លោក ឌេល លីសាក់៖**

ខ្ញុំចង់ដឹងថាតើមេធាវីការពារក្តី អ្នកបកប្រែយ៉ាងម៉េចដែរ ប្រសិនបើអ្នកបកប្រែបកប្រែអ្វីដែលមេធាវីការពារក្តីទើបតែបានបកពីភាសាអាល្លឺម៉ង់ នោះមិនមែនជាការបកប្រែផ្លូវការទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ភាសាអង់គ្លេស ដែលអ្នកបកប្រែកំពុងមាននៅក្នុងដៃនេះគឺ ថាជាការបកប្រែចេញពីភាសាអាល្លឺម៉ង់ដោយក្រុមការពារក្តីរបស់យើងខ្ញុំ។ ខ្ញុំបានបញ្ជាក់ហើយថា ការបកប្រែចេញទៅជាភាសា

អង់គ្លេស ដោយក្រុមយើងខ្ញុំនេះគឺថា មិនជាផ្លូវការទេ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែដាក់នាទីណាមួយច្បាស់លាស់ដើម្បីយើងឲ្យអនុញ្ញាតឲ្យធ្វើដូច្នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺពីនាទី១៣:៣១ ដល់១៥:៤៩ គឺថាមានរយៈពេល២នាទី ១៨វិនាទី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយផ្នែកខាងសោតទស្សន៍ចាក់ផ្សាយនូវខ្សែវីដេអូ ឃ្លីបវីដេអូដែលតាមសំណើសុំរបស់មេធាវីការពារក្ដីលោក នួន ជា។

[១៣:៣៩:៤៦]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"...បក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាង មហាអស្ចារ្យ។ ការងើបឡើងរបស់ និងធ្លាក់ចុះទៅវិញរបស់ ប៉ុល ពត គឺជារឿងមួយនៃសង្គ្រាមប្រយុទ្ធគ្នាដែលមិនអាចយោគយល់គ្នាបាននៅក្នុងបក្សតែមួយ។ ជំហរម៉ាក្ស-ឡេនីន និងជំហរអន្តរជាតិ នេះបើយោងទៅតាមទំនៀមទម្លាប់របស់ពួកគេប្រឆាំងទៅនឹងក្រុមបិសាចដែលព្យាយាមបន្ទុបឡើងដោយពួកអនុត្តរភាពប៉េកាំងនៅក្នុងប្រទេសកម្ពុជា។ យើងអាចប៉ាន់ស្មានថា អ្វីដែលកើតឡើងចំពោះបុរសទាំងអស់នោះ គឺមានបង្ហាញនៅក្នុងតួនាទីឋានៈរបស់គេ។ តើគាត់នឹងត្រូវបាន ប៉ុល ពត ដាក់ច្រវាក់ ឬក៏គាត់លាក់ខ្លួនហើយរួចហើយ នឹងយកកាំភ្លើងរបស់គាត់មកភ្ជង់ ប៉ុល ពត។ រហូតមកដល់ឆ្នាំ១៩៧៥ នៅក្នុងអំឡុងពេលសង្គ្រាមប្រយុទ្ធប្រឆាំងជាមួយនឹងពួកចក្រពត្តិដើម្បីរំដោះមូលដ្ឋានមួយចំនួននោះគឺថា មិនទាន់លេចជាពន្លឺទេនៅពេលនោះ។ ហើយរយៈពេលពិតប្រាកដ គឺត្រូវបានគ្របដណ្ដប់ទៅដោយគោលបំណងមួយក្នុងការធ្វើម៉េចបង្រួបបង្រួមប្រជាជនកម្ពុជាភាគច្រើន។ ប៉ុន្តែ ប៉ុល ពត ក៏បានធ្វើទៅតាមផែនការនៅក្នុងទ្រង់ទ្រាយធំ។ នៅពេលនោះ គឺថាប្រធានរំដោះជាតិ សឺង ង៉ុកថាញ់ ក៏បានត្រឡប់មកវិញ ហើយគាត់បានចូលរួមនៅបាយល្ងាចមួយដែលរៀបរៀងឡើងដោយពួកក្រុមចិន។ ហើយគាត់បានស្លាប់នៅក្នុងប្រទេស -- ទីក្រុងប៉េកាំង។..."*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៣:៤២:០៧]

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់លោក វ៉ិចទ័រ កូប៉េ!

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ សម្រាប់ជាប្រតិចារឹក តើលោកដឹងថាឯកសារនេះត្រូវបានថតឡើងនៅពេលណាទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

តាមដែលខ្ញុំយល់ គឺខ្សែភាពយន្តនេះត្រូវបានផលិតឡើងនៅក្នុងឆ្នាំ១៩៨១ ដោយជនជាតិអាល្លឺម៉ង់ខាងកើត ក្រោយពេលវៀតណាមចូលមកកាន់ប្រទេសកម្ពុជា គឺស្ថិតជាឯកសារខ្សែភាពយន្តសរសេរជាភាសាអាល្លឺម៉ង់។ នេះគឺជាសម្រង់ភាពយន្តដើមហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីតាំងសំណួរដេញដោលចំពោះសាក្សី!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី លោកស្រីមានឃើញខ្សែភាពយន្តដែលទើបតែបញ្ចាំងជូនអម្បាញ់មិញទេ?

**លោកស្រី ស៊ិន ផែម៖**

**ឆ៖** ខ្ញុំមិនដែលបានទៅមើលទេ ព្រោះគ្មានមនុស្សចាំផ្ទះ មានតែកូនចៅគេទៅអស់ៗ មិនដែលបានទៅណាទេ។

[១៣:៤៤:០០]

**ប្រធានអង្គជំនុំ៖**

សូមតាំងសំណួរសាជាថ្មីម្ដងទៀត។

លោកសាក្សីចាំស្ដាប់សំណួរឲ្យបាន។ សំណួរហ្នឹងគឺចង់បញ្ជាក់រឿងបញ្ហាខ្សែភាពយន្តដែលបានបង្ហាញ បញ្ចាំងលើកញ្ចក់ទូរទស្សន៍នៅមុខលោកស្រីអម្បាញ់មិញនេះ។ សួរពាក់ព័ន្ធនឹងបញ្ហាហ្នឹងទេ មិនមែនសួរពាក់ព័ន្ធនឹងបញ្ហាថាតើលោកស្រីធ្លាប់ទៅមើលកុន មើលអីពីដើមនោះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី ឥឡូវនេះនៅលើអេក្រង់នេះ អេក្រង់កុំព្យូទ័រអម្បាញ់មិញនេះ បញ្ចាំងភាពយន្តរយៈពេល២នាទី លោកស្រីបានឃើញទេមុនហ្នឹង?

**លោកស្រី ស៊ិន ផែម៖**

**ឆ៖** ឃើញៗក្នុងទូរទស្សន៍។ ឃើញដែរ។

**ស៖** ហើយនៅចុងបញ្ចប់នៃខ្សែភាពយន្តនេះ ក៏មានរូបថតដែលលោកស្រីបានឃើញរូបថតរបស់មនុស្សម្នាក់ទេអម្បាញ់មិញហ្នឹង?

**ឆ៖** រូបថតពីណា រូបថតប្ដីខ្ញុំហ្នឹងឯង។ តែមករូបថតពីណាៗ ខ្ញុំមិនស្គាល់ទេ មិនដឹងទេ។

**ស៖** លោកស្រីស្គាល់មនុស្សពីរនាក់ដែលបានឃើញនៅផ្នែកចុងក្រោយ គឺប្ដីរបស់លោកស្រី ហើយនិងមនុស្សពីរនាក់ទៀត ឯមនុស្សពីរនាក់ផ្សេងទៀតហ្នឹងលោកស្រីស្គាល់ទេ អំមិញហ្នឹង?

**ឆ៖** ពីណាមួយ ខ្ញុំមិនស្គាល់ដែរ ខ្ញុំមិនចាំដែរ។ ប្រាប់ឈ្មោះខ្ញុំ ខ្ញុំស្គាល់ ខ្ញុំដឹង។ ខ្ញុំវាភ្លេចអស់ហើយ។

[១៣:៤៥:៥៨]

**ស៖** ម្នាក់ឈ្មោះ សឹង ង៉ុកមិញ។

**ឆ៖** ង៉ុកមិញ ខ្ញុំមិនដែលឃើញទេ ពួកគេនោះ។

**ស៖** ហើយចុះម្នាក់ទៀត ឈ្មោះ កែវ មុនី ស្គាល់ទេ?

**ឆ៖** កែវ មុនី ក៏ខ្ញុំមិនបានស្គាល់ដែរ។

**ស៖** សំណួរមួយចុងក្រោយពាក់ព័ន្ធទៅនឹងខ្សែភាពយន្តនោះ។ ពីខាងដើមមកគឺថា បានមានការបកប្រែក្រៅផ្លូវការ គឺដូចតទៅ ខ្ញុំសូមដកស្រង់ ការបកប្រែរបស់ខ្ញុំផ្ទាល់៖ "ការងើបឡើង និងការធ្លាក់ទៅវិញរបស់ ប៉ុល ពត នេះគឺជារឿងមួយនៃសង្គ្រាមប្រយុទ្ធគ្នាមិនអាចអនុគ្រោះបាននៅក្នុងបក្សតែមួយ។ ការប្រកាន់ជំហរ ម៉ាក្ស-ឡេនីន និងជំហរអន្តរជាតិ នេះបើយោងទៅតាមទំនៀមទម្លាប់របស់គេគឺវាប្រឆាំងទៅនឹងពួកបិសាច ដែលព្យាយាមបន្តុបក្រុមពួកអនុត្តរភាពប៉េកាំង នៅក្នុងប្រទេសកម្ពុជា។" បញ្ចប់ការដកស្រង់។ លោកស្រីសាក្សី លោកស្រីធ្លាប់ឮសូរការប្រយុទ្ធគ្នារវាងសមាជិកនៅក្នុងបក្សតែមួយដែរទេ?

**ឆ៖** ហ្នឹងខ្ញុំ អើវាៗដឹងៗដែរ ប៉ុន្តែវាភ្លេច។ ដល់អីចឹងខ្ញុំមិនដឹងថាម៉េចទេ ភ្លេចអស់ហើយ។ ខ្ញុំ

ថាខ្ញុំនិយាយមិនកើតទេ ព្រោះខ្ញុំភ្លេចភ្លាំងអស់ហើយ។

[១៣:៤៨:១៩]

**ស៖** ឥឡូវខ្ញុំសូមអានសម្រង់មួយចំនួនទៀត ក្រែងលោថាអាចជួយរំឭកដល់ការចងចាំ។ ឥឡូវនេះ ខ្ញុំសូមអានសម្រង់ខ្លីគឺឯកសារE3/5309, ERNជាភាសាខ្មែរ 00388327, អង់គ្លេស 00426128, បារាំង 00479776។ នេះ គឺជាកិច្ចសម្ភាសន៍របស់មនុស្សម្នាក់ឈ្មោះ ហេង ទាវៗ។ ហេង ទាវ គឺថាមានតួនាទីខ្ពស់ណាស់នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៨៤, ៨៥ ហើយនិងលេខាតំបន់មួយទៀតឈ្មោះ តាប៉ែត ឬក៏ តាកន្ទុល។ ខ្ញុំសូមដកស្រង់៖ "ក្រោយ ១៧ មេសា ១៩៧៥ អ្នកណាជាអ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅខាងក្រៅ? ហើយអ្នកណាដែលមើលឃើញថាជាមេដឹកនាំបក្ស ប៉ុល ពត ឬក៏អ្នកណាឲ្យពិតប្រាកដនោះ? ហើយចម្លើយថា៖ មានពីរផ្នែក មួយផ្នែកគឺជាបក្សកុម្មុយនីស្តកម្ពុជា។ មួយផ្នែកទៀត គឺបក្សរបស់យើងដឹកនាំដោយ សឹង ង៉ុកមិញ ហើយនៅក្នុងប្រទេសមិនមែនដឹកនាំដោយ ប៉ុល ពត ទេ គឺដឹកនាំ ទូ សាមុត។" លោកស្រីទើបតែនិយាយពី -- បើខ្ញុំនិយាយពី សឹង ង៉ុកមិញ លោកស្រីនឹកឃើញទេ? លោកស្រីធ្លាប់ដែលឮពូរបស់លោកស្រី កែវ មាស និយាយអំពីថា ពេលនោះ មានបក្សកុម្មុយនីស្តពីរ លោកស្រីដែលធ្លាប់ឮពូរបស់លោកស្រីនិយាយពីរឿងនេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ឃើញថាសម្រង់ដែលយកមកសួរសាក្សីនេះ គឺថាមេធាវីការពារក្តីហាក់បីដូចជាសួរនាំមុខហើយ ពីព្រោះសាក្សីដែលបានឆ្លើយនោះគឺថាឆ្លើយថា សឹង ង៉ុកមិញ ស្លាប់តាំងពីឆ្នាំ១៩៧២ឯណោះ។ ដូច្នេះគាត់មិនអាចមកដឹកនាំបក្សនៅក្នុងឆ្នាំ១៩៧៥ទេ។ ហើយនៅពេលដែលនិយាយអំពី ទូ សាមុត វិញគឺជាពេលវេលាមួយផ្សេងទៀតហើយ។ ដូច្នេះយើងខ្ញុំសូមជំទាស់ថាសម្រង់ដែលយកមកសួរនេះ គឺវាខុសពេលវេលាគ្នាឆ្ងាយណាស់ គឺពេលវេលាពាក់ព័ន្ធទៅនឹង សឹង ង៉ុកមិញ នេះឯង។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំដឹងហើយថា ទូ សាមុត គឺថាត្រូវបានគេសម្លាប់តាំងពីឆ្នាំ១៩៦២ ប្រហែលជា

ដោយរបប សីហនុ ហើយ សឺង ង៉ុកមិញ ខ្ញុំដឹងថាគាត់ស្លាប់នៅក្នុងឆ្នាំ១៩៧២។ ប៉ុន្តែចលនាវាតមករហូតដល់ឆ្នាំ៧៥ ដែលមានបក្សកុម្មុយនីស្តកម្ពុជាដល់ពីរកាលហ្នឹង មួយសកម្មនៅក្នុងស្រុក ហើយមួយទៀតជាបក្សរបស់គាត់ហ្នឹង គឺថាដឹកនាំដោយ សឺង ង៉ុកមិញ។ ហើយមនុស្សដែលមានឋានៈទី២នៅភូមិភាគពាយ័ព្យ គឺថាមានតួនាទីខ្ពស់ណាស់ រហូតមកដល់ឆ្នាំ១៩៨៥, ៨៦ ទើបស្លាប់ទៅក្នុង--។ ដូច្នេះយើងខ្ញុំគួរតែត្រូវបានអនុញ្ញាតឲ្យសួរសំណួរទាំងនេះ ទៅកាន់សាក្សី។

[១៣:៥២:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៤:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសម្រេចលើការជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិ លើការតាំងសំណួរចុងក្រោយរបស់មេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះយល់ឃើញថា សំណួររបស់មេធាវីការពារក្តី នួន ជា ត្រូវតែបដិសេធចោល ដោយសារតែវាពាក់ព័ន្ធទៅនឹងរយៈពេលមុនសម័យកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះវាមិនពាក់ព័ន្ធនឹងរយៈកាលនៃការជំនុំជម្រះក្តីយើងទេ។ ហើយសំណួរនេះធ្វើឲ្យមានការភ័ន្តច្រឡំទៀត។ ដូច្នេះយើងហាមមិនឲ្យសួរសំណួរនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកចៅក្រម ឡាវែន៍ សំណួរច្បាស់ហើយ គឺថាវាពិតមិន -- វាមិន -- ឆ្ងាយពីឆ្នាំ១៩៧៥ ហើយខ្ញុំនឹងសួរសំណួរស្រដៀងៗគ្នា។

[១៣:៥៦:០១]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នេះ គឺជាសម្រង់ចេញពីសាក្សីដែលមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០៥ តុលា ឆ្នាំ២០១៥នេះ និងសាក្សីម្នាក់ទៀតនៅថ្ងៃទី០៦ តុលា ដែលជាសក្ខីកម្មរបស់លេខាស្រុក ដែលសាក្សីរូបនេះនិយាយអំពីបក្សពលករ។ ខ្ញុំសូមអានសម្រង់នេះឲ្យសាក្សីស្តាប់ គឺឯកសារ E1/354.1 នៅ

ម៉ោង០៩:៣៤នាទីព្រឹក។ “សួរ៖ តើលោកដឹងថាគេបង្កើតបក្សពលករកម្ពុជាទេ? កែ ពក គឺជាសមាជិកបក្សពលករកម្ពុជា ហើយក្រោយមកក៏ចូលបក្ស រួមបក្សជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា ដែលគេបង្កើតឡើងតាំងពីឆ្នាំ១៩៦៨។ ដូច្នេះ ប៉ុល ពត ក៏បានចាកចេញទៅចូលជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា ហើយតាមដែលខ្ញុំដឹង នៅតំបន់របស់ខ្ញុំមានកម្មាភិបាលខ្មែរដែលបណ្តុះបណ្តាលដោយវៀតណាម ដែលជាសមាជិករបស់បក្សពលករកម្ពុជា ហើយក្រោយមកគេបញ្ជូនមកដើម្បីឱ្យមកកសាងពង្រឹងកម្លាំងរបស់ខ្លួននៅក្នុងមូលដ្ឋាន។ មានចៅហ្វាយស្រុកម្នាក់មកពីភូមិភាគឧត្តរនិយាយអំពីការដែលមានបក្សពីរនៅក្នុងចលនាបដិវត្តន៍ មួយហៅថាបក្សកុម្មុយនីស្តកម្ពុជា មួយទៀតហៅថាបក្សពលករកម្ពុជា។” លោកស្រីធ្លាប់ដែលឮឈ្មោះបក្សពលករកម្ពុជាទេ?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** ខ្ញុំមិនដែលឮទេ។ ខ្ញុំដឹងតែមួយកំណាត់មកក្រោយទេ ឯលើៗខ្ញុំអត់ដឹងទេ។ ដឹងតែត្រង់ដែលគេសម្លាប់ប្រជាជន ហើយខ្ញុំដឹងទាំងអស់។

**ស៖** ខ្ញុំព្យាយាមសួរលោកស្រីម្តងទៀត គឺពាក់ព័ន្ធទៅនឹងឯកសារចុះខែសីហា ១៩៧៩ ឯកសារ E3/7327, ERN ជាភាសាខ្មែរ 0011375*(ស៊ីក)*, ERN ជាភាសាអង់គ្លេសមិនច្បាស់។ លោកប្រធានឯកសារនេះគឺឯកសារចេញមកអំពីតុលាការបដិវត្តន៍ប្រជាជនកម្ពុជា ដែលផ្តន្ទាទោសបនប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី។ អ៊ីចឹងឯកសារនេះ ជាឯកសារដែលបានមកពីតុលាការកាលពេលនោះ។ លោកសាក្សី នៅខាងលើនេះគឺនិយាយអំពីការស្វាគមន៍ គឺឯកសារចុះខែមិថុនា ១៩៧៨ បុរសកំពូលរបស់បក្សពលករកម្ពុជា ទី១ ឈ្មោះ សោ ភឹម ជាលេខារបស់បក្សពលករកម្ពុជា ដែលបានធ្វើអត្តឃាតនៅខែមិថុនា ១៩៧៨។ លេខ២ តាញឹម គឺថាអនុលេខាបក្ស ដែលត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៨ និងលេខ៣ កែវ មាស ត្រូវបានចាប់ខ្លួននៅខែកញ្ញា – ២១ កញ្ញា ១៩៧៦។ ដូច្នេះលោកស្រី បងប្អូនជីដូនមួយលោកស្រីដែលជិតដិតនឹងលោកស្រីគឺ កែវ មាស នេះមានឋានៈលេខ៣នៅក្នុងជួរបក្សពលករកម្ពុជា។ លោកស្រីធ្លាប់ដឹងរឿងនេះទេ ឬក៏លោកស្រីមិនធ្លាប់ដឹងទេ?

[១៤:០០:៣៦]

**ឆ៖** ខ្ញុំមិនបានដឹង សោ ភឹម សោអី ខ្ញុំមិនដឹងទេ មិនសូវដឹងទេ។ ដឹងមកតែខាងក្រោយ ឯមកខាងសម្លាប់មនុស្ស ខ្ញុំដឹង។ តែមុនៗ ព្រោះគេប្រុសៗ គេត្រូវការ គេមិនដែលនិយាយជាមួយខ្ញុំទេ។

**ស៖** ខ្ញុំយល់ហើយលោកស្រី។ ឥឡូវខ្ញុំនិយាយពីបងប្អូនជីដូនមួយលោកស្រី កែវ មាស ម្តង

ទៀត គឺឯកសារ E3/1684 ជាសម្រង់ចេញពីសៀវភៅរបស់ ដេវីដ ឆេនដ៍ល័រ ERN ជាភាសាអង់គ្លេស 00192--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន។ មេធាវីអានញាប់ពេក។

**ប្រធានអង្គជំនុំ៖**

មេធាវីអានលេខឯកសារសាជាថ្មីម្តងទៀត។ អានរង្វើលៗ យឺត រង្វើលៗបានហើយ អ្នកបកប្រែបកអត់ទាន់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ លោកប្រធាន។ ឯកសារ E3/1684 ជាសៀវភៅរបស់ ដេវីដ ឆេនដ៍ល័រ និយាយអំពី ស-២១, ERN ជាភាសាអង់គ្លេស 00192733, ខ្មែរ 00191890, បារាំង 00357321។ ឥឡូវខ្ញុំសុំអានសម្រង់ ហើយនិងសួរលោកស្រីមើលពាក់ព័ន្ធទៅនឹងជីដូនមួយរបស់លោកស្រី កែវ មាស នេះ។ លោក ដេវីដ ឆេនដ៍ល័រ បានសរសេរថា គាត់ជាមួយនឹង នង សួន គឺថាបានធ្វើប្រតិបត្តិការបើកមុខតែម្តង ចំហាតែម្តងក្នុងទសវត្សរ៍៥០។ គាត់គឺជាសមាជិករដ្ឋសភា។ លោកស្រីនៅនឹកឃើញទេបងប្អូនជីដូនមួយលោកស្រីនេះ គឺថាបានចូលរួមនៅក្នុងរឿងនយោបាយ ហើយបានឈរឈ្មោះជាតំណាងរាស្ត្រពីរដង លោកស្រីនៅចាំទេ?

[១៤:០៣:១៨]

**លោកស្រី ស៊ិន ផែម៖**

**ផ៖** ខ្ញុំមិនបានដឹងទេរឿងហ្នឹង ខ្ញុំអត់ដឹងអីសោះ។ *(ឮមិនច្បាស់)* មិនដឹងទេ ព្រោះគាត់ក៏មិនសូវដែលនៅផ្ទះ ប៉ុន្តែគាត់ពីដើម ពីសង្គមឪគាត់មេស្រុក។ ដឹងតែប៉ុណ្ណឹងទេ ដឹងតែប៉ុណ្ណឹង។

**ស៖** ប៉ុន្តែលោកស្រីនឹកឃើញ និងធ្លាប់បានដឹងថាគាត់បានចូលរួមក្នុងបញ្ហានយោបាយ ហើយព្យាយាមឈរឈ្មោះជាតំណាងរាស្ត្រពីរដងនៅក្នុងទសវត្សរ៍៦០?

**ផ៖** ខ្ញុំអត់បានដឹង ខ្ញុំមិនដឹងគាត់ទេ ព្រោះនៅខ្ញុំនៅក្មេងកាលនុ៎ង។

**ស៖** តើលោកស្រីដឹងដែរឬទេ ថាតើ កែវ មាស នៅក្នុងឆ្នាំ១៩៧០ ទសវត្សរ៍ឆ្នាំ៧០ គាត់ធ្វើការនៅប៉េកាំង នៅហាណូយ នៅក្នុងនាមរាជរដ្ឋាភិបាលរួបរួមជាតិដែលនៅក្រៅប្រទេសកាលនោះ?

**ផ៖** គាត់មិនដែលទៅនៅដល់នុ៎ងទេ។ គាត់នៅតែភ្នំពេញ បងខ្ញុំទៅមកៗ។

**ស៖** ខ្ញុំចាំថាលោកស្រីបានឱ្យចម្លើយនេះមុនពេលសម្រាក ប៉ុន្តែលោកស្រីប្រាកដហើយថា គាត់មិនដែលធ្វើការនៅក្នុងប្រទេសចិន ឬក៏ប្រទេសវៀតណាមទេ ក្នុងនាមរណសិស្សរួបរួមជាតិកាលនោះ? លោកស្រីប្រាកដថាអ៊ីចឹង?

[១៤:០៥:១៥]

**ឆ៖** ចាស មិនដែលទេ។ គាត់នៅតែភ្នំពេញមែន ត្រង់ផ្សារស្ពឺគេទេ។ ខ្ញុំវាភ្លេចផ្សារហ្នឹងទៅ។ បងខ្ញុំទៅមកៗ ជួបរាល់តែថ្ងៃ។ ធ្វើម៉េចខ្ញុំមិនដឹង។

**ស៖** ហើយក៏បាននិយាយដែលថា នៅក្នុងឆ្នាំ១៩៧៥ គាត់មកប្រទេសកម្ពុជាវិញ គេឃុំខ្លួនគាត់ក្នុងផ្ទះ។ តើលោកស្រីនៅចាំដែរឬទេ លោក កែវ មាស នោះដែលនិយាយប្រាប់លោកស្រីថា គេឃុំខ្លួនគាត់ក្នុងផ្ទះទេ ពេលដែលគាត់មកវិញ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ រឿងឃុំនៅក្នុងផ្ទះនុ៎ង តែឮតែថាគាត់ជម្លៀសចេញពីកន្លែងភ្នំពេញហ្នឹង គាត់ទៅនៅឯណាទេ។ ហើយដល់ពេលអ៊ីចឹងស្រាប់តែគេរកឃើញ គេចាប់បានសម្លាប់ចោលទៅ ទាល់ឥឡូវទៅ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** យើងមានភ័ស្តុតាងថា គេបានចាប់ខ្លួនគាត់នៅខែកញ្ញា ឆ្នាំ១៩៧៦។ តើលោកស្រីដឹងទេ មុនពេលដែលគេចាប់ខ្លួនគាត់ គេបានដាក់ឃុំខ្លួនគាត់នៅក្នុងផ្ទះ? មានន័យថា គេឱ្យគាត់នៅតែក្នុងផ្ទះទេ អត់ឱ្យទៅណាទេ នៅទីក្រុងភ្នំពេញ។ តើលោកស្រីធ្លាប់បានឮអ៊ីចឹងដែរឬទេ?

[១៤:០៦:៥១]

**ឆ៖** ខ្ញុំបានឮតែអ៊ីចេះ បានឮថា គាត់ចេញ ជម្លៀសចេញពីផ្ទះ ហើយគេតាមរកឃើញ នៅតែរកឃើញ យកមកសម្លាប់ចោលទៅ។ ហ្នឹងខ្ញុំដឹងអ៊ីចឹង តែប៉ុណ្ណឹងទេ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់ផ្នែកមួយផ្សេង។ ហើយយើងបញ្ចប់រឿង កែវ មាស ទៅអ្នកផ្សេងទៀតដែលយើងបានជជែកពីខាងដើម។ យើងនិយាយពី ឈូក ហើយនិង ចក្រី។ ជាពិសេស លោកប្រធាន ខ្ញុំយើងទៅរកឯកសារ E3/13 ឯកសារចុះថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៦ កំណត់ហេតុនៃអង្គប្រជុំកងពល ហើយនិងកងវរសេនាតូច។ ហើយនៅក្នុងកំណត់នេះ សុន សេន និយាយទៅកាន់យោធាដែលវត្តមាន ហើយមេបញ្ជាការនៅកងពលផ្សេងៗទៀតដែលវត្តមានកាលនោះ ជាពិសេសគឺគាត់និយាយអំពីទំព័រខ្មែរ 00052406, អង់គ្លេស 00940343, បារាំង 00334946។ ហើយនិយាយទៅមេបញ្ជាការ៖ "ខ្មាំងនៅបូព៌ា មនុស្សសំខាន់នោះគឺវៀតណាម ហើយដែលមានសូវៀតនៅពីខាងក្រោយ

ដែលវាយប្រហារ ដោយមានគាំទ្រនូវខ្មាំងបង្កប់ខាងក្នុងមាន យ៉ា, មាន ឈូក, មាន ចក្រី។ អ្នកដែលវាយប្រហារនៅខាងក្រៅ ខ្មាំងខាងក្រៅហ្នឹងគឺ មានឆេកូស្លូវ៉ាគី ហើយនិងអង់ហ្គោឡា។ នេះគឺជាការគាំទ្រខាងផ្លូវចិត្ត ផ្លូវសីលធម៌ប៉ុណ្ណោះ ពីព្រោះគេមិនអាចធ្វើអ្វីបានទេ។” បញ្ចប់សេចក្ដីដកស្រង់។ តាមពិតលោកស្រីសាក្សី គឺមិនបានវត្តមាននៅការប្រជុំជាមួយ សុន សេន នោះទេ ប៉ុន្តែគឺថាគេនិយាយយោងទៅរកផែនការរបស់ខ្មាំងភូមិភាគបូព៌ា ដែលវាយប្រហារកម្ពុជា ដែលមនុស្សបួនរូបដែលគេបញ្ជាក់ឈ្មោះច្បាស់នោះ គឺដែលថាលោកស្រីស្គាល់ពីរ ឬបីក្នុងចំណោមនោះ លើកលែងតែឈ្មោះ យ៉ា ទេ ដែលជាប្រធានភូមិភាគឧត្តរ -- ភូមិភាគឦសាន យ៉ា នោះ គឺថាក្រៅផ្សេងទៀត ឈូក, ចក្រី និង កែវមាស គឺថាលោកស្រីស្គាល់ ដែលថាគេមានផែនការមកពីភូមិភាគបូព៌ាជាមួយនឹងវៀតណាម ដើម្បីវាយប្រហារកម្ពុជាប្រជាធិបតេយ្យ។ តើលោកស្រីធ្លាប់បានឮ ឬក៏ដឹងអំពីរឿងនេះដែរឬទេ?

[១៤:១០:២២]

**ឆ៖** បានដឹង បានឮដែរ តែខ្ញុំវាភ្លេចៗអស់ហើយ។ ខ្ញុំតែងតែចាំបានតែបួន មើល! បងចក្រី ហើយនិង តាឈូក ព្រោះ តាឈូក គាត់មកផ្ទះខ្ញុំ ទៅមកៗ រាប់អានបងខ្ញុំ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** តើលោកស្រីដឹងទេ តើពួកគេពិភាក្សារឿងអ្វីខ្លះ?

**ឆ៖** គ្មានពីណាគេឲ្យខ្ញុំដឹងទេ ស្រីៗនោះ ដេកជំនុំតែគ្នាគេប្រុសៗនោះ។ រឿងអីចឹងៗ គេមិនអាចជំនុំបានទេ។

**ស៖** ខ្ញុំយល់ហើយ។ តើលោកស្រីមិនធ្លាប់ឮអ្វីៗទាល់តែសោះ តើធ្លាប់ឮពួកគាត់និយាយអំពីផែនការសម្លាត់អ្វីដែរឬទេ?

**ឆ៖** ផែនការសម្លាត់ក៏គេមិនដែលប្រាប់អីខ្ញុំដែរ គេមិនដែលនិយាយទេ។ គេទៅនិយាយធ្វើអី ព្រោះខ្ញុំស្រីៗ គេថាស្រីមាត់ដាច មិនបានទេ។

**ស៖** ខ្ញុំនឹងយោងទៅរក ទៅអ្វីដែលលោកស្រីឆ្លើយប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/7526 មានតែខ្មែរ និងបារាំងទេ។ បារាំងទំព័រERN 00746949, ខ្មែរ 00185371។ លោកស្រីបាននិយាយអំពីបងប្រុសរបស់លោកស្រី នៅចំណុចមួយគេសួរសំណួរថា អំពី ចាន់ ចក្រី។ ហើយលោកស្រីស្ដាប់ខ្ញុំ ខ្ញុំអានចម្លើយហ្នឹងជាភាសាបារាំង។ អ្នកសួរសួរលោកស្រីដូចខាងក្រោមនេះ៖ “តើលោកស្រីធ្លាប់ឮគេនិយាយអំពី ចាន់ ចក្រី ទេ? ពេលនោះលោកស្រីឆ្លើយថា៖ បាទ ខ្ញុំធ្លាប់ឮ ប៉ុន្តែខ្ញុំមិនដែលឃើញ ចាន់ ចក្រី នេះទេ។ បងខ្ញុំនិយាយអំពី ចាន់ ចក្រី នេះ។ សួរ៖ តើបងរបស់លោកស្រី

និយាយអ្វីខ្លះអំពី ចាន់ ចក្រី? លោកស្រីឆ្លើយថា៖ គាត់ប្រាប់ខ្ញុំថា ចាន់ ចក្រី នេះនឹងមកជួបយើងនៅពេលក្រោយ។” តើលោកស្រីនៅចាំថា បាននិយាយឆ្លើយបែបនេះ និយាយអំពីបងប្រុសលោកស្រីនិយាយប្រាប់លោកស្រីថា ក្រោយមក ចាន់ ចក្រី មកជួបនឹងបងប្រុសរបស់លោកស្រី?

[១៤:១៣:៣៩]

**ឆ៖** បានគាត់និយាយដែរ គាត់និយាយថា ចាន់ ចក្រី ហ្នឹងពួកម៉ាក់គាត់ គាត់ថាអ៊ីចឹងអ្ន។ ពួកម៉ាក់ មិត្តភក្តិស្រឡាញ់គ្នាណាស់ ថាអ៊ីចឹង។ អើ!គាត់បាននិយាយតែប៉ុណ្ណឹង ហើយខ្ញុំក៏មិនដឹងស្អីដែរ ព្រោះខ្ញុំវានៅក្មេង វាមិនដឹងខ្យល់អីទេ។

**ស៖** ដូច្នេះលោកស្រីមិនដឹង ថាតើបងប្រុសរបស់លោកស្រីហ្នឹង ហើយនិង ចាន់ ចក្រី, ឈូក ហើយនិង កែវ មាស មិនដឹងថា គាត់ធ្វើអី ផែនការអី មិនដឹងទេ អ៊ីចឹងឬ? ខ្ញុំដកសំណួរមកវិញ ប៉ុន្តែខ្ញុំនឹង អ៊ីចឹងគឺថាខ្ញុំនឹងប្តូរសំណួររបស់ខ្ញុំ ធ្វើឲ្យលឿនជាងនេះ លោកប្រធាន។ សុន សេន គឺថានៅក្នុងឯកសារដដែលដែលខ្ញុំបានយោងនោះ គឺគាត់បាននិយាយអំពីហេតុការណ៍ដែល ចក្រី បានធ្វើសកម្មភាពជាមួយអ្នកផ្សេងទៀត គឺហេតុការណ៍ដែលគេបាញ់កាំភ្លើងនៅសាលាជិតសាលាវិចិត្រសិល្ប ហើយគេគប់គ្រាប់បែកនៅជិតវាំង ហើយនៅដើមឆ្នាំ ខែមេសា ឆ្នាំ១៩៧៦ គឺគេបានគប់គ្រាប់បែកម្តងទៀត។ តើលោកស្រីធ្លាប់ឮអំពីការគប់គ្រាប់បែក ដែលថាគេបាញ់អាវុធ ឬក៏បាញ់កាំភ្លើងនៅសាលារចនា ឬក៏សាលាវិចិត្រសិល្បៈនៅជិតវាំងដែរឬទេ?

[១៤:១៥:២៥]

**ឆ៖** ខ្ញុំមិនបានដឹងបានឮទេ អ៊ីចឹងៗអី ខ្ញុំមិនដឹងដែរ។ តែខ្ញុំដឹងអី ខ្ញុំដឹងត្រង់ ត្រឹមអីគេរើប្រជាជន ខ្ញុំដឹង តែពីមុនៗមកខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំសូមផ្តល់នូវព័ត៌មានលម្អិតផ្សេងទៀតអំពីហេតុការណ៍នៅដើមឆ្នាំ១៩៧៦។ លោកប្រធាន ខ្ញុំយោងទៅសៀវភៅ លោក ដេវីដ ឆេនដ៍ល័រ សៀវភៅពី ស-២១ គឺ E3/1684 ទំព័រអង់គ្លេស៥៤ អង់គ្លេស ERN 00192731, ខ្មែរ 00191888, បារាំង 00357319។ គាត់សរសេរដូចខាងក្រោមនេះ លោកស្រីសាក្សី គាត់សរសេរថា៖ “បីថ្ងៃក្រោយមកគឺថ្ងៃ ខែមេសា គឺថាមុនព្រលប់បន្តិចគឺថា គេគប់គ្រាប់បែកនៅមុខវាំង ហើយគេបាញ់កាំភ្លើងនៅជិតសាលារចនាភ្នំពេញ។ (ហើយនៅខាងក្រោម) ជនសង្ស័យគឺស្ថិតនៅក្នុងកងពល១៧០ ហើយដែលជាកងទ័ពបង្កើតឡើងក្រោយឆ្នាំ១៩៧៥ ហើយស្ថិតនៅក្នុងកងពលនៅភូមិភាគបូព៌ា សល់ពីសង្គ្រាមត្រជាក់មក។ កងពលនេះ គឺស្ថិតនៅខាងក្រៅតំបន់ភ្នំពេញ

ដែលឃោធា ដែលត្រូវបានគេចាត់តាំងឲ្យធ្វើស្រែ។ ការសង្ស័យក្រោយមក គឺគេសង្ស័យទៅលើ ចាន់ ចក្រី ដែលជាមនុស្សសំខាន់នៅក្នុងកងទ័ពភូមិភាគបូព៌ា ហើយគាត់ធ្លាប់បួសជាព្រះសង្ឃ ហើយគាត់ធ្វើជាស្នងការឃោធា។ ដោយសារមានការចាប់ខ្លួន ចក្រី ហើយ ល្វៃ ក៏ជាលេខាកងពល១៧០ ហើយ ចក្រី គឺក៏បានឆ្លើយទៅដាក់ ពេញ ដែលថាជាស្នងការកងពល១៧០ដែរ។ ហើយ សួស នៅ ហៅ ឈូក លេខានៅក្នុងតំបន់២៤ នៅភូមិភាគបូព៌ា ត្រូវបានចាប់ខ្លួនខែមិថុនា ឆ្នាំ១៩៧៩ ហើយ ឈូក នៅខែសីហា។ ហើយ ឈូក គឺជាអ្នកគាំទ្រ សោ ភឹម ជាលេខាភូមិភាគបូព៌ា។" ហើយបន្តទៅទៀត ប៉ុន្តែខ្ញុំសូមបញ្ចប់សេចក្តីដកស្រង់ត្រឹមនេះ។ នៅពេលដែលខ្ញុំអានខ្លឹមសារជូនលោកស្រីស្តាប់ តើលោកស្រីដឹង ឬក៏នឹកឃើញពីអ្វីទេ ឬក៏លោកស្រីមិនដឹងអំពីព័ត៌មានអី ពីអ្វីដែលខ្ញុំទើបតែអាននោះទេ?

[១៤:១៨:៤៤]

**ធ៖** ខ្ញុំមិនដឹងអីទេ ព្រោះខ្ញុំក៏វាមិនចេះអក្សរផង ហើយដល់អ៊ីចឹងខ្ញុំអត់ដឹងខ្យល់អីទេ។ ថាខ្ញុំមនុស្សខ្ញុំ មនុស្សគ្រាន់តែថាត្រឹមដឹង ដឹងថាត្រង់ដឹង ប៉ុល ពត សម្លាប់ប្រជាជន ដឹងតែប៉ុណ្ណឹង។ រឿងអស់នុ៎ង ខ្ញុំមិនដឹងអីទេ។

**ស៖** លោកស្រីសាក្សី ដោយហេតុថាមនុស្សបីនាក់ដែលជិតស្និទ្ធនឹងលោកស្រីគឺមាន កែវ មាស មាន ឈូក ហើយនិងបងប្រុសរបស់លោកស្រីផង ហើយនិង ចាន់ ចក្រី បានពាក់ព័ន្ធទៅនឹងរដ្ឋប្រហារ ហើយនិងវាយប្រហារឃោធានៅជិតវាំង នៅជិតវិចិត្រសិល្បៈនៅភ្នំពេញ ហើយក្រោយមកត្រូវបានគេចាប់ខ្លួន។ តើលោកស្រីមិនដឹងរឿងហេតុហ្នឹងទាល់តែសោះ ឬយ៉ាងម៉េច?

**ធ៖** ខ្ញុំមិនដែលដឹងផង អត់ដឹងសោះ ទទេ។ ដឹងថាធ្វើៗ ស្រាប់តែគេចាប់យកទៅបាត់ ធ្វើៗចាប់យកទៅបាត់។ ខ្ញុំអត់ដឹងទេ។

**ស៖** ចុះប្តីរបស់លោកស្រី តើគាត់ធ្លាប់ប្រាប់លោកស្រីអំពីមូលហេតុអីដែលគាត់គិតថា បងប្រុសរបស់លោកស្រី ហើយនិង ចាន់ ចក្រី ត្រូវបានគេចាប់ខ្លួនទេ? តើគាត់បាននិយាយប្រាប់លោកស្រីអំពីការឆ្ងល់សង្ស័យរបស់គាត់ទៅលើការចាប់ខ្លួនអ្នកទាំងនោះទេ?

**ធ៖** គាត់មិនដែលនិយាយប្រាប់ខ្ញុំទេ ទទេ។ ហើយម៉្យាងមានតែហាមខ្ញុំកុំឲ្យមាត់កុំឲ្យក នៅស្ងៀម។ ខ្ញុំហ្នឹងបិទមាត់ឲ្យស្ងៀម ខ្ញុំស្ងៀមមែន។

**ស៖** ខ្ញុំបញ្ជាក់ឈ្មោះមួយចំនួនពីខាងដើម។ តើឈ្មោះទាំងអស់ហ្នឹងលោកស្រីបានឮ បានដឹងដែរឬទេ? ខ្ញុំនិយាយអំពី ចក្រី ហើយនិង ឈូក។ ចុះចំពោះ លី ផែន ឬក៏ រស់ ភួង តើលោកស្រីធ្លាប់ឮ

ឈ្មោះអ្នកទាំងនេះទេ?

[១៤:២១:២៣]

**ផ៖** ពីណាវិញ? ខ្ញុំមិនស្គាល់ទេ។

**ស៖** បាទ គឺឈ្មោះបីដែលខ្ញុំចង់ឲ្យលោកស្រីជួយខ្ញុំ។ គឺ លី -- ឈ្មោះ ល្វៃ ហើយនិង លី ផែន ជាស្នងការយោធា ហើយនិង រស់ ភឹង – ល្វៃ ហើយ លី ផែន ហើយនិង រស់ ភឹង។ តើធ្លាប់ឮឈ្មោះអ្នកបីនាក់នេះទេ?

**ផ៖** ទេ ខ្ញុំមិនដូចចន្លោះៗណាស់។ អត់មានឮស្គាល់ ឮអីទេ អត់ដឹងទេ។

**ស៖** ហើយអ្នកសរសេរសេចក្ដីដកស្រង់នេះ គឺជាអ្នកប្រវត្តិសាស្ត្រ និយាយថា ឈ្យូក គឺជាគាំទ្រលេខាភូមិភាគ សោ ភឹម។ តើលោកស្រីដឹងទេតើ ឈ្យូក គឺជាអ្នកការពារ ឬអ្នកគាំទ្រឲ្យ សោ ភឹម អ៊ីចឹងទេ? ធ្លាប់ដឹងទេ ឈ្មោះ ឈ្យូក នេះ?

**ផ៖** ខ្ញុំមិនដឹងតែម្ដង អត់ដឹងអីតិចសោះ ព្រោះ ឈ្យូក ហើយ ភឹង ខ្ញុំអត់ស្គាល់ ខ្ញុំមិនដឹងមុខម៉េចទេ។ ប៉ុន្តែខ្ញុំដឹងតែបងខ្ញុំ ហើយនិង បងចក្រី ហ្នឹងវាត្រូវពួកម៉ាក់ ខ្ញុំដឹងតែប៉ុណ្ណឹង។ ហើយថាឲ្យដឹងទៅណាៗ ខ្ញុំមិនដឹងទេ។

**ស៖** ខ្ញុំនឹងត្រឡប់ទៅបងប្រុសរបស់លោកស្រី។ លោកស្រីនៅក្នុងប្រវត្តិបដិវត្តន៍របស់គាត់នោះ គឺថា E3/7526 នៅក្នុងទំព័រទី១ ខ្មែរ 00079567, បារាំង 00728260។ បងប្រុសលោកស្រីឆ្លើយសំណួរនៅពេលដែលគាត់ចូលបដិវត្តន៍នោះ។ គាត់ចូលបដិវត្តន៍នៅឆ្នាំ១៩៧០ នៅថ្ងៃទី២៧ ខែតុលា អ្នកនាំៗគាត់ចូលគឺ សមមិត្ត ចក្រី។ ខ្ញុំគិតថាយើងពិភាក្សាបន្តិចហើយព្រឹកនេះ ប៉ុន្តែឲ្យប្រាកដ។ តើតាមពិតហ្នឹង គឺសមមិត្ត ចាន់ ចក្រី ជាអ្នកណែនាំ ជាអ្នកនាំគាត់ចូលបដិវត្តន៍ នាំបងប្រុសលោកស្រីចូលបដិវត្តន៍អ៊ីចឹងមែនឬទេ?

[១៤:២៤:១៧]

**ផ៖** ខ្ញុំដឹងតែ តាឈ្យូក ដឹកនាំ។ តែ ចាន់ ចក្រី ខ្ញុំមិនដឹងទេ។ តែដល់ក្រោយមកបានខ្ញុំដឹង ដឹងថាពួកម៉ាក់ ដឹងតែប៉ុណ្ណឹង។

**ស៖** លោកស្រីនិយាយថា ជាពួកម៉ាក់។ តើជាពួកម៉ាក់ជិតស្និទ្ធ ជាមិត្តភក្តិល្អ ឬក៏ដែលថាជាសមមិត្ត មិត្តភក្តិហ្នឹង តើទំនាក់ទំនងរបស់ពួកគាត់ហ្នឹងយ៉ាងដូចម្ដេច? ស្និទ្ធស្នាលយ៉ាងម៉េច?

**ផ៖** ស្និទ្ធស្នាលដើម្បីដោយសារថា ដូច តាឈ្យូក អ៊ីចឹង ហើយនិងបងខ្ញុំ តាឈ្យូក គាត់បង្រៀន

ប៉ុន្តែរាប់អានគ្នា ហើយ បងចក្រី ហ្នឹងមិនដឹងនៅឯណាទេ ទើបដល់ឮក្រោយមកថា ចក្រី ដែរ។ ហើយ អ៊ីចឹងខ្ញុំឆ្លើយថា ចក្រី ដែរទៅ បង ពួកម៉ាកគាត់ មិនអ៊ីចឹង។

**ស៖** អ៊ីចឹងត្រឹមត្រូវទេ ដែលខ្ញុំនិយាយថាបងប្រុសរបស់លោកស្រី ឈូក, ចក្រី, កែវ មាស, ហើយ តាធុច ដែលជាប្អូនប្រុស កែវ មាស ហ្នឹងគឺទាំងប្រាំនាក់ហ្នឹង ជាមនុស្សស្និទ្ធស្នាលនឹងគ្នា។ តើ អ៊ីចឹងឬទេ?

**ឆ៖** អ៊ីចឹងមែន ព្រោះគាត់ធ្វើគ្រូបង្រៀន ពូធុចហ្នឹង។

[១៤:២៦:០៣]

**ស៖** ឥឡូវនេះនៅក្នុងឯកសារដដែល ឯកសារទំព័រដដែល គឺគេសួរសំណួរទៅបងប្រុសរបស់ លោកស្រី៖ "ថាតើធ្វើ កាលចូលបដិវត្តន៍ហ្នឹង ត្រូវធ្វើដូចម្ដេច? គាត់ឆ្លើយ៖ ខ្ញុំវាយតម្លៃគំនិតរបស់ខ្ញុំ ខ្ញុំ ខឹងចក្រពត្តិអាមេរិកាំង ហើយនិងជនក្បត់ជាតិ លន់ នល់។" អ៊ីចឹងបងប្រុសរបស់លោកស្រីនិយាយអំពី ចក្រពត្តិអាមេរិក ហើយនិងជនក្បត់ជាតិ លន់ នល់។ តើគាត់ធ្លាប់និយាយប្រាប់លោកស្រីពីរឿងហ្នឹង ទេ? តើគាត់និយាយរឿងហ្នឹងទេ? អ៊ីចឹងលោកស្រីយល់ដូចម្ដេចដែលថា ចក្រពត្តិអាមេរិក ហើយនិងជន ក្បត់ លន់ នល់ ហ្នឹង?

**ឆ៖** ខ្ញុំមិនបានដឹងទេ។ រឿងគេមិនដែលនិយាយជាមួយខ្ញុំផង។ អារឿងខ្ញុំស្រីៗ គេមិននិយាយ ទេ គេនិយាយតែគ្នាទេ ស្ងាត់ៗ។ ខ្ញុំអត់ដឹង អត់ឮទេ។

**ស៖** ខ្ញុំយល់ បងប្រុសរបស់លោកស្រី ហើយលោកស្រីក៏បានរៀបការជាមួយប្ដីដែលគាត់ចូល ជាបដិវត្តន៍។ តើប្ដីលោកស្រី ហើយនិងបងប្រុសលោកស្រីធ្លាប់និយាយយ៉ាងដូចម្ដេច អំពីជនក្បត់ លន់ នល់ ដែរឬទេ? តើមានន័យដូចម្ដេច? តើពេលដែលគាត់និយាយពាក្យហ្នឹង តើគាត់ចង់មានន័យដូចម្ដេច?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៤:២៨:០៩]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ មេធាវីបានសួររួចហើយ ថាតើគាត់បានពិភាក្សាជាមួយនឹងសាក្សី ដែរឬអត់។ ហើយមិនត្រឹមត្រូវទេ ថាតើ សួរថាតើបងប្រុសរបស់គាត់មានន័យដូចម្ដេចចំពោះពាក្យ

នេះ។ បើសិនជាសួរ ក្នុងករណីសួរសំណួរនេះ គ្រាន់តែឲ្យសាក្សីនិយាយឆ្លើយដោយព្រាវ ដោយស្មានតែប៉ុណ្ណោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំព្យាយាមនឹងសម្រួលសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី តើបងប្រុសរបស់លោកស្រី តើគាត់បានពាក់ព័ន្ធនៅក្នុងការចាប់ខ្លួន ហើយនិងការសម្លាប់មនុស្សមួយចំនួន ដែលធ្វើការនៅក្នុងរបប លន់ នល់ ជាអតីតអ្នករដ្ឋការ ឬទាហានដែរឬទេ?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** មិនដែលទេ។ ខ្ញុំ ព្រោះគេនៅឆ្ងាយ ខ្ញុំនៅជិត ខ្ញុំនៅស្វាយយាណោះ ហើយគេនៅឯក្រសាំងចារណោះ ខ្ញុំមិនដឹងផង។ ឯលើខ្ញុំអត់ដឹងទេ។

**ស៖** បាទ ខ្ញុំនឹងចូលទៅដល់ពីអ្វីៗដែលលោកស្រីដឹងវិញ។ ខ្ញុំសួរសំណួរមួយចំនួនអំពីរយៈកាលឆ្នាំ១៩៧៥ ដល់ ១៩៧៩ តើលោកស្រីរៀបរាប់អំពីសកម្មភាពពីការងារ តើលោកស្រីធ្វើការកន្លែងណា? ពេញចិត្តធ្វើការដែរឬទេ? ហើយធ្វើអ្វីខ្លះពីចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩?

[១៤:២៩:៥៦]

**ឆ៖** ខ្ញុំធ្វើការណាស់ តាំងពីរែកដី ជីកប្រឡាយ ធ្វើការស្ទូងស្រូវ គេឲ្យទៅស្ទូងត្រង់ណា ខ្ញុំទៅត្រង់នោះ។ គេឲ្យទៅណា ខ្ញុំទៅត្រង់នុំង ខ្ញុំមិនដែលខានទេ។ ខ្ញុំខ្លាចគេ។ ប្ដីខ្ញុំប្រាប់ថា គេឲ្យធ្វើអី ធ្វើទៅអ៊ីចឹង ហើយកុំមាត់កុំក នៅស្ងៀមទៅ បានវាសុខខ្លួន។ ខ្ញុំតាមប្ដីណាស់ ប្ដីថាម៉េច អ៊ីចឹង។

**ស៖** តើលោកស្រីចាំអ្វីខ្លះ អំពីពេលម៉ោងធ្វើការក្នុងមួយថ្ងៃ? ពេលព្រឹកធ្វើការចាប់ផ្ដើមម៉ោងប៉ុនណា ហើយពេលល្ងាច ចាប់ផ្ដើមធ្វើការពីម៉ោងប៉ុនណា?

**ឆ៖** ពីម៉ោងប្រាំពីរព្រឹក រហូតដល់ម៉ោងប្រាំល្ងាច ខ្ញុំធ្វើ ប៉ុន្តែអើ មានឈប់ ពេលថ្ងៃហូបបាយមួយម៉ោងដែរ ប៉ុណ្ណឹង។ ធ្វើៗស្វិតខ្លួនអស់រលីង។

**ស៖** តើទាក់ទងទៅនឹងការងារនៅក្នុងវាលស្រែ ឬក៏ធ្វើការនៅតាមការដ្ឋានទំនប់អី ប្រឡាយអីទេ នៅក្នុងភូមិភាគបូព៌ា?

**ឆ៖** តាមប្រឡាយ ជីកប្រឡាយៗ ហើយនិងទៅជីកខាងកើតវត្តស្វាយជ្រំអីហ្នឹង ខ្ញុំទៅ ហើយ

កូននៅតូចៗ គ្មានកូនធំទេ។ កូននៅផ្ទះ ខ្ញុំទៅដឹងតែពីធ្វើ។

**ស៖** តើលោកស្រីចាំដែរឬទេ ពីឆ្នាំណាដល់ឆ្នាំណា ដែលធ្វើការនៅទំនប់ នៅកាលសម័យនោះ?

**ឆ៖** ឆ្នាំ៧៧ ខ្ញុំទៅធ្វើ ហើយដល់ពេលក្រោយមកបានគេ មកគេចាប់ប្ដីខ្ញុំទៅៗ គេក៏លែងឲ្យទៅៗ ខ្ញុំធ្វើមុន។ ប្ដី -- ខ្ញុំធ្វើនៅចុងក្រោយ ដែលគេចាប់ហ្នឹង។

**ស៖** នៅពេលដែលធ្វើការនៅទំនប់ តើមានតួនាទីដឹកនាំអីដូចប្ដីរបស់លោកស្រីទេ ឬក៏គ្រាន់តែជាកម្មករធម្មតា?

[១៤:៣២:៣២]

**ឆ៖** អូ៎! ខ្ញុំមិនហ៊ានទេ ខ្ញុំខ្លាចណាស់។ ខ្លាចងាប់ នឹកឃើញសព្វ ខ្លាចងាប់ណាស់។ ប្ដីខ្ញុំហាមដាច់ខាត កុំមាត់កុំកឲ្យសោះ គេឲ្យធ្វើអី ធ្វើទៅ ថាអ៊ីចឹង ហើយខ្ញុំចេះតែធ្វើហើយ។ ខ្ញុំមិនហ៊ានទទឹងរឹងរូសជាមួយគេទេ។

**ស៖** អ៊ីចឹងលោកស្រីបានធ្វើជាកម្មករ ហើយប្ដីរបស់លោកស្រីទេ ដែលជាថ្នាក់ដឹកនាំនៅក្នុងស្រុក ឬក៏នៅក្នុងឃុំ។ តើអ៊ីចឹងឬទេ?

**ឆ៖** អ៊ីចឹង។

**ស៖** តើលោកស្រីស្ថិតនៅក្នុងកងកម្លាំងឃុំ ឬក៏ស្រុក ឬក៏ស្ថិតនៅក្នុងកងចល័ត កាលនោះ?

**ឆ៖** ខ្ញុំមិនមែនកងចល័ត ក៏មិនមែនអីដែរ តែគេចាត់ឲ្យខ្ញុំទៅជីកប្រឡាយហ្នឹង។ ចាត់ឲ្យជីកប្រឡាយ ហើយជីកហើយហ្នឹង មិនហ៊ានមាត់ មិនហ៊ានក ស៊ីតែបាយហើយ នាំគ្នាដេកទៅថ្ងៃ ដល់ពេលយប់ ជីកទៀត ទាល់តែនេះ ខ្ញុំមិនដែលមាត់ទេ។ នៅតែមិនចង់សុខខ្លួនទៀត។

**ស៖** នៅពេលដែលលោកស្រីធ្វើការនៅតាមវាលស្រែ ឬក៏តាមការដ្ឋានទំនប់ដែលមានគេត្រួតពិនិត្យមើល តើលោកស្រីធ្លាប់ឮថា មានប្រជាជនថ្មីនៅធ្វើការនៅតាមឃុំ តាមស្រុកហ្នឹងដែរឬទេ? តើមានភាពខុសគ្នារវាងប្រជាជនចាស់ ឬក៏ប្រជាជនថ្មីដែរឬទេ កាលនោះ?

**ឆ៖** ទេ ខ្ញុំដែលខ្ញុំទៅធ្វើ ទៅធ្វើតែជាមួយប្រជាជនថ្មីហ្នឹង។ គេមិនដែលថាអីឲ្យខ្ញុំ ហើយខ្ញុំក៏មិនដែលថាអីឲ្យគេ។ គេធ្វើតែទាំងអស់គ្នា ស្រុះដៃស្រុះជើង មានស្អី។ គ្មានជៀមដាមរកគ្នាទេ ធ្វើរាប់អានដូចបងប្អូនអ៊ីចឹង មានស្អីចែកគ្នាស៊ីទៅ។ អាហ្នឹងអ៊ីចឹង។

[១៤:៣៥:០៣]

**ស៖** តើប្រជាជនថ្មីទទួលបានចំនួនចំណីអាហារដូចគ្នា ស្មើគ្នានឹងប្រជាជនចាស់ដែរទេ?

**ឆ៖** ដូចគ្នា ប៉ុន្តែដូចប្រជាជនចាស់ក៏បាយបបរមួយវែកៗឲ្យហូបដូចតែគ្នា ហើយប្រជាជនថ្មីក៏បាយបបរមួយវែកៗដូចតែគ្នាហ្នឹង។ ឲ្យហូបបបរ មិនឲ្យហូបបាយស្រួយទេ។ បើបាយស្រួយប៉ិៗ។

**ស៖** ហើយតើប្រជាជនថ្មីធ្វើការដូចគ្នានឹងប្រជាជនចាស់ដែរឬទេ នេះនិយាយអំពីចំនួនម៉ោងធ្វើការក្នុងមួយថ្ងៃៗ ប្រជាជនថ្មីធ្វើស្មើគ្នានឹងប្រជាជនចាស់ដែរទេ?

**ឆ៖** ធ្វើដូចគ្នា ហើយធ្វើចំណាប់ណាស់ ខ្លះចំណាប់មែនទែន។ ធ្វើការគ្មានទេ ដូចខ្ញុំវិញទៅធ្វើជាមួយតែគ្នា ប្រលូកជាមួយតែគ្នា លេងសើចដូចតែគ្នាហ្នឹង។ ដល់ពេលក្រោយមកស្រាប់តែយកគ្នាទៅបាត់អស់រលីង។

**ស៖** ចុះនៅពេលដែលប្រជាជនថ្មីធ្លាក់ខ្លួនឈឺពេលធ្វើការហ្នឹង តើប្រជាជនថ្មីទទួលបានថ្នាំពេទ្យដូចប្រជាជនចាស់ដែលធ្លាក់ខ្លួនឈឺនោះដែរ?

**ឆ៖** មាន តែថ្នាក់ដូចអាចម៍ទន្សាយ។ ទុកតែចាស់ក៏ដូចអាចម៍ទន្សាយដែរ។

**ស៖** ខ្ញុំយល់ហើយ តើខ្ញុំត្រឹមត្រូវដែរឬទេ បើសិនជាខ្ញុំនិយាយថានៅក្នុងឃុំ ឬក៏ស្រុករបស់លោកស្រី គឺថាប្រជាជនថ្មី និងប្រជាជនចាស់ គេគឺថាពាក់ព័ន្ធទៅនឹងការទទួលបានថ្នាំពេទ្យ ទទួលបានរបបអាហារ គឺថាដូចៗគ្នាទេ មិនខុសគ្នាទេ។ អ៊ីចឹងមែនទេ?

[១៤:៣៧:២៥]

**ឆ៖** ចាស បានដូចគ្នា ប៉ុនដូចអាចម៍ទន្សាយ។

**ស៖** លោកស្រីនៅចាំទេ ថានៅក្នុងឃុំ ឬក៏ស្រុករបស់លោកស្រីហ្នឹង គេចាប់ផ្ដើមហូបបាយរួមនៅក្នុងឆ្នាំណា?

**ឆ៖** ខ្ញុំវាភ្លេចដែរហ្នឹង ដូចឆ្នាំ៧៧ យ៉ាងមើលទៅ។ ខ្ញុំថាអ៊ីចឹងចុះ ៧៧ ប៉ុន្តែដើមឆ្នាំ។ ដល់ពេលឆ្នាំ៧៨ ចាប់ផ្ដើម -- អ្ហេ!៧៨អីទេ ៧៧ចាប់គ្រួសារខ្ញុំ ហ្នឹងបាយបានប្រហែលជាប្រាំប្រាំមួយខែយ៉ាងបាយរួម។

**ស៖** តើប្រជាជនម្នាក់ៗត្រូវតែស្លៀកពាក់ខោអាវខ្មៅហ្នឹងតាំងពីឆ្នាំ១៩៧៥មក ឬក៏យ៉ាងណា?

**ឆ៖** ពីឆ្នាំ មើលខ្ញុំគិតមើលសិន ខ្ញុំភ្លេចដែរ។ ប្រហែលជាឆ្នាំ៧៦ មិនដឹងទេ អ្ហេមិនមែន៧៦ទេថា ៧៥។ ខ្ញុំថាអ៊ីចឹងចុះ។ កាលនេះខ្ញុំវាភ្លេច ព្រោះខ្ញុំវាភ្លេចភ្លាំងអស់ហើយ ខ្ញុំមិនបានចាំ។

**ស៖** តើប្ដីលោកស្រី ពេលគាត់នៅធ្វើជា -- គាត់ ប្ដីលោកស្រីគឺមិនដែលឲ្យអ្នកណាម្នាក់ទៅចាប់ខ្លួនប្រជាជនទេ?

**ឆ៖** មិនដែលទេ គ្មានឲ្យទៅចាប់ធ្វើអី គ្នាស្រឡាញ់ប្រជាជនសឹងងាប់ គេមិនឲ្យចាប់ទេ។ ហើយដល់ពេលក្រោយមកបានគេចាប់ វ៉ៃឡើងពាយទៅ។

**សៈ** ពីខាងដើមមកគឺថា លោកស្រីត្រូវបានសួរអំពីការរៀបការចម្រុះជាតិសាសន៍ នៃគ្រួសារចម្រុះជាតិសាសន៍គ្នា ដែលការរួមគ្នាខ្មែរ-វៀតណាម វៀតណាម-ខ្មែរនេះ ទៅធ្វើការជាមួយគ្នាដែរទេ តាំងពីពេលប្ដីលោកស្រីនៅទទួលខុសត្រូវនោះ?

[១៤:៤០:២៣]

**ឆ៖** មានថី ទៅធ្វើជាមួយគ្នាអីតើ! ស្រុកខ្មែរ ហើយគាត់យកប្ដីខ្មែរហើយគាត់ទៅធ្វើជាមួយតែគ្នាហ្នឹង ប៉ុន្តែហ្នឹងគេភូមិខាងជើងខ្ញុំទេ តែឆ្លងព្រែកមួយ។ ខ្ញុំក៏នេះដែរ តែខ្ញុំសួរគេថា មិនអីទេ ត្រូវគ្នា ហើយប្ដីខ្ញុំក៏និយាយដែរថា មានថី គាត់ធ្វើណាស់។ ហើយដល់ក្រោយមកបានយកគាត់ទៅវ៉ៃចោល បានខ្ញុំអាសូរគាត់ដែរ កូនផង កូនកំពុងតែំ"ៈឹម៉ឹមដោះ បេះយកទៅៗ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:៣៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីការសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី មុនពេលឈប់សម្រាកខ្ញុំសួរលោកស្រីអំពីក្រុមគ្រួសារដែលរៀបការជាមួយនឹងជនជាតិវៀតណាម នៅក្នុងឃុំរបស់លោកស្រី។ មុននឹងខ្ញុំសួរបន្តទៅទៀត ខ្ញុំសូមត្រឡប់ទៅនិយាយនូវអ្វីដែលលោកស្រីបានឆ្លើយមុនពេលឈប់សម្រាក គឺខ្ញុំសួរលោកស្រីថា៖ តើលោកស្រីបានដឹងថា មានចលនាបក្សពីរនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែរឬក៏អត់ទេ? លោកស្រីថា៖ ខ្ញុំមិនដឹងទេរឿងនេះ។ ប៉ុន្តែនៅពេលឈប់សម្រាកនេះ ខ្ញុំបានមើលចម្លើយរបស់លោកស្រីឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាអានជាភាសាបារាំង។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីនូវចម្លើយគឺឯកសារ E3/7526, ERN បារាំង 00746692, ខ្មែរ 00185384។ ខ្ញុំសូមអានជាភាសាបារាំងម្តងទៀត ហើយអធ្យាស្រ័យ ចំពោះអំណានជាភាសាបារាំងផង។ អ្នកស៊ើបអង្កេតបានសួរដូចតទៅ៖ “មិនមែនអ៊ីចឹងទេ។ ខ្ញុំគិតថាមានខាងខ្មែរក្រហមដូចគ្នាអ៊ីចឹងណ៎ា។ ហើយបន្ទាប់មកទៀត វាមានបក្សមួយផ្សេងទៀត។ ពួកនុ៎ងមិនមែនជាខ្មែរក្រហមទាំងស្រុងទេ ពួកហ្នឹងវាស្អប់ជាតិ។” លោកស្រីពីព្រឹកមិញ សហព្រះរាជអាជ្ញាបានសួរអំពីបញ្ហាខ្មែរក្រហមនេះ តែនៅត្រង់នេះ លោកស្រីហាក់បីដូចជាញែកដាច់ពីគ្នា រវាងមួយហៅថា “ខ្មែរក្រហម” ម្ខាងទៀតហៅថា “ក្រុមក្បត់ជាតិ”។ ហេតុអីក៏លោកស្រីឆ្លើយយ៉ាងដូច្នេះ?

[១៥:០៤:០៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងការកំណត់ចរិតលក្ខណៈ វាមិនបានត្រឹមត្រូវ នៅត្រង់ផ្នែកនេះ។ ក្នុងការដែលចម្លើយខាងក្រោមមកទៀត គឺថា សាក្សីមិននិយាយអំពីថាមានបក្សពីរខុសគ្នាទេ និយាយពេលដែល ប៉ុល ពត និងមជ្ឈិមចាប់ផ្តើមសម្លាប់ប្រជាជន។ កាលណានិយាយអំពីពួកក្បត់ ក្រុម

ក្បត់នេះ គឺសំដៅទៅលើក្រុម ប៉ុល ពត ដែលចាប់ផ្ដើមស្លាប់មនុស្សនេះតែម្ដង។ ដូច្នេះចម្លើយរបស់សាក្សីហ្នឹង មិនពាក់ព័ន្ធទៅនឹងថាមានបក្សពីរនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមធ្វើការឆ្លើយតប។ នៅក្នុងចម្លើយរបស់គាត់គឺថា គាត់អាចពន្យល់បានត្រង់ចំណុចដែលគាត់និយាយថា មានខ្មែរក្រហមមួយផ្នែក មួយផ្នែកទៀតមានក្រុមក្បត់ជាតិនោះ។ ERNជាភាសាបារាំង 00746961, ខ្មែរ 00185384។ គាត់បានឆ្លើយដូចតទៅ៖ “ពួកគេប្រាប់យើងថា គេមិននិយាយអំពីរឿងរ៉ាវរបស់ពួកគេទេ បក្សខ្មែរក្រហមម្ខាង ហើយនិងម្ខាងទៀតបក្សខាងពួក ប៉ុល ពត។” ទោះបីជាសរសេរជាភាសាបារាំង ខ្ញុំអានមិនបាន យល់មិនបានល្អក៏ដោយ ក៏ប៉ុន្តែត្រង់ចម្លើយនេះគឺនិយាយអ៊ីចឹងថា មួយក្រុមគឺថាជាបក្សហ្នឹងតែម្ដង ហើយមួយក្រុមទៀតគឺក្រុមក្បត់ជាតិ។

[១៥:០៦:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីឱ្យមានភាពងាយស្រួល គឺយើងអានសំណួរចម្លើយទាំងស្រុង ដែលសួរទៅកាន់សាក្សី។ ខ្ញុំសូមអាន គេសួរសំណួរចង់ដឹងថា តើគេធ្វើបាបមនុស្សយ៉ាងម៉េច? ពេលនោះគាត់ឆ្លើយដូចតទៅ៖ គេធ្វើបាប នៅសម័យនោះគេមិនចង់ឱ្យមាន ហើយគេចេះតែថា គេមិនបាននិយាយអំពីរឿងដែលថា ម្ខាងមានខ្មែរក្រហម និងម្ខាងទៀតមានបក្សរបស់ពួក ប៉ុល ពត នោះទេ។ ពួកគេមិននិយាយអ៊ីចឹងទេ។ គេនិយាយថា គេបានប្រមូលចូលគ្នាអស់ហើយ។ ពួកគេវ៉ៃដើម្បីយកអ្វីៗទាំងអស់ មានន័យថា ខ្មែរក្រហមប៉ុល ពត ហ្នឹងគឺដូចគ្នាទេ។ អត់មានអី ដូចថាខុសគ្នាដោយឡែក ប៉ុល ពត ផ្សេង ខ្មែរក្រហមអីទេ។ ដូច្នេះខ្ញុំមើលទៅដូចពិបាកឃើញថា ពីរបក្សណាស់ ព្រោះមើលទៅដូចវាដូចតែមួយបក្សទេ ខ្មែរក្រហមហើយនិង ប៉ុល ពត នោះ។ បើមើលតាមការបកស្រាយជាភាសាបារាំងនោះ ដូចជាមិនសូវល្អប៉ុន្មានទេ ពិបាកយល់ដែរ ក៏ប៉ុន្តែយើងឃើញតែមួយបក្សទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

[១៥:០៧:៤១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**លោក វ៉ិចទ័រ កូប៉េ៖**

ភាសាបារាំងមិនមែនជាភាសាកំណើតរបស់ខ្ញុំទេ តែតាមដែលខ្ញុំយល់ហ្នឹងគឺគាត់ឆ្លើយ និយាយអំពីពីរបក្សនេះដែរ គឺខ្មែរក្រហមមួយបក្សទៅ ហើយនិងក្រុមក្បត់ជាតិនោះ មួយក្រុមទៅ។ ប្រហែលជាចង់សំដៅនិយាយថា ប៉ុល ពត គឺជាជនក្បត់ជាតិ ក៏មិនដឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា កុំយោងទៅលើការបកប្រែជាភាសាបារាំងហ្នឹងពេក ព្រោះថាបកដូចជាមិនសូវត្រូវទេ។ លោកសួរសំណួរផ្ទាល់អំពីអ្វីដែលគាត់ដឹងតែម្តងទៅ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោសលោកចៅក្រម ឡាវែន ខ្ញុំគិតថា ទោះបីជាការបកប្រែជាភាសាបារាំងមិនល្អក៏ដោយ ក៏ប៉ុន្តែការសួរពាក់ព័ន្ធទៅនឹងបក្សខ្មែរក្រហមម្ខាង បក្សប៉ុល ពតម្ខាងនោះ គាត់បាននិយាយច្រើនដងរួចមកហើយ។ ដូច្នេះហើយខ្ញុំគិតថា គាត់អាចសួរបញ្ជាក់ពីសាក្សីបានដើម្បីឲ្យដឹងថាតើមានបក្សពីរផ្សេងគ្នា ឬអត់ ក៏ប៉ុន្តែតាមឯកសារ ដូចជាមើលទៅឃើញមានបក្សពីរផ្សេងគ្នាមែន។

[១៥:០៨:៥៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនអាចសន្និដ្ឋានបានទេ ប្រហែលជាភាសាបារាំងបកប្រែទៅវា ដូចថាវាអន់ពេក។ ប៉ុន្តែខ្ញុំសុំសួរសំណួរចំៗទៅសាក្សីតែម្តង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី តើលោកស្រីកំពុងនិយាយថា មានបក្សពីរ គឺមួយហៅថា ខ្មែរក្រហម និងមួយទៀតគឺក្រុមក្បត់ជាតិ លោកស្រីសំដៅទៅ ប៉ុល ពត មួយបក្សទៅ ហើយមួយបក្សទៀតផ្សេងហ្នឹងឬយ៉ាងម៉េច?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** ខ្ញុំអារឿងខ្មែរក្រហម ហើយនិងក្បត់ជាតិហ្នឹង ដូចជាសូវនិយាយដែរ តែដូចភ្លេចអស់រលីងហើយ វាភ្លេច។ ប៉ុន្តែបើតាមការពិតទៅ វាគ្មានណាបក្សពីរបីទេ មានតែថាខ្មែរក្រហមហ្នឹងអ្នកសម្លាប់

ប្រជាជនតែម្តង ខ្ញុំថាអ៊ីចឹង។

**ស៖** តើបងប្រុសរបស់លោកស្រី ប្តីលោកស្រី នៅជាមួយនឹងខ្មែរក្រហមនៅខាងខ្មែរក្រហម ឬក៏នៅម្ខាងទៀត ឬក៏នៅជាមួយនឹងខាងពួកក្រុមក្បត់ជាតិ? លោកស្រីយល់ថាម៉េចនៅកន្លែងហ្នឹង?

**ឆ៖** គ្មាននៅក្រុមខាងក្បត់ជាតិទេ នៅស្មោះត្រង់ នៅនឹងផ្ទះ រកស៊ីចិញ្ចឹមកូន ចិញ្ចឹមចៅ ដល់ពេលស្រុកអ៊ីចឹងទៅ ទៅតាមតែគេតាមតែឯងទៅ។ ទៅធ្វើទៅ ដល់ធ្វើៗ ស្រាប់តែងាប់ខ្លួន។ ឯខ្ញុំវាសង្ស័យត្រង់ហ្នឹងដែរ ហើយខ្ញុំឆ្ងល់ត្រង់ហ្នឹងដែរ ឆ្ងល់មែនទែន។

[១៥:១១:០៨]

**ស៖** ក៏ប៉ុន្តែអ្នកណាដែលជានិយាយថាជាអ្នកដែលក្បត់ជាតិនោះ? បក្សខ្មែរក្រហមមួយណា?

**ឆ៖** ក្បត់ជាតិៗ វាដូចថា ងាប់ៗហើយដែលបានថាក្បត់ជាតិ ពួកអាក្បត់ អាហ្នឹងត្រូវសម្លាប់យើង។ ប៉ុន្តែវាមានអ៊ីចេះ វាមានត្រង់ថា អង្កាល់ដែលសាមុនគេធ្វើល្អណាស់ ដល់ពេលក្រោយមកនេះ អាឃុំក្រោយនេះបានវាធ្វើបាបប្រជាជន វាធ្វើបាប វាចូលក្រោយ។ ដល់ធ្វើបាប ងាប់វាពាយទៅ ចាប់ៗគ្មានប្រណី ចាប់យកទៅសម្លាប់ៗទៅ។

**ស៖** ខ្ញុំសូមអានខ្មែរ ភាសាដើមទៅចុះ។ ឥឡូវ ខ្ញុំចាប់ផ្តើមសួរឡើងវិញអ្វីដែលខ្ញុំបានសួរមុនពេលឈប់សម្រាកនោះ។ ខ្ញុំបានសួរពាក់ព័ន្ធទៅនឹងអ្នកដែលបានរៀបការជាមួយជនជាតិវៀតណាមនៅក្នុងឃុំរបស់លោកស្រី។ អ្នកដែលរៀបការជាមួយជនជាតិវៀតណាមនៅក្នុងឃុំលោកស្រីហ្នឹង លោកស្រីស្គាល់ឈ្មោះពួកគេទេ?

**ឆ៖** បងប្អូនខ្ញុំ មិនស្គាល់ម៉េច! បងប្អូនខាងម៉ែ ហើយអ៊ីចឹងខ្ញុំធ្វើអីមិនស្គាល់។

**ស៖** តើអ្នកណាខ្លះដែលជាសាច់ញាតិខាងម្តាយរបស់លោកស្រីនុ៎ង?

**ឆ៖** តាឆោម ហ្នឹង បងប្អូនខាងម្តាយខ្ញុំហើយហ្នឹង។ ហើយតែបើ តាឈិន ស៊ីការហ្នឹងមិនមែនទេ តែគេក្នុងស្រុក ឃុំ ភូមិស្វាយយាដែរ ប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមទោស។ ឥឡូវនេះ ខ្ញុំកំពុងសួរលោកស្រីអំពីគ្រួសារដែលរៀបការជាមួយវៀតណាមដែលធ្វើការនៅតាមវាលស្រែជាមួយលោកស្រី និងនៅតាមការដ្ឋានលើកទំនប់ផ្សេងៗ។ គឺសួរអំពីគ្រួសារដែលរៀបការជាមួយវៀតណាមហ្នឹងឯង។ តើលោកស្រីស្គាល់ឈ្មោះគ្រួសារទាំងនោះដែរទេ?

[១៥:១៣:៥១]

**លោក ឌេល លីសាក់៖**

សម្រាប់ប្រតិចារឹក ឈ្មោះពីរនាក់ដែលសាក្សីទើបនឹងឆ្លើយ គឺប្តីខ្មែរ ដែលរៀបការជាមួយប្រពន្ធវៀតណាម។ ខ្ញុំឮសួរឈ្មោះពីរនាក់នេះទៅ គឺថាវាស៊ីចង្វាក់គ្នា គឺស៊ីចង្វាក់គ្នាទៅនឹងឈ្មោះដែលខ្ញុំបានដឹងថា រៀបការជាមួយជនជាតិវៀតណាម។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមទោស ខ្ញុំស្តាប់ឮផ្សេង។ អ៊ីចឹងខ្ញុំរៀបសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីស្គាល់ពួកគេ ដោយសារគេជាប់ជាសាច់ឈាមជាមួយលោកស្រី។ តើពួកគេជាសាច់ឈាមដូចម្តេចដែរជាមួយនឹងលោកស្រី?

**លោកស្រី ស៊ិន ផែម៖**

**ឆ៖** ម៉ែខ្ញុំ ហើយនិងប្រពន្ធគាត់បងប្អូនជីដូនមួយ។

**ស៖** លោកស្រីដឹងថាពួកគេមានសញ្ជាតិអ្វីដែរទេ?

**ឆ៖** មានទេ ខ្មែរសុទ្ធប្តីគាត់ តែវៀតណាមនុ៎ង គាត់ៗប្រពន្ធក្រោយទេ ប្រពន្ធហ្នឹង គាត់យកប្រពន្ធក្រោយ។ ប្រពន្ធមុន គាត់ស្លាប់ហើយ ហើយដល់អ៊ីចឹងយកប្រពន្ធក្រោយទៀត បានកូនពីរ។ ប្រពន្ធវៀតណាមនុ៎ងទៅជួបគ្នាឯណាទេ ស្រឡាញ់គ្នាបានយកមកហ្នឹង មិនបានរៀបការរៀបអីនឹងគេទេ។

[១៥:១៥:៣០]

**ស៖** ប៉ុន្តែលោកស្រីដឹងថា ប្រពន្ធនោះក្នុងឆ្នាំ១៩៧៥ហ្នឹងមានអត្តសញ្ញាណប័ណ្ណខ្មែរ ហើយដែលទទួលសញ្ជាតិខ្មែរហើយនៅ?

**ឆ៖** ខ្ញុំអត់បានដឹងអាត្រង់នុ៎ងទេ អត់បានដឹងទេ ដឹងតែប្រពន្ធកូន ហើយដល់ពេលនេះ ស្រាប់តែថា អូសយកទៅវ៉ៃចោល។ ខ្ញុំអត់ដឹងផង ហ្នឹងអារឿងម៉េចៗខ្ញុំអត់ដឹងទេ។

**ស៖** ចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ តើចន្លោះនុ៎ង លោកស្រីធ្លាប់បានឃើញគេសម្លាប់អ្នកណាម្នាក់ដោយផ្ទាល់ភ្នែកដែរទេ?

**ឆ៖** ខ្ញុំអត់បានឃើញទេ ប៉ុន្តែមានសម្លាប់នៅដាក់កប់នៅក្បែរផ្ទះ ខាងត្បូងផ្ទះខ្ញុំនុ៎ង នៅកែងស្រែក៏មានដែរ កំពុងតែបុកស្រូវ។ បុកស្រូវ បុកៗអូសគ្នាយកមកវ៉ៃចោលតែម្តង។ មុននឹង -- មិនវ៉ៃ

ចោលមក មកសេពកាមគ្នាអស់ ទាល់អន់ណាណី បានវ៉ៃចោល។ ឆ្កែហែកអ្វែងស្បែក ហែកខោអាវ វហែកនៅរយ៉ុងរយ៉ៃនៅនឹងកែងស្រែ កប់អត់ជិតទេ។

**ស៖** អរគុណចំពោះចម្លើយនេះ ប៉ុន្តែលោកស្រីមិនធ្លាប់បានឃើញគេសម្លាប់មនុស្សដោយផ្ទាល់ភ្នែកទេ កាលនោះ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំមិនដែលបានឃើញទេ ប៉ុន្តែខ្ញុំទៅច្រូតខ្ញុំឃើញខ្មោច ហើយគេប្រាប់ខ្ញុំថា អា្ហ! ងាប់គេវ៉ៃយប់មិញហើយនេះ។ ហើយមួយគ្រូបង្រៀននៅកប់នឹងកែងអន្លង់ខាងជើងគ្នាហ្នឹង កូនពីរប្ដីមួយប្រពន្ធមួយ កប់មួយអន្លង់បួននាក់។ ខ្ញុំទៅឃើញទាំងផ្នូរទៀត។ ខ្ញុំមិនបានឃើញគេវ៉ៃទេ អ៊ូ! ឃើញគេវ៉ៃផងមិនបាច់ទេ ខ្ញុំរាកអាចម៍រាកនោម។

[១៥:១៨:០១]

**ស៖** តើលោកស្រីមានដឹងថា គេមានបញ្ជូនប្រជាជនវៀតណាម -- បញ្ជូនជនជាតិវៀតណាមតាមទូកទៅប្រទេសវៀតណាមវិញទេ?

**ឆ៖** ថាបញ្ជូនៗ ប៉ុន្តែដឹងទៅ មិនទៅ ខ្ញុំមិនដឹងទេ មិនបានដឹងដែរ។ គេថាគេហ្នឹងស្អី គេហៅថាម៉េចទេ ហៅថាៗអីទេ ខ្ញុំភ្លេចទៅ។ ថាគេបញ្ជូនទៅវិញ ប៉ុន្តែខ្ញុំអត់បានដឹង។ អត់បានឃើញ។

**ស៖** អ្នកដែលរៀបការចម្រុះជាតិសាសន៍ខ្មែរ-វៀតណាមនេះ តើលោកស្រីធ្លាប់ឃើញគេចាប់ខ្លួនអ្នកទាំងនោះ ឬក៏គេបណ្ដើរអ្នកទាំងនោះចេញពីកន្លែងលោកស្រីធ្វើការទៅទេ?

**ឆ៖** មានតើ! ចាប់ ហើយដល់ពេលគេឲ្យរត់មុនកង់ ហើយកង់ជិះពីក្រោយ ចងដៃទៅក្រោយទៀត។ ខ្ញុំឃើញជាក់ស្ដែងនឹងភ្នែក។

**ស៖** ហើយអ្នកដែលគេចាប់ចង ហើយបណ្ដើរឲ្យរត់មុខកង់ហ្នឹង ហ្នឹងជាពេលដែលលោកស្រីឃើញចុងក្រោយបំផុតហើយឬ?

**ឆ៖** ដឹងជាចុងមុន ដឹងជាចុងក្រោយ ប៉ុន្តែអង្កាល់ទុំងខ្ញុំទៅជីកដី ហើយខ្ញុំចេញមកវិញ គេឲ្យរំសាយឲ្យមកផ្ទះ ហើយខ្ញុំមកឃើញ គេឃើញរត់ ខ្ញុំឈរកពុទ្ធោ ខ្ញុំថាអ្អើយ។

**ស៖** លោកស្រីធ្លាប់ឮស្នូរគ្រាប់កាំភ្លើងបាញ់បោះ ធ្លាប់ឮគ្រាប់បែក គ្រាប់កាំភ្លើងធំ ឬក៏សួរម៉្យាងទៀតថា លោកស្រីធ្លាប់ឮសូរសំឡេងគ្រាប់កាំភ្លើងប្រយុទ្ធគ្នាជាមួយនឹងវៀតណាមទេ?

**ឆ៖** ឮ! អ៊ូឮណាស់។

**ស៖** លោកស្រីចាំអ្វីខ្លះដែរអំពីការប្រយុទ្ធគ្នានេះ?

[១៥:២០:៥២]

**ឆ៖** ប្រយុទ្ធគ្នាអង្កាល់ដែលប្រយុទ្ធគ្នានោះ កាំភ្លើងផ្គោងក៏ផ្គោង គ្រាប់ស្នឹក៏អីដែរ ខ្ញុំភ័យហូរអាចម៍ ហូរនោមណោះ ភ័យខ្លាចត្រូវ ហើយកូនចៅខ្ញុំរត់ប្រសេចប្រសាច ខ្ញុំខ្លាចត្រូវងាប់។ ឲ្យតែឮនេះឯណាហ្នឹង ខ្ញុំរត់ហើយ រត់ទៅនៅភូមិគេនោះ ពកូនរត់ទៅហើយ កូននៅតូចៗ។

**ស៖** ហើយការបាញ់ផ្គោងនេះ គឺកងទ័ពវៀតណាមឬដែលបាញ់ផ្គោងចូលមកក្នុងទឹកដីកម្ពុជាហ្នឹង?

**ឆ៖** មែន បាញ់មកពីហ្នឹងមែន។ ប៉ុន្តែវាមានតាម ខ្ញុំមើលទៅវាមានពីរឯកសណ្ឋាន មានពីរ មួយគេល្អ មួយគេអាក្រក់អីចេះ។ បានខ្ញុំថាអីចឹងចុះ។

**ស៖** លោកស្រីចង់និយាយថាម៉េចហ្នឹង មួយល្អ មួយអាក្រក់ហ្នឹង?

**ឆ៖** ខ្ញុំចង់និយាយថា មួយធីវគី មួយវៀតណាមគេល្អត្រឹមត្រូវមែន។ ខ្ញុំថាអីចឹង តែដឹងខ្ញុំខុសត្រូវ ខ្ញុំមិនដឹងទេ។

**ស៖** លោកស្រីសាក្សី នៅពេលដែលលោកស្រីឆ្លើយអីចឹង ហេតុម៉េចបានជាលោកស្រីសើច?

**ឆ៖** ឮគេថាអីចឹង គេថាធីវគី ពួកអាធីវគីៗ ខ្ញុំអត់ដឹងដែរ ដឹងតែអីចឹងទៅ។ ហើយដល់ពេលអីចឹងផ្គោងមក បាញ់មក នៅស្រុកខ្ញុំ ភូមិខ្ញុំ ធ្លាយដល់ស្នួត ដល់អីចឹងៗ។ ដល់អីចឹង គេចេះតែថាអីចឹងទៅ ខ្ញុំអីចឹងដែរទៅ។

**ស៖** តើលោកស្រីមានដឹងថាអ្នកភូមិអ្នកឃុំអ្នកស្រីហ្នឹង មានត្រូវរបួសឬក៏ស្លាប់ ដោយសារតែការបាញ់ផ្គោងពីសំណាក់កងទ័ពវៀតណាមនេះទេ?

[១៥:២៣:២៩]

**ឆ៖** ត្រូវដែរ ត្រូវរបួសធ្លាយគ្រាប់អំបែងស្នួត អំបែងដល់ស្នួតនោះ ហើយនិងកំបុតស្លឹកត្រចៀកម្ខាង ហ្នឹងគ្រាប់ផ្គោងមកពីនាយមក។

**ស៖** តើលោកស្រីដឹងថា មានកងទ័ពកម្ពុជាប្រជាធិតេយ្យ ឬក៏ថាកងទ័ពខ្មែរនេះ ទទួលរងរបួសឬក៏ស្លាប់ដោយសារតែគេបាញ់ផ្គោងពីសំណាក់វៀតណាមនេះដែរទេ?

**ឆ៖** អ្ហែ! មិនសូវមានទេ ដែលបាញ់មកផ្គោងមក កម្រដែរ ព្រោះគេគេច។ ដូចខ្ញុំវិញ គ្រាន់តែឮថា អ្ហូ!មកហើយនោះ ទៅនៅឯណោះ ស្រុកនេះណោះ ជើងណោះ ពកូនទៅហើយ កូនតូចៗ ភ័យអីចឹង។ ហើយដែលក្មួយខ្ញុំហ្នឹង ដែលថាត្រូវធ្លាយដល់ស្នួតហ្នឹង បានពួកវៀតណាម ពួកនេះហ្នឹង វាមកពី

កើតមក គេមកគេឲ្យថ្នាំឲ្យអីលេបទៅជា។ គ្រាន់បើបានទាល់តឡូវៗនៅនេះណោះ នៅកន្លែងរោងដំរីទៅរះដល់វៀតណាមណោះ។

**ស៖** ការបាញ់ផ្លោងពីសំណាក់កងទ័ពវៀតណាមហ្នឹង តើលោកស្រីនៅចាំថា ក្នុងឆ្នាំណាដែរ ឆ្នាំ១៩៧៧ ឬចុង៧៧ ឬក៏ដើមឆ្នាំ១៩៧៨។ លោកស្រីចាំទេ ឆ្នាំណាដែរ?

**ឆ៖** ឆ្នាំ៧៧ តែដើមឆ្នាំ មិនមែនចុងឆ្នាំទេ។

**ស៖** តើមានពេលណាមួយ លោកស្រីបានឃើញកងទ័ពវៀតណាមនេះចូលមកក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៧ ដែរទេ? ឃើញមានឃើញកងទ័ព ហើយនិងរថក្រោះចូលមកក្នុងឆ្នាំ១៩៧៧ ដែរទេ?

[១៥:២៦:០៥]

**ឆ៖** ឃើញៗដែរ រថក្រោះ ហើយនិងឆ្នាំពេលនុ៎ងមកពួកវៀតណាមហ្នឹងមកវ៉ៃគ្នាដល់ហ្នឹងទៅ ហើយចូលទៅនឹងផ្ទះខ្ញុំអីហ្នឹង ដាំបាយដាំអីហូបនៅនុ៎ង។ ធ្វើទាំងនំឲ្យខ្ញុំហូបទៀត ធ្វើនំបានឲ្យខ្ញុំហូប។

**ស៖** រឿងរ៉ាវដែលលោកស្រីបានឃើញជនជាតិវៀតណាម ដែលគេចាប់ចងបណ្តើរមុខកង់ហ្នឹង គឺលោកស្រីបានឃើញនៅមុន ឬក៏នៅក្រោយពេលដែលកងទ័ពវៀតណាមបាញ់ផ្លោងចូលមកទឹកដីកម្ពុជាហ្នឹង?

**ឆ៖** ទេ! អត់មែននេះទេ មិនមែនពួកវៀតណាមចាប់ចងដឹកមុខកង់ទេ ខ្មែរយើងតែម្តង ដែលចាប់ដឹកកង់នុ៎ង តែវៀតណាមគេមិនដែលធ្វើអ៊ីចឹងទេ។ គេមិនដែលធ្វើចាប់អ៊ីចឹង ដឹកអ៊ីចឹងទេ។ តែបើខ្មែរយើងមាន ខ្មែរហើយនិងខ្មែរហ្នឹង។ ចាប់ប្រធានភូមិដឹកទៅទាំងថ្ងៃហ្នឹង ដឹកតាមផ្ទះខ្ញុំ ក្បែរផ្ទះខ្ញុំ។ ប្រធានភូមិ ហើយម្នាក់គាត់ធ្វើខាងអនុប្រធានដែរ កំពុងតែហូបបាយបះពីមាត់យកទៅៗតែម្តង បាយនៅរោង។

**ស៖** ខ្ញុំយល់ហើយលោកស្រីថាមិនមែនកងទ័ពវៀតណាមទេ ដែលចាប់ចងក្រុមគ្រួសារវៀតណាមនុ៎ង។ សំណួររបស់ខ្ញុំសួរថាអ៊ីចេះ រឿងរ៉ាវដែលលោកស្រីបានឃើញជនជាតិវៀតណាមគេចងបណ្តើរមុខកង់នុ៎ង ដែលលោកស្រីឆ្លើយមុននុ៎ង តើលោកស្រីបានឃើញហ្នឹងមុនពេលកងទ័ពវៀតណាមបាញ់ចូលមកក្នុងប្រទេសកម្ពុជា ឬក៏ក្រោយ?

**ឆ៖** ក្រោយ។ ហើយនិយាយរួមទៅ វៀតណាមគេមកមែន គេមក គេមិនដែលធ្វើអីយើងទេ គ្រាន់គេមកៗ ប៉ុន្តែបើតាមការពិត ខូចផុតត្រឹមខ្មែរហើយនិងខ្មែរហ្នឹង ខូចណាស់។

[១៥:២៨:៤៧]

**ស៖** លោកស្រីអាចប៉ាន់ប្រមាណបានទេថា នៅក្នុងចុងឆ្នាំ១៩៧៧ហ្នឹងមានកងទ័ពវៀតណាមចូលមកក្នុងភូមិលោកស្រីហ្នឹងប្រហែលជាប៉ុន្មាននាក់?

**ឆ៖** មកច្រើន ពួកកងទ័ព គេមក គេជួយនេះដែរ គេមិនធ្វើបាយអីយើងទេ។ គេមកៗមកចូលមកនេះទៅ។ គេដើរៗតាមផ្លូវគេទៅឆ្ពុយៗទៅ។ យើងដើរតាមយើងទៅ គេៗដើរតាមគេទៅ គេតែគ្នាគេនុ៎ងទៅ។

**ស៖** លោកស្រីអាច កាលដែលលោកស្រីឃើញចំនួនកងទ័ពវៀតណាមហ្នឹង អាចថា១០០នាក់ ១.០០០នាក់ ១០.០០០នាក់ ឬក៏ចំនួនប៉ុន្មានដែរ មកជាមួយនឹងរថក្រោះផងនុ៎ង?

**ឆ៖** មកច្រើនគ្នាដែរ មកជួនណា មកនុ៎ងមកជួនណាដាំបាយផ្ទះខ្ញុំហូប ហូបហើយគេបណ្ដើរគ្នាទៅ ឌីៗ ទៅៗ។ គេទៅគ្នាទៅ ព្រួសៗៗទៅ។ គេគ្មានធ្វើអីយើងផងហ្នឹង។

**ស៖** តើវាអាចថាពួកខាងទ័ពវៀតណាមហ្នឹងចាកចេញទៅនៅថ្ងៃ០៦ មករា ១៩៧៨ បានទេ?

**ឆ៖** វាភ្លេចឆ្នាំអស់ហើយ គ្មានដឹងឆ្នាំណាឆ្នាំណីទេ ព្រោះខ្ញុំវាសឹងតែនេះទៅហើយ។

**ស៖** ខ្ញុំយល់ យូរហើយ។ តើកងទ័ពវៀតណាមហ្នឹងត្រឡប់ទៅវៀតណាមវិញហ្នឹងប្រហែលជាក្នុងរយៈពេលណាដែរ បើគិតពីពេលដែលគេចាប់ខ្លួនប្ដីលោកស្រី?

[១៥:៣១:១២]

**ឆ៖** ទៅ កាលដែលទៅនុ៎ងទៅប្រហែលជាទៅមុនប្ដីខ្ញុំស្លាប់ គេយកប្ដីខ្ញុំទៅ យកទៅមុន គេទៅមុន។ ទៅបាត់អស់បានពួកនុ៎ងគេចាប់សម្លាប់តែម្ដង។

**ស៖** តើគេចាប់ប្ដីរបស់លោកស្រីហ្នឹង ពីព្រោះគេចោទគាត់ថាគាត់ចូលដៃខាងវៀតណាមដែរ ឬទេ?

**ឆ៖** ទេ រឿងគេថាហ្នឹង ខ្ញុំមិនដឹងដែរ មិនបានឮទេ ប៉ុន្តែគ្រាន់ថា អើគេណេះខ្មែរ ខ្មែរផ្សេងទៅវៀតណាមៗផ្សេងទៅ ប៉ុន្តែដល់ក្រោយមកនេះ បានរំដោះខ្ញុំរស់ឡើងវិញហ្នឹង បានវៀតណាមចូលមកតើ! វៀតណាមចូលមក បានរស់ខ្ញុំមានរូបមានរាងទៅទាល់តែសព្វថ្ងៃ ខ្ញុំរត់ប្រផាប់ពភីង យកអង្ករយកស្លឹកគ្រៃ ពកូនពចៅរត់។ មកដល់នេះហ្នឹងបានផ្ទះគ្រាប់បែកនៅព្រែកខ្សាយហ្នឹង បានខ្ញុំត្រឡប់ទៅវិញហ្នឹងវៀតណាមចូលមកហើយ ជួយហើយជីវិតខ្ញុំហើយ ទាំងអស់គ្នា។ កុំតែបានវៀតណាមហ្នឹង ក៏វាងាប់អស់រលីងដែរ ខ្ញុំថាអ៊ីចេះចុះ។ មិនមែនគេកាចតែរហូត គេអាក្រក់តែរហូតទេ ខ្ញុំក៏សរសើរគេដែរ។

ខ្ញុំមិនខឹងគេទេ។

**ស៖** តើលោកស្រីដឹងដែរឬទេ ក្រុមគ្រួសារដែលរៀបការប្ដីប្រពន្ធខ្មែរនោះដែលគេចងបណ្ដើរមុខកង់នោះ តើអ្នកទាំងអស់នោះគេចោទប្រកាន់ថា ចូលដៃជាមួយវៀតណាមដែលថាពួកកងទ័ពវៀតណាមហ្នឹងវ៉ៃចូលមកក្នុងឆ្នាំ១៩៧៧ ហើយក៏បានចេញទៅវិញនៅក្នុងឆ្នាំ១៩៧៨ហ្នឹងឬ?

[១៥:៣៣:២១]

**ឆ៖** អ្ហើ! មិនមែនអ៊ីចឹងទេ។ គេថាតែអ៊ីចេះទេ គេថាពួកអស់នេះសុទ្ធតែពួកក្បត់ គេថាអ៊ីចឹងពួកក្បត់។ គេថាអ្នកដែលចាប់ទៅហ្នឹងសុទ្ធតែពួកក្បត់ទេ។ ហើយខ្ញុំដឹងក្បត់រឿងម៉េចទេ ខ្ញុំមិនដឹងដែរ។ ហើយអាខ្លះគេថាខុសសីលធម៌ ដែលមេធំៗសុទ្ធតែសីលធម៌ហើយ គ្មានអាណាអត់មួយទេ។ អ៊ីចឹងបានខ្ញុំនឹកឃើញសព្វៗ ប្រទេចផ្ដាសាថា អ្ហែងងាប់ ប្ដីអញងាប់ អ្ហែងក៏ងាប់ដែរ! មិនបានប៉ុន្មានគេចាប់អ្ហែងយកទៅវ៉ៃទាំងអស់គ្នាហ្នឹងតែម្ដងទៅ ទាំងអាសន្តិសុខ ទាំងអាអីហ្នឹង វ៉ៃអ្ហែងពាយអស់។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបញ្ចប់ការតាំងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរ សូមឲ្យលោកស្រីជួយបំភ្លឺមួយចំនួន។ ជាដំបូង ខ្ញុំសូមត្រឡប់មកនិយាយអំពីសំណួរដែលបានសួរដោយមេធាវី កូប៉េ។ ខ្ញុំចង់ឲ្យយើងច្បាស់ កុំឲ្យមានការភ័ន្តច្រឡំពាក់ព័ន្ធទៅនឹងរយៈកាលដែលលោកស្រីបានលើកឡើង។ លោកស្រីនិយាយអំពីទាហានវៀតណាមមកផ្ទះរបស់លោកស្រីមកដាំស្លក្នុងផ្ទះលោកស្រី។ លោកស្រីច្បាស់ទេថា ពេលនុំងគឺនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** ខ្ញុំអត់ដឹងស្អីៗទេ តែឃើញតែគេមក។ ខ្ញុំ គេក៏មិនធ្វើអីខ្ញុំៗក៏មិនដឹងធ្វើអីគេដែរ។ ខ្ញុំដឹងតែប៉ុណ្ណឹង។ គេដាំស្លហូបទៅ គេហូបទៅ ជួនណាមានសម្ល គេហុចឲ្យខ្ញុំហូបដែរ។ ហើយខ្ញុំចេះតែថានេះទៅ។ ត្រង់គេម៉េចៗ ខ្ញុំអត់បានដឹង។

[១៥:៣៦:០០]

**ស៖** ទោះបីជាលោកស្រីចាំមិនច្បាស់ក៏ដោយ ក៏ប៉ុន្តែលោកស្រីថាឆ្នាំ៧៧។ ខ្ញុំនឹងអានកិច្ចសម្ភាសន៍របស់លោកស្រីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺលោកស្រីនិយាយអំពីសង្គ្រាមរវាងអាមេរិកាំងជាមួយនឹងខ្មែរក្រហម និង លន់ នល់ គឺឯកសារ E3/7526។ ERN ជាភាសាបារាំងគឺ 00746944, ជាភាសាខ្មែរគឺ 00185376 ជាភាសាបារាំងគឺនៅទំព័រខាងដើម។ ខ្ញុំនឹងអាន ដើម្បីឲ្យបានច្បាស់ ជាភាសាបារាំងគឺ 00746953។ “គឺនៅពេលដែលកងទ័ពរំដោះដឹកនាំនោះ គឺចាប់ពីឆ្នាំ៧៨ហ្នឹងមែនទេ? ហើយចុះប្រជាជននៅក្នុងភូមិលោកស្រីយ៉ាងម៉េចដែរ? លោកស្រីបានឆ្លើយថា៖ អត់មានអីគួរឲ្យកត់សម្គាល់ទេ គឺធម្មតា។ បន្ទាប់មកទៀតអ្នកសម្ភាសហ្នឹង គេសួរលោកស្រីតទៅទៀត៖ អ៊ីចឹងមានន័យថា នៅពេលនុ៎ង គេចាប់ផ្តើមរួចទៅហើយមែនទេ? ហើយការងារប្រជាជនហ្នឹង គេចាត់ចែងរបៀបម៉េចដែរ? ជាគេរៀបចំជាក្រុម ជាសហករណ៍ ឬក៏យ៉ាងម៉េច? កាលនុ៎ងលោកស្រីឆ្លើយថា៖ មានជាក្រុម មានជាកង មានជាសហករណ៍។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅពេលដែលទាហានមកដល់គេមិនដែលធ្វើបាបអីយើងទេ។ ហើយពួកយើងក៏មិនដែលធ្វើអីចំពោះពួកយោធាទាំងនុ៎ងដែរ។ ពេលខ្លះទៅយើងថែមទាំងផ្តល់អាហារទៅឲ្យពួកយោធាទៅទៀត។ ពេលដែលគេមកផ្ទះយើងៗឲ្យពួកគេហូប។ មានអ្នកខ្លះមកពីហាណូយ ហើយមករស់នៅ មកស្នាក់នៅផ្ទះខ្ញុំ។ ផ្ទះខ្ញុំមានអ្នកមកពីហាណូយឡើងពេញ។ ពួកហ្នឹងអត់ចេះខ្មែរអីបន្តិចសោះ។ គេមកនៅផ្ទះខ្ញុំ គេដេកនៅពេញព្រៃៗរង្គើ ហើយឲ្យដាំស្លឲ្យយកទៅឲ្យហូបទៅ។ ពួកខ្ញុំដាំស្លឲ្យគេហូបអ៊ីចឹង។ គេសុទ្ធតែឲ្យយើងហូបមុន និងហើយសហការជាមួយពួករំដោះវាយទាហានអាមេរិកាំង លន់ នល់។” សូមបញ្ចប់ការដកស្រង់។ លោកស្រីសាក្សី តើលោកស្រីនឹកឃើញឡើងវិញទេថា ពេលដែលលោកស្រីឃើញទាហានវៀតណាមហ្នឹង គឺមិនមែនជាពេលវាយប្រយុទ្ធគ្នារវាងខ្មែរក្រហមជាមួយហ្នឹង លន់ នល់ ឬក៏អាមេរិកាំងទេ ឬក៏យ៉ាងម៉េច?

[១៥:៣៨:១៦]

**ឆ៖** ខ្ញុំឃើញ ខ្ញុំឮគេនិយាយប្រាប់ខ្ញុំថា មានអាពួកធៀវគី ហើយនិងអាមេរិកាំងចូល ហ្នឹងខូច

ថាអ៊ីចឹងអ្នា! ហើយបើថាពួកមួយប៉ែកទៀត ដូចថាអត់អី។ ហើយដូចហាណូយហ្នឹង គេមកមែន គេមក ៗមុនដំបូង ដល់ពេលមកទៅគេធ្វើការគេ ដាំស្ពឲ្យហូប។ គេឲ្យយើងដាំស្ល គេសុំបាយ សុំទឹកស្រួលបួល ណាស់។ ហើយដល់យើងដាំហើយ គេឲ្យយើងហូបមុន ខ្លាច គេមិនហ៊ានហូបរបស់យើងទេ គេខ្លាច ពុល គេខ្លាចយើងបំពុលគេងាប់។ ហ្នឹងមកមែន ខ្ញុំតាមការពិតជាក់ស្តែង។

**ស៖** អ៊ីចឹងហើយបានជាខ្ញុំសួរលោកស្រី ថាលោកស្រីចាំទេ ពេលហ្នឹងគឺជាសង្គ្រាមខ្មែរក្រហម ជាមួយនឹង លន់ នល់ ហ្នឹងឬក៏យ៉ាងម៉េច? គឺពេលហ្នឹង គឺមុនពេលខ្មែរក្រហមវាយដណ្តើមយកទីក្រុង ភ្នំពេញ និងខេត្តនានានៅទូទាំងប្រទេសបាន ឬក៏យ៉ាងម៉េច លោកស្រីនឹកឃើញទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗឆ្លើយ!

**លោកស្រី ស៊ិន ផែម៖**

**ឆ៖** បើយករបស់ខ្ញុំ ខ្ញុំថាប្រហែលជាមិននេះទេ ព្រោះខ្មែរក្រហមផ្សេង ហើយនេះផ្សេង អា ហ្នឹងពីរ អាហ្នឹងការយល់របស់ខ្ញុំថាអ៊ីចឹង។

[១៥:៤១:០១]

**ស៖** សំណួរខ្ញុំហ្នឹង ខ្ញុំចង់ដឹងថា ពេលដែលទាហានវៀតណាមមកហូបចុកផ្ទះលោកស្រី ហើយ លោកស្រីដាំស្លឲ្យពួកទាហានហ្នឹងហូបនោះ លោកស្រីចាំទេ ថាមុនពេលខ្មែរក្រហមវាយយកទីក្រុង ភ្នំពេញបានហ្នឹងមែនទេ គឺពេលដែល លន់ នល់ កំពុងតែកាន់អំណាចហ្នឹងមែនទេ?

**ឆ៖** ខ្ញុំវាភ្លេចដែរ មិនដឹងម៉េចទេ តែថា ប៉ុនបើនិយាយរួមទៅទាហានពួករំដោះ ហើយនិងពួក វៀតណាមត្រូវគ្នា ដាំស្លស៊ីអ៊ីចឹង ល្អកល្អិនជាមួយគ្នាដែរ។ បានខ្ញុំថាមិនអី ពួកនុ៎ងមិនអីទេ។

**ស៖** ពេលហ្នឹងគឺពេលក្នុងរបប លន់ នល់ ហ្នឹងមែនទេ?

**ឆ៖** ក្រោយៗ លន់ នល់។

**ស៖** លោកស្រីចាំទេថា គឺហេតុការណ៍ហ្នឹងមុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥ មែនទេ?

**ឆ៖** ខ្ញុំពិបាកថា ខ្ញុំភ្លេចមុខភ្លេចក្រោយ ដូចថាវា -- តែមុនដំបូងដឹងថាឆ្នាំ៧៥ គេដូចថាឡើង មកជ្រួលច្របល់ហើយអង្កាល់នុ៎ង។ ហើយដល់ក្រោយមកឆ្នាំ៧៦ មកចូល៧៧ បាយរួមៗ ហើយដល់ ចុងឆ្នាំ៧៨ ដូចថាបែកអ៊ីចឹងទៅមិនដឹង ៧៩មិនដឹង ខ្ញុំភ្លេចអស់ហើយ យូរដែរ។

**ស៖** ខ្ញុំមិនសួរដេញដោលអីទៀតទេ អ៊ីចឹងខ្ញុំចង់បានការបំភ្លឺមួយទៀត។ អម្បាញ់មិញនេះ

លោកស្រីនិយាយអំពីមនុស្សដែលត្រូវបានចាប់ខ្លួន ហើយគេឲ្យរត់តាមកង់។ សំណួរដំបូងខ្ញុំចង់ដឹងថា លោកស្រីបានឃើញការចាប់ខ្លួនគ្រួសារវៀតណាមហ្នឹង ដោយផ្ទាល់ភ្នែកទេ?

[១៥:៤៣:៣៧]

**ឆ៖** អត់ទេ ខ្ញុំមិនឃើញទេ។ ប៉ុន្តែដូចថាចាប់ថ្ងៃហ្នឹង សម្លាប់ចោលថ្ងៃហ្នឹង ស្អែកឡើងគេប្រាប់ខ្ញុំ អ៊ីចឹង។ ខ្ញុំបានតែគេប្រាប់ដែលហ្នឹង ខ្ញុំដែលដើរទៅណា ខ្ញុំនៅផ្ទះធ្វើការងារ ទៅធ្វើងណោះបាត់ៗទៅ ខ្ញុំមិនសូវដែលនៅផ្ទះផង។

**សៈ** អ៊ីចឹងមុននេះបន្តិច នៅពេលដែលលោកស្រីនិយាយជាមួយនឹងលោកមេធាវី កូប៉េ អំពីអ្នកដែលត្រូវបានគេចាប់ខ្លួន ហើយឲ្យរត់តាមកង់នោះ លោកស្រីនិយាយអំពីការចាប់ខ្លួនផ្សេងទៀតមែនទេ?

**ឆ៖** ជាក់ស្តែងមែនវ៉ៃដើរតាមថ្នល់ខាងត្បូងផ្ទះខ្ញុំមែន ហើយហៅគេ ហៅកូនក្មេងឲ្យជួយវ៉ៃទៀត។ អាហ្នឹងជាក់ស្តែងណាស់អារឿងរត់មុខកង់។

**ប្រធានអង្គជំនុំ៖**

មិនមែនសួរអ៊ីចឹងទេលោកស្រី គេសួរថា អ្នកដែលគេដាក់ឲ្យរត់មុខកង់ហ្នឹង វាជាជនជាតិវៀត-ណាម ឬក៏ជាជនជាតិខ្មែរ អាអ្នកដែលត្រូវគេចាប់នោះ?

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** អាហ្នឹងខ្មែរសុទ្ធតែម្តង ខ្មែរហើយខ្មែរគ្នាយើង គ្មានវៀតណាមណាមកធ្វើអ៊ីចឹងទេ។

[១៥:៤៥:០៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**សៈ** ដើម្បីរំឭកការចងចាំរបស់លោកស្រី គឺនៅក្នុងឯកសាររបស់លោកស្រីដែលបានសម្ភាសជូនមជ្ឈមណ្ឌលឯកសារកម្ពុជា E3/7526, ERN ជាភាសាបារាំងគឺ 00746963, ERN ជាភាសាខ្មែរគឺ 00185385 (សូមទោស) គឺ86។ លោកស្រីបាននិយាយជាមួយអ្នកដែលសម្ភាសលោកស្រីអំពីការចាប់ខ្លួន ហើយឲ្យរត់មុខកង់។ ពេលនោះគេសួរលោកស្រីដូចតទៅ៖ “តើនរណាជាអ្នកដែលគេចាប់ហ្នឹង? ហើយលោកស្រីបានឆ្លើយថា៖ គឺនៅក្នុងភូមិ ក្នុងឃុំ គឺមេភូមិ មេឃុំហ្នឹងហើយជាអ្នកចាប់នោះ។ ពេលដែលគេចាប់ម្តងៗ គឺគេតែងតែធ្វើបែបហ្នឹង។” តើលោកស្រីចាំទេ ថាអ្នកដែលចាប់ហ្នឹង ភាគច្រើនហ្នឹង អ្នកដែលទៅចាប់ហ្នឹង គឺច្រើនតែជាមេភូមិ មេឃុំ ហើយដល់ពេលគេចាប់គេតែងតែធ្វើអ៊ីចឹង គេឲ្យរត់មុខកង់អ៊ីចឹង?

**ឆ៖** ចាប់គ្នា ឲ្យគ្នារត់មុខកង់ ហើយហៅក្មេងឲ្យរើ។ ហើយខ្ញុំថា "រើគេ អ្វែងចាំមើលប្រយ័ត្ន គេរើអ្វែងវិញ"។ ហើយមិនបានប៉ុន្មាន អាខ្លះនេះទៅ គេចាប់យកទៅវៃចោលទៅ អាខ្លះនៅរស់ទៅ គេបញ្ជូនទៅណេះ បញ្ជូនទៅណោះទៅ អ៊ីចឹង។ ហើយខ្ញុំ ខ្ញុំមិនធ្វើអ៊ីចឹងទេ ខ្ញុំមិនហ៊ានទេ។ ទោះបីជាយ៉ាងណាក៏ខ្ញុំមិនហ៊ានដែរ ខ្ញុំខ្លាចណាស់។ ខ្ញុំខ្លាចអាហ្នឹងកម្មពា ខ្លាចកម្មពា។ ធ្វើល្អ បានល្អដូចគ្រាន់បើរបស់ខ្ញុំមែន។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅចំណុចមួយផ្សេងទៀតនៃសក្ខីកម្មរបស់លោកស្រី។ លោកស្រីបាននិយាយអំពីការចាប់ខ្លួនបងប្រុសរបស់លោកស្រី។ លោកស្រីថា ប្រពន្ធកូនរបស់គាត់ត្រូវបានបញ្ជូនទៅខេត្តពោធិ៍សាត់ ហើយក្រោយមកត្រឡប់មកវិញ។ លោកថា បងថ្លៃរបស់លោកនៅរស់។ តើលោកស្រីអាចបញ្ជាក់ពីចំណុចនេះបានទេ?

[១៥:៤៧:៥៥]

**ឆ៖** មែន នៅរស់ ប៉ុន្តែឥឡូវស្លាប់ប្រពន្ធហើយ ឥឡូវទៅនៅស្រុកកូន នៅស្រុកឯជើង។ គាត់នៅរស់ តែកូនៗស្លាប់ខ្លះ នៅខ្លះ។ កូនទៅធ្វើពួករំដោះ ដល់អ៊ីចឹងស្លាប់អស់មួយ អស់ពីរ។

**ស៖** ជាភាសាបារាំង ខ្ញុំឮថា បងប្រុស។ ខ្ញុំៗនិយាយពីប្រពន្ធរបស់បងប្រុសទេ ខ្ញុំនិយាយពីបងថ្លៃលោកស្រីនោះ គាត់នៅរស់ទេ ពេលនុ៎ង?

**ឆ៖** ប្រពន្ធបងប្រុសខ្ញុំក៏ទៅដែរ ទៅកូន ទៅចៅ តូចតាចរញ៉េចរញ៉ាច ដល់ពេលត្រឡប់មកវិញ មកទាំងអស់ អត់មានខូចខាតអីទេ ទៅនៅស្រុកគេហ្នឹង គេជម្លៀសទៅ។

**ស៖** លោកស្រីថា បងថ្លៃមកវិញជាមួយកូនៗ ហើយមុននេះលោកស្រីថា កូនគាត់ពីរនាក់ស្លាប់ អ៊ីចឹងខ្ញុំចង់ដឹងថា កូនពីរនាក់ដែលស្លាប់ហ្នឹង ស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ក្រោយរបបនេះ?

**ឆ៖** វាក្រោយ ប៉ុន្តែដល់ពេល វាចងក វាឈឺពេក វាពិបាកខ្លួនវាពេក ចងក ហើយមួយហ្នឹង ឈឺគឺសដោះ ទើបនឹងស្លាប់ដែរហ្នឹង ហ្នឹងទើបនឹងស្លាប់ឆ្នាំ ២ឆ្នាំ ឆ្នាំមុនហ្នឹង។ ប៉ុណ្ណឹងទេ។

**ស៖** នៅក្នុងកំណត់ហេតុ E3/7794, ERN ជាភាសាបារាំងគឺ – សូមអភ័យទោស ខ្ញុំសូមរកមើលបន្តិចសិន។ ជាភាសាបារាំងគឺ 00285547, ជាភាសាអង់គ្លេសគឺ 00251407, ជាភាសាខ្មែរគឺ 00249918។ លោកស្រីបានឆ្លើយជូនអ្នកស៊ើបអង្កេតអំពីការចាប់ខ្លួនជនជាតិវៀតណាមនៅទួលវិហារ គឺចាប់មួយគ្រួសារតែម្ដង។ លោកស្រីអាចបញ្ជាក់បានទេថា ភូមិទួលវិហារនេះ មានចម្ងាយប៉ុន្មានពីភូមិរបស់លោកស្រី?

**ឆ៖** ជិតណាស់ ឆ្លងព្រែកទៅដល់។

[១៥:៥១:២៥]

**ស៖** ជិតហ្នឹងប្រហែលជាប៉ុន្មាននាទីដែរ ឥឡូវបើយើងដើរពីភូមិរបស់លោកស្រីទៅភូមិនោះ?

**ឆ៖** ខ្ញុំថា ដើរប្រហែលជាមួយម៉ោងកន្លះដល់ហើយ ថាប៉ុណ្ណឹងចុះ។

**ស៖** លោកស្រីក៏បាននិយាយអំពីការចាប់ខ្លួនមនុស្សនៅភូមិស៊ីការ លោកស្រីអាចជម្រាបបានទេថា ភូមិលោកស្រីហ្នឹងទៅភូមិស៊ីការហ្នឹងមានចម្ងាយប៉ុន្មានម៉ែត្រ ប៉ុន្មានគីឡូម៉ែត្រដែរ?

**ឆ៖** ប្រហែល១គីឡូដី។

**ស៖** លោកស្រីក៏បាននិយាយអំពីការចាប់ខ្លួនមនុស្សនៅភូមិកៀនតាសៀវ តើភូមិកៀនតាសៀវនេះមានចម្ងាយប៉ុន្មានពីភូមិលោកស្រី?

**ឆ៖** ចម្ងាយប្រហែល១គីឡូដីដែរ ពីផ្ទះខ្ញុំទៅកៀនតាសៀវ ១គីឡូដីឆ្ងាយអី មួយបន្តិចដើរដល់។

**ស៖** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យលោកស្រីទៅភូមិទាំងពីរបីហ្នឹងញឹកញាប់ទេ?

**ឆ៖** ញឹកញាប់ហើយ ទៅទិញអីវ៉ែអីវ៉ាន់ផ្ទះគេនុំង ទិញដូចថា ម្ហូបស៊ី ស្អីៗលើផ្ទះគេនុំង ហើយស្រាប់តែគេចាប់ទៅបាត់អស់ទៅ។ គេលក់ដូរ។

**ប្រធានអង្គជំនុំ៖**

សាក្សីស្ដាប់ឲ្យបានថា គាត់សួរហ្នឹងកាលពីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ របបខ្មែរក្រហមនោះណ៎ា នៅក្នុងរបបខ្មែរ -- សម័យខ្មែរក្រហម តើលោកស្រីបានទៅផ្ទះពួកគេនុំងដែរឬទេ? ទៅភូមិនុំងដែរឬទេ? ទៅញឹកញាប់ទេ?

[១៥:៥៣:៥២]

**លោកស្រី ស៊ិន ឆែម៖**

**ឆ៖** ខ្ញុំទៅតើ! ហើយចុះមានស្អី រាប់អានគ្នាដូចតែខ្មែរហើយនិងនេះអ៊ីចឹង រាប់អានគ្នា ទៅទិញអីវ៉ែអីវ៉ាន់ស៊ីអី ស៊ីចុកអី ដូចថាម្ហូបម្ហែបអី ទៅសឹងរាល់ថ្ងៃ។ ហើយដល់ពេលស្រាប់តែបាត់ខ្លួនអស់ ខ្ញុំសួរ គេថា អ៎! គេយកទៅបាត់អស់ហើយ។ ថាយកទៅពីអង្កាល់? យកទៅយប់មិញ គេថាអ៊ីចឹង។ ហ្នឹងខ្ញុំច្បាស់អ៊ីចឹង បានខ្ញុំហ៊ាននិយាយ បើមិនច្បាស់ ខ្ញុំក៏មិនហ៊ាននិយាយដែរ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មសាក្សីជាច្រើនរូប ហើយពួកគេបានបញ្ជាក់ថា គេលុប

បំបាត់មិនឲ្យចាយលុយទេនៅក្នុងរបបនោះ។ អ៊ីចឹងលោកស្រីអាចបញ្ជាក់បានទេ ម៉េចបានជាក្នុងរបបខ្មែរក្រហមនោះ លោកស្រីអាចទិញអីវ៉ាន់បាននៅក្នុងភូមិ ឬក៏តាមភូមិផ្សេងៗហ្នឹង?

**ឆ៖** ស្រូវដូរទៅ គ្មានលុយទេ ប៉ុន្តែដូរស្រូវ ដូរជាអី ខ្ញុំ *(ឮមិនច្បាស់)* អ៊ីចឹងទៅ។ ហ្នឹងចេះតែនេះទៅ ធ្វើឲ្យតែពីរស់នៅទៅ អ៊ីចឹង។

**ស៖** បើអ៊ីចឹងមានន័យថា ការចាប់ខ្លួនមនុស្សនៅក្នុងភូមិទាំងបីហ្នឹង គឺលោកស្រីបានឮពីគេទេ លោកស្រីមិនបានឃើញផ្ទាល់ភ្នែកទេ មែនទេ?

**ឆ៖** មិនបានឃើញទេ ពីព្រោះខ្ញុំអាណាទៅហ៊ានទៅមើល បើទោះជាឃើញ ក៏ខ្ញុំមិនហ៊ានមាត់ដែរ ព្រោះខ្ញុំលាក់ទុកហើយ ខ្ញុំខ្លាចណាស់។ គេតែគេខ្សឹបប្រាប់ បើគេខ្សឹបប្រាប់ បានខ្ញុំដឹង។ បងប្អូនខ្ញុំនៅក្បែរនុំងខ្ញុំមួយគំនរ។

**ស៖** ប្រសិនលោកស្រី នៅចាំហ្នឹង លោកស្រីអាចប្រាប់បានទេ អ្នកណាខ្លះជាអ្នកនិយាយប្រាប់លោកស្រីហ្នឹង ពេលហ្នឹងហើយពួកគេហ្នឹងមានមុខងារអ្វីខ្លះនៅក្នុងភូមិរបស់លោកស្រី?

[១៥:៥៦:០៧]

**ឆ៖** ខ្ញុំអត់បានចាំទេ វាភ្លេចអស់ហើយ ប៉ុន្តែសុទ្ធតែបងប្អូនខ្ញុំនៅកៀនតាសៀវនុំង ហើយគេប្រាប់ខ្ញុំ។ តែបងប្អូនហ្នឹងវាមិនដឹងពីណាមួយទេ ឥឡូវខ្ញុំភ្លេចអស់ហើយ កាលមុនខ្ញុំចាំ ឥឡូវខ្ញុំភ្លេចហើយ ភ្លេចអស់ហើយ មិនដឹងម៉េចទេ។

**ស៖** ទោះបីជាលោកស្រីមិនចាំថាអ្នកណាក៏ដោយ ក៏ប៉ុន្តែលោកស្រីនឹកឃើញថា ក្នុងចំណោមទាំងអស់ហ្នឹង មានអ្នកណាមានកាន់តំណែងអីធំដុំទេ ឬក៏អ្នកនិយាយប្រាប់នោះ សុទ្ធតែជាប្រជាជនធម្មតាទេ?

**ឆ៖** ប្រជាជនធម្មតាហ្នឹង គេឃើញអ៊ីចឹងគេស្រៀវ គេនេះគេចង់ងាប់ហើយ គេកេះប្រាប់ខ្ញុំ ហើយតែឥឡូវខ្ញុំវាភ្លេចមនុស្ស អាមនុស្សប្រាប់នោះ ភ្លេចបាត់អស់ហើយ។ តាំងពីណាណីមកហើយ វាភ្លេចភ្លាំងអស់រលីងហើយ។

**ស៖** ពួកគាត់មានបានប្រាប់ថាគេចាប់មនុស្សហើយហ្នឹង គេយកទៅណាទៀតទេ?

**ឆ៖** គេថាយកទៅវាយចោល។ គេប្រាប់ទាំងកន្លែងគេវាយទៀតណោះ គេរើសបានមាសមួយគំនរ គេអ្នកយកមាស។

[១៥:៥៧:៣៦]

សះ អ៊ីចឹងមានន័យថា អ្នកដែលគេប្រាប់លោកស្រីហ្នឹង គឺពួកគាត់បានឃើញគេចាប់ខ្លួនផ្ទាល់ភ្នែក ហើយតាមដានទៅមើល ឃើញគេនាំយកទៅសម្លាប់ចោលអ៊ីចឹងទៀត ឬក៏ពួកគាត់គ្រាន់តែឮតាមគេដែរ មកប្រាប់លោកស្រីតទៀតទេ?

ឆះ ខ្ញុំបានឮគេចាប់យកទៅ យកទៅកប់នៅម៉ឺនសាយ កប់ម៉ឺនសាយ គេទៅគាស់យកមាសបានមាសៗប៉ុន្មានជិត១គីឡូ។ ចុះបើយកទៅអស់រលីងហើយមានពីណានៅ យកទាំងប្ដីទាំងប្រពន្ធនិងកូនទៅ ហើយមាសគេរកស៊ី។ ឥឡូវមនុស្សហ្នឹងនៅរស់សព្វថ្ងៃ ដែលអ្នកយកមាសគេហ្នឹងនៅ។

សះ ខ្ញុំមិនមែនសួរអ៊ីចឹងទេ។ ខ្ញុំសួរថាអ្នកដែលប្រាប់លោកស្រីអំពីការចាប់ខ្លួនមនុស្សនោះ ពួកគាត់ហ្នឹងគ្រាន់តែឮពីគេទេ ឬក៏ពួកគាត់បានឃើញគេចាប់ហ្នឹងផ្ទាល់ភ្នែកហើយតាមទៅមើល ពេលដែលគេនាំយកទៅសម្លាប់ទៀតហ្នឹង?

ឆះ គេឃើញផ្ទាល់ភ្នែក គេអ្នកនៅជិតគេឃើញផ្ទាល់ភ្នែក បានគេហ៊ានប្រាប់ខ្ញុំ។ បើគេមិនឃើញគេមិនហ៊ានប្រាប់ខ្ញុំទេ។

សះ ដោយសារតែការចាប់ខ្លួនហ្នឹង គឺនៅមួយកន្លែង ហើយគេសម្លាប់នៅកន្លែងមួយទៀត។ អ៊ីចឹងមានន័យថា អ្នកដែលប្រាប់លោកស្រីហ្នឹង ត្រូវបានគេអនុញ្ញាតឲ្យទៅដល់កន្លែងដែលគេសម្លាប់មនុស្សហ្នឹងអី បានជាបានឃើញហ្នឹង? លោកស្រីអាច មាននៅចាំឈ្មោះអ្នកណាខ្លះទេ លោកស្រីនឹកទៅមើល មានចាំឈ្មោះទេ?

[១៥:៥៩:៤០]

ឆះ គេផ្ទះគេនៅក្បែរគ្នានឹងផ្ទះវៀតណាមហ្នឹងណ៎ា ផ្ទះនេះហ្នឹង ហើយដល់ពេលព្រឹកឡើងគេប្រាប់ៗបន្តៗគ្នាទៅ គេប្រាប់ខ្ញុំ អ៊ីចេះ។ ខ្ញុំមិនបានឃើញ ហើយអាគេហ្នឹងគេឃើញ អាគេជាក់ស្ដែងហ្នឹង គេឃើញនឹងភ្នែក។ ហើយដល់អ៊ីចឹងគេ ព្រលឹមឡើងបានគេប្រាប់ថា “អ្ហូ យកទៅហើយ ពូសោម-ពូសៅ យំគគ្រឹកគគ្រេកទៅអស់ហើយ” ថាអ៊ីចឹង។ ខ្ញុំៗដឹងតែប៉ុណ្ណឹងទេ តែដឹងពីណា ខ្ញុំភ្លេចអស់ហើយ។ ខ្ញុំមិនដឹងពីណាទេ អ្នកប្រាប់ហ្នឹង។

សះ ដូច្នេះមានន័យថា គេឃើញផ្ទាល់ភ្នែកតែម្ដង ឃើញមានអ្នកចាប់គេចាប់មនុស្សទៅហើយនាំយកទៅហ្នឹងឃើញដោយផ្ទាល់ភ្នែកហើយ មកប្រាប់លោកស្រី មែនទេ?

ឆះ ចាស ប្រាប់ខ្ញុំ ហើយដល់ខ្ញុំៗនឹកឃើញ វាអាណោចអាធ័មគ្នាដែរ។

សះ លោកប្រធានដល់ម៉ោងហើយ ក៏ប៉ុន្តែនេះជាប្រធានបទចុងក្រោយ គឺវាពាក់ព័ន្ធទៅនឹង

លោក ខៀវ សំផន។ លោកស្រី តើលោកស្រីច្បាស់ទេថា លោកស្រីមិនដែលជួបលោក ខៀវ សំផន ទេ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ធ៖** ខ្ញុំមិនដែលស្គាល់ទេ មិនដឹងដូចម៉េចទេ តែខ្ញុំឮតែគេនិយាយដែរ គេនិយាយថា ខៀវ សំផន រត់ចូល ប៉ុល ពត។ ខ្ញុំឮតែអ៊ីចឹង តែប៉ុណ្ណឹង ខ្ញុំមិនដឹងថាគេម៉េចៗ ខ្ញុំមិនដែលឃើញគេទេ មិនដែលស្គាល់គេទេ។

**ស៖** លោកស្រីថា គាត់រត់ចូល ប៉ុល ពត ហ្នឹងលោកស្រីនិយាយពីពេលណាដែរ?

[១៦:០១:៣៤]

**ធ៖** ចាប់ពីដំបូងមកនោះ ហ្នឹងដែលធ្វើការហ្នឹង ធ្វើៗដល់ពេលនេះស្រាប់តែថា ខៀវ សំផន រត់ចូល ប៉ុល ពត ហើយ ថាអ៊ីចឹង។ ខ្ញុំឮគេនិយាយអ៊ីចឹង ហើយខ្ញុំក៏ អាហ្នឹងតាមតែពាក្យគេដែរហ្នឹង គេអ្នកនិយាយ ខ្ញុំឮ តែដែលគេប្រុសៗ គេមិនឲ្យខ្ញុំឮទេ តែស្រីៗនិយាយគ្នាឯងដឹង គេចេះ។ ហើយខ្ញុំចេះអី ខ្ញុំ ខ្ញុំមិនដែលចេះអក្សរផង។ ខ្ញុំដែលដឹងស្អីខ្ញុំ។ ខ្ញុំនេះដែរ ប៉ុនកាលនុំងវានៅនិយាយបាន ដល់ពេលក្រោយមកបិទឈឹង លែងមានអាណានិយាយអីហើយ។

**ស៖** អម្បាញ់មិញនេះ នៅពេលដែលលោកស្រីនិយាយជាមួយសហព្រះរាជអាជ្ញា លោកស្រីថា ខៀវ សំផន ចូលជាមួយខ្នាំង។ លោកស្រីនិយាយអំពីខ្មាំងណាដែរ ពេលនុំង?

**ធ៖** ខ្មាំងខ្ញុំថា ប៉ុល ពត។

**ស៖** ខ្មាំងហ្នឹងជាខ្មាំងរបស់អ្នកណា?

**ធ៖** មិនដឹងទេ។ ខ្ញុំដល់ចង់ដឹងដែរ។ ពាក្យថា "ខ្មាំងៗ" ខ្ញុំមិនដឹងដែរ ឮគេថាដែរ គេថាខ្មាំង។ ហើយដល់ពេលអ៊ីចឹងវា ឮប្រទូសប្រទាំងគ្នាអ៊ីចឹងទៅ បានដឹងខ្លួនថា ដឹងជាស្អីៗទេ។

**ស៖** លោកស្រីចាំទេ ពេលហ្នឹងគឺក្នុងអំឡុង គឺមុនរដ្ឋប្រហារ លន់ នល់ ឬក៏ក្រោយរដ្ឋប្រហារ លន់ លន់ ពេលដែលលោកស្រីថាលោក ខៀវ សំផន រត់ចូលទៅជាមួយខ្មាំង ជាមួយប៉ុល ពត ហ្នឹង? មុនរដ្ឋប្រហារ លន់ នល់ ឬក៏ក្រោយរដ្ឋប្រហារ លន់ នល់?

**ធ៖** ខ្ញុំភ្លេចអស់ហើយ អត់ដឹង គឺភ្លេច វាភ្លេចហើយ ខ្វល់ខ្ញុំដែរ។

**ស៖** បើខ្ញុំមិនសង្កត់ធ្ងន់លើចំណុចនេះទេ អ៊ីចឹងខ្ញុំចង់សួរជាចុងក្រោយថា នៅក្នុងសម័យនោះ លោកស្រីមិនដឹងថាលោក ខៀវ សំផន មានមុខតំណែងអ្វីទេ មែនទេ?

[១៦:០៤:០៩]

**ឆ៖** ស្តាប់មិនបានទេ មិនដឹងស្អី។

**ស៖** ខ្ញុំសួរជាចុងក្រោយម្តងទៀត។ ក្នុងសម័យនោះ លោកស្រីធ្លាប់ឮគេនិយាយអំពីលោក ខៀវ សំផន ទេ ក្រៅពីលោកស្រីឮថាគាត់រត់ចូល ប៉ុល ពត ហើយនោះ?

**ឆ៖** ឮតើ ខ្ញុំចេះបានខ្ញុំនេះ ហ៊ូ នឹម, ហ៊ូ យន់ គាត់ទៅធ្វើស្រូវប្រាំងស្រុកខ្ញុំ។ ហើយដល់ពេលត្រឡប់មកវិញហ្នឹង ឆ្នាំ៧៥មិនដឹង ៧៦មិនដឹងទេ។ គាត់ទៅធ្វើ ហើយក៏៧៧ ប៉ុន្តែមិនមែនទេ ប្រហែលជា៧០ហើយ។ តែទៅធ្វើទៅ បានត្រឡប់មកវិញមិនបានប៉ុន្មានឮថា ខៀវ សំផន រត់ចូលខ្លាំងហើយ រត់ចូល ប៉ុល ពត ហើយ ថាអ៊ីចឹង។ បានខ្ញុំឮគេនិយាយអ៊ីចឹង បានខ្ញុំដឹងថាគេចូល ប៉ុល ពត។ បានតែបន្តិចហ្នឹង ក្នុងឯណេះក្នុងឯណោះហ្នឹងទៅ ខ្ញុំមិនដឹងផង។ ខ្ញុំឯណេះចាំតែហូរនោម ហើយនិងហូរអាចម៍ ដឹងអីខ្ញុំ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ដោយសារតែអស់ពេល ដូច្នេះខ្ញុំអស់សំណួរហើយ។

[១៦:០៥:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ដល់ពេលនេះសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ិន ឆែម បានដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោកស្រី ស៊ិន ឆែម ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ។ ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីជួបតែសំណាងល្អ មានសុខភាពល្អ បានសេចក្តីសុខសេចក្តីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី ស៊ិន ឆែម វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយសវនាការនៅថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅស្អែក ថ្ងៃអង្គារ ទី១៥ ខែធ្នូ ឆ្នាំ

២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-846។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមកាលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីរត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*